Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

91023

# ផ្ទៃមេឃស្រឡះ

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា



## ប្រធានបទពិសេស៖

1. វិស័យអង្ករនៅកម្ពុជា
2. ប្រធានបទពិសេសទី២៖ ការបង្កើតកាលានុវត្តភាពសម្រាប់ក្រុមហ៊ុននៅកម្ពុជា៖ លទ្ធផលរកឃើញពីការវាយតម្លៃចុងក្រោយលើបរិយាកាសវិនិយោគ

WORLD BANK GROUP

ខែតុលា ២០១៤

# ផ្លែមេឃស្រឡះ

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែ តុលា ឆ្នាំ ២០១៤

WORLD BANK GROUP

**@ រក្សាសិទ្ធិគ្រប់យ៉ាង**

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះគឺជាផលិតផលរបស់ធនាគារពិភពលោក។

របកគំហើញ ការបកស្រាយ និងការសន្និដ្ឋាន នៅក្នុងបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះគឺជារបកគំហើញ ការបកស្រាយ និងការសន្និដ្ឋានរបស់បុគ្គលិកធនាគារពិភពលោក និងមិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់គណៈគ្រប់គ្រងរបស់ធនាគាររបស់ក្រុមប្រឹក្សាភិបាល ឬរដ្ឋាភិបាលដែលធនាគារពិភពលោកតំណាងនោះទេ។

ធនាគារពិភពលោកមិនធានាភាពត្រឹមត្រូវនៃទិន្នន័យដែលមាននៅក្នុងវណ្ណកម្មនេះទេ។

# អារម្ភកថា និងសេចក្តីថ្លែងអំណរគុណ

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) គឺជាផលិតផលមួយរបស់បុគ្គលិករបស់ធនាគារពិភពលោក។ ផលិតផលនេះត្រូវបានរៀបចំដោយ លោក លី សូដេត (Sodeth Ly) និង លោក អេនរិកេ អាល់ដាហ្ស ខារ៉ូល (Enrique Aldaz – Carroll) ផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តការគ្រប់គ្រងសារពើពន្ធពិភពលោក (MFMGP) ការិយាល័យធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា។ កញ្ញា គី លីនណា (Linna Ky) មានតួនាទីជាជំនួយការស្រាវជ្រាវ។ ក្រុមការងារធ្វើការក្រោមការដឹកនាំរបស់លោក ម៉ាស្វ អេ វើហ្គិស (Mathew A. Verghis) ប្រធានផ្នែកការអនុវត្តនៃ MFMGP។ លោក គង់ មុនីច័ន្ទ (Munichan Kung) ផ្នែកអភិវឌ្ឍទីប្រជុំជន ជនបទ និងសង្គម បានរួមចំណែកចំពោះការសរសេរផ្នែកប្រធានបទពិសេសស្តីពី "**វិស័យអង្ករនៅកម្ពុជា**" ហើយលោក ជូលៀន ឡាទីមែរ គ្លើក (Julian Latimer Clarke) ផ្នែកពាណិជ្ជកម្ម និងការប្រកួតប្រជែង បានរួមចំណែកចំពោះការសរសេរផ្នែកបញ្ហាពិសេសស្តីពី "**ការវាយតម្លៃបរិយាកាសវិនិយោគ**"។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះយោបល់ការប្រឹក្សា និងការណែនាំ ដែល លោកអ៊ូលរិក ហ្សាចៅ (Ulrich Zachau) នាយកប្រចាំប្រទេសកម្ពុជាសម្រាប់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក និងលោក អាឡាសាន សូ (Alassane Sow) នាយកគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជា។

របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានផលិតរៀងរាល់ឆមាស ដើម្បីផ្តល់ព័ត៌មានថ្មីៗលើការអភិវឌ្ឍផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានបោះពុម្ពផ្សាយ និងចែកចាយយ៉ាងទូលំទូលាយទៅកាន់អាជ្ញាធរកម្ពុជា សហគមន៍ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមអ្នកវិភាគ និងរៀបចំគោលនយោបាយ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសិក្សាស្រាវជ្រាវ។ របាយការណ៍បច្ចុប្បន្នភាពនេះ ត្រូវបានកំណត់ពេលឲ្យស្របជាមួយនឹងការបោះពុម្ពផ្សាយបច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ារបស់ផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តការគ្រប់គ្រងសារពើពន្ធពិភពលោក (MFMGP)នៃធនាគារពិភពលោក។

យើងបានទទួលយោបល់ និងសំណើដ៏មានតម្លៃពីមិត្តរួមការងារ ដែលរួមមាន លោក សាប៊ីស អាលី មូហីប (Shabih Ali Mohib) អង្គភាពគ្រប់គ្រងក្នុងប្រទេស លោក សឺជី ហ្សរីយា (Sergiy Zorya) ផ្នែកវិស័យកសិកម្ម លោក នាក់ សមសែន (Samsen Neak) ផ្នែកវិស័យភាពក្រីក្រ។ យើងក៏សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះយោបល់ និងសំណើច្បាស់លាស់ដែល លោកស្រី រ៉ាឆាដា អនាន់តាវ៉ាសីលប៉ា (Ratchada Anantavrasilpa) និងលោក ជេមសឺ សីវើដ (James Seward) ផ្នែកវិស័យហិរញ្ញវត្ថុ និងទីផ្សារ។

របាយការណ៍នេះក៏ទទួលបានការរួមចំណែកពីយោបល់ ការណែនាំ និងទស្សនៈរបស់ភាគីពាក់ព័ន្ធជាច្រើននៅក្នុងរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន ស្ថាប័នដៃគូអភិវឌ្ឍន៍ និងអ្នកសិក្សាស្រាវជ្រាវ។ ក្រុមការងារសូមអរគុណចំពោះពួកគាត់ដែលបានចំណាយពេល និងផ្តល់ការរួមចំណែក។

យើងសូមថ្លែងនូវសេចក្ដីដឹងគុណយ៉ាងខ្លាំងចំពោះអាជ្ញាធរកម្ពុជា ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ក្នុងការរៀបចំបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ។

ក្រុមការងារផ្នែកទំនាក់ទំនងនៅកម្ពុជា ដែលរួមមាន លោក ប៊ូ សារឿន (Saroeun Bou) និង លោកស្រី សុភានិត សំអឿន (Sophinith Sam Oeun) បានរៀបចំអត្ថបទផ្សព្វផ្សាយតាមសារព័ត៌មាន អត្ថបទបង្ហាញតាមគេហទំព័រ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារនៅកម្ពុជា សូមចូលទៅមើលនៅ www.worldbank.org/cambodia។

ដើម្បីដាក់បញ្ចូលទៅក្នុងបញ្ជីចែកចាយបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាតាមអ៊ីម៉ែលនិងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធ សូមទាក់ទងកញ្ញា គី លីនណា តាមសារអេឡិកត្រូនិច lky@worldbank.org។ សម្រាប់សំណួរស្ដីពីខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org)។

# មាតិកា


ខ្លឹមសារសង្ខេប ..... 1

វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗ..... 7

១. វិស័យផលិតកម្ម ..... 7

ក) វិស័យកាត់ដេរ ..... 8

ខ) វិស័យសំណង់ និងអចលនទ្រព្យ ..... 9

គ) វិស័យទេសចរណ៍..... 10

ឃ) វិស័យកសិកម្ម..... 10

២. វិស័យទូទាត់ក្រៅប្រទេស..... 17

ក) ការនាំចេញ ..... 17

ខ) ការនាំចូល ..... 18

៣. អតិផរណា..... 18

៤. វិស័យរូបិយវត្ថុ..... 19

ក) រូបិយវត្ថុសរុប អត្រាប្តូរប្រាក់ និងអត្រាការប្រាក់..... 19

ខ) វិស័យធនាគារ ..... 21

៥. វិស័យសារពើពន្ធ ..... 22

ក) សមាសភាគចំណូល ..... 22

ខ) សមាសភាគចំណាយ..... 23

គ) សមតុល្យសារពើពន្ធ ..... 23

ខ្លឹមសារគន្លឹះ និងអនុសាសន៍..... 25

ប្រធានបទពិសេសទី ១ ៖ វិស័យអង្ករនៅកម្ពុជា..... 27

១. ការជំរុញ..... 27

២. ផលិតកម្ម និងការកែច្នៃស្រូវ ..... 27

៣. ការនាំចេញអង្ករ..... 28

៤. នីតិវិធីនាំចេញអង្ករ និងភស្តុភារ..... 29

៥. តម្លៃអង្ករ..... 30

៦. សេចក្តីសន្និដ្ឋាន..... 31

ប្រធានបទពិសេសទី ២ ៖ការបង្កើតកាលានុវត្តភាពសម្រាប់ក្រុមហ៊ុននៅកម្ពុជា៖ លទ្ធផលរកឃើញពីការវាយតម្លៃចុងក្រោយលើបរិយាកាសវិនិយោគ ..... 33

១. ការជំរុញ..... 33

២. វឌ្ឍនភាព និងឧបសគ្គដែលនៅតែមាន..... 33

សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា..... 37

## ខ្លឹមសារសង្ខេប

**កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅតែមានកម្រិតខ្ពស់ដដែល ទោះបីជាប្រទេសជិតខាងកំពុងមានភាពមិនប្រាកដប្រជា និងអស្ថិរភាពក៏ដោយ។** កំណើនពិតក្នុងប្រទេសកម្ពុជាសម្រាប់ឆ្នាំ ២០១៤ ត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ៧,២ ភាគរយ ដោយសារតែវិស័យកាត់ដេរ សំណង់ និងសេវាកម្ម។ ជារួម ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចមានភាពល្អ ដោយមានការពង្រឹងផ្នែកសារពើពន្ធចេញពីការគ្រប់គ្រងចំណូលបានល្អជាងមុន។ នៅក្នុងឆ្នាំ ២០១៥ ដោយមើលឃើញពីកំណើនទំនុកចិត្ត និងការវិលត្រឡប់នៃស្ថិរភាពនយោបាយក្នុងខែកក្កដា ឆ្នាំ ២០១៤ បន្ទាប់ពីការបញ្ចប់ការជាប់គាំងផ្នែកនយោបាយរយៈពេលមួយឆ្នាំមក រួមជាមួយនឹងស្ថានភាពសេដ្ឋកិច្ចសកល ដែលមានភាពប្រសើរឡើងនោះអត្រាកំណើនសេដ្ឋកិច្ចពិតរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ ២០១៥ ត្រូវបានប៉ាន់ស្មានថានឹង វិលត្រឡប់មកភាពល្អប្រសើរឡើងវិញទាំងស្រុង ហើយនឹងមានចំនួន ៧,៥ ភាគរយ ដែលជាអត្រាកំណើន ប្រហាក់ប្រហែលនឹងអត្រាកំណើនក្នុងឆ្នាំ ២០១៣ ដែរ។ ហានិភ័យមួយចំនួនដែលអាចធ្វើឲ្យប៉ះពាល់ដល់ កំណើនសេដ្ឋកិច្ចរឹងមាំដែលបានប៉ាន់ស្មាននេះ រួមមាន ការកើតមានជាថ្មីនៃការរំជើបរំជួលរបស់កម្មករ គ្រោះធម្មជាតិ ជាពិសេសលទ្ធភាពនៃទឹកជំនន់ខ្លាំង និងភាពមិនប្រាកដប្រជាផ្នែកនយោបាយក្នុងតំបន់ផងដែរ។

## វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗ

**វិស័យកាត់ដេរនៅបន្តជាម៉ាស៊ីនកំណើនសំខាន់របស់ប្រទេសកម្ពុជា ទោះបីជាវិស័យសំណង់ ដែលជាម៉ាស៊ីនជំរុញកំណើនសំខាន់បំផុតទីពីរ បានកើនឡើងផុតពីវិស័យទេសចរណ៍ និងវិស័យដំណាំ ដែលមានល្បឿនកំណើនវិស័យនេះយឺតជាងមុន។** វិស័យកាត់ដេរមានអត្រាកំណើនចំនួន ១៤,១ ភាគរយ ធៀបនឹងឆ្នាំមុនគិតមកត្រឹមពាក់កណ្ដាលឆ្នាំ ២០១៤ ដែលបានទទួលការគាំទ្រពីបរិយាកាសសេដ្ឋកិច្ចសកលដែលមានភាពប្រសើរឡើង និងកំណើនស្ថិរភាពទីផ្សារការងារ។ វិស័យសំណង់បានកើនឡើង ដោយសារតែមានកំណើនទំនុកចិត្តក្នុងប្រទេស ដោយវិស័យនេះមានកំណើនខ្ពស់ជាងវិស័យទេសចរណ៍ និង វិស័យដំណាំ។ កំណើនវិស័យសេវាកម្ម នៅតែមានភាពល្អប្រសើរ ទោះបីជាកំណើនវិស័យទេសចរណ៍ មានល្បឿនយឺត ដោយមានអត្រាកំណើននៃភ្ញៀវទេសចរត្រឹមតែ ៥,២ ភាគរយប៉ុណ្ណោះ ក្នុងអំឡុងប្រាំមួយខែដំបូងបើធៀបនឹងឆ្នាំមុន។ ការថយចុះនៃកំណើនវិស័យទេសចរណ៍ គឺដោយសារតែអស្ថិរភាពនយោបាយនៅប្រទេសថៃ និងភាពតានតឹងរវាងប្រទេសវៀតណាម និងប្រទេសចិន។ វិស័យកសិកម្មមានកំណើនយឺត ដោយតម្លៃកសិផលក្នុងពិភពលោកបន្តថយចុះ។

**ការកាត់បន្ថយភាពក្រីក្រនៅតែបន្តដោយសារតែកំណើនសេដ្ឋកិច្ចខ្លាំង ប៉ុន្តែក្នុងល្បឿនទាបជាងមុន។** អត្រាភាពក្រីក្របានធ្លាក់ចុះមកត្រឹម ១៨,៦ ភាគរយ ក្នុងឆ្នាំ២០១២ ដែលធ្លាក់ចុះ ១,៩ ភាគរយ ធៀបនឹងឆ្នាំ ២០១១។ ទោះជាយ៉ាងណា ល្បឿននៃការកាត់បន្ថយភាពក្រីក្រក្នុងអំឡុងឆ្នាំ២០១១-២០១២ យឺតជាងល្បឿននៅអំឡុងឆ្នាំ២០០៤-២០១១ ដោយក្នុងអំឡុងពេលនោះ អត្រាភាពក្រីក្របានធ្លាក់ចុះចំនួន ៤,៧ ភាគរយក្នុងមួយឆ្នាំៗ

ដោយសារតែមានកំណើនតម្លៃអង្ករ ដែលបានជួយដល់ប្រជាជនក្រីក្រតាមតំបន់ជនបទ។

**ការបន្តកំណើនសេដ្ឋកិច្ចល្អក្នុងឆ្នាំនេះបណ្ដាលមកពីដំណើរការវិស័យទូទាត់ក្រៅប្រទេសប្រកបដោយស្ថិរភាព នៅខណៈពេលដែលមានកំណើនលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស ដែលជួយផ្ដល់ហិរញ្ញប្បទានភាគច្រើន ដល់កំណើនឱនភាពគណនីចរន្ត ដែលរួមចំណែកដល់កំណើតប្រាក់បំរុងអន្តរជាតិ។** កំណើននាំចេញសំលៀកបំពាក់នៅតែបន្តកើនឡើង ស្របពេលនឹងកំណើនលំហូរការវិនិយោគផ្ទាល់ពីបរទេស ដោយសារតែការវិលត្រឡប់មកវិញនៃស្ថិរភាពទីផ្សារការងារ និងចំណាប់អារម្មណ៍សាជាថ្មីរបស់វិនិយោគិនលើវិស័យសំណង់ និងអចលនទ្រព្យ ដែលបានធ្វើឲ្យមានកំណើនការនាំចូលសម្ភារសំណង់។ ការនាំចូលទំនិញប្រើប្រាស់ ក៏មានការកើនឡើងផងដែរ ដោយទំនិញនាំចូលនាំមុខគឺយានយន្ត និងប្រេង។ ឱនភាពគណនីចរន្តបច្ចុប្បន្នត្រូវបានព្យាករថា នឹងឈានដល់ ១១,៣ ភាគរយ នៃផលិតផលក្នុងស្រុកសរុប ដែលមានកម្រិតខ្ពស់ជាងកម្រិតឱនភាពគណនីចរន្តសម្រាប់ឆ្នាំ ២០១៣ បន្តិច ដោយកម្រិតព្យាករណ៍នៃឱនភាពឆ្នាំ ២០១៣ មានចំនួន ១០,៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប ដែលភាគច្រើនទទួលហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស។ ដូច្នេះ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងយ៉ាងលឿនដល់ ៤,២ ពាន់លានដុល្លាអាមេរិក ឬប្រមាណ ៣,៥ ខែនៃការនាំចូលនៅត្រឹមពាក់កណ្ដាលឆ្នាំ ២០១៤ ពី ៣,៦ ពាន់លានដុល្លាអាមេរិក ឬប្រមាណ ៣,៤ ខែនៃការនាំចូលនៅត្រឹមបំណាច់ឆ្នាំ ២០១៣។

**ទោះជាអតិផរណា និងស្ថិរភាពតម្លៃបានកើនឡើងបន្តិច ក៏នៅតែស្ថិតក្នុងកម្រិតអាចទទួលយកបានដែលជំរុញឲ្យមានកំណើនសេដ្ឋកិច្ច និងគាំទ្រដល់ភាពក្រីក្រ។** កម្រិតអតិផរណាប្រចាំឆ្នាំបានកើនឡើងដល់ ៤,៩ ភាគរយ ត្រឹមពាក់កណ្ដាលឆ្នាំ ២០១៤ ដែលជាកម្រិតខ្ពស់ជាងបន្តិចបើធៀបទៅនឹងកម្រិតកំណើន ៤,៦ ភាគរយនៅបំណាច់ឆ្នាំ ២០១៣។ ថ្លៃទំនិញឧបភោគបរិភោគភាគច្រើននៅតែមានស្ថិរភាព ទោះបីជាថ្លៃទំនិញឧបភោគបរិភោគមួយចំនួន ដូចជា សាច់ និងផ្លែឈើ និងទំនិញមិនមែនជាទំនិញឧបភោគបរិភោគផ្សេងទៀត ដូចជា សេវាកម្មសាធារណៈ (ទឹកភ្លើង) មានការកើនឡើងបន្តិចបន្តួចជាបន្តបន្ទាប់ក្តី។ កម្រិតអតិផរណាក្នុងតំបន់ និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត នៅតែមានកម្រិតសមស្រប។

**កំណើនប្រាក់បញ្ញើក្នុងវិស័យឯកជនមានការកើនឡើងយ៉ាងលឿន ដោយសារតែកំណើនការជឿទុកចិត្តឡើងវិញទៅលើសេដ្ឋកិច្ច ដែលធ្វើឲ្យវិស័យធនាគារមានស្ថិរភាពកាន់តែខ្លាំងឡើង។** ប្រាក់បញ្ញើក្នុងវិស័យឯកជន បានកើនឡើងយ៉ាងលឿនរហូតដល់ ៨,០៩ ពាន់លានដុល្លាអាមេរិក ឬមានអត្រាកើនឡើង ២២,២ ភាគរយត្រឹមពាក់កណ្ដាលឆ្នាំ ២០១៤ ដោយធៀបនឹងបំណាច់ឆ្នាំ ២០១៣ ដែលមានចំនួន ៦,៨៨ ពាន់លានដុល្លាអាមេរិក ឬ ១៤,២ ភាគរយក្នុងមួយឆ្នាំ។ កំណើនឥណទានក៏មានការថយចុះពី ២៦,៧ ភាគរយ មកត្រឹម ២១,៨ ភាគរយក្នុងមួយឆ្នាំ ក្នុងអំឡុងពេលដូចគ្នានេះ។ ការកើនឡើងនៃកំណើនប្រាក់បញ្ញើ រួមជាមួយនឹងការថយចុះនៃកំណើនឥណទាន បានធ្វើឲ្យមានការថយចុះអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើពី ៩០ ភាគរយនៅបំណាច់ឆ្នាំ ២០១៣ មកត្រឹម

៨២,២ ភាគរយត្រឹមពាក់កណ្តាលឆ្នាំ២០១៤។ អត្រាការប្រាក់កម្ចីក្នុងរយៈពេលខ្លី មានការថយចុះបន្តិចពី ១១,៣ ភាគរយនៅបំណាច់ឆ្នាំ ២០១៣ មកត្រឹម ១១,២ ភាគរយត្រឹមខែ មេសា ឆ្នាំ ២០១៤ ដោយសារតែកំណើននៃការប្រកួតប្រជែងរបស់ធនាគារ។

**ប្រាក់រៀលមានតម្លៃថេរ ដោយមានតម្លៃប្រមាណ ៤០០០ រៀលក្នុងមួយដុល្លាអាមេរិកដោយសារការកំណត់អត្រាប្តូរប្រាក់នេះ ធ្វើឲ្យមានការឡើងថ្លៃបន្តិចនៃអត្រាប្តូរប្រាក់ពិតនៃប្រាក់រៀល។** អត្រាប្តូរប្រាក់ក្នុងមួយដុល្លាអាមេរិកគឺ ៤.០៤០ រៀលត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ ចំណែកនៅបំណាច់ឆ្នាំមុន មួយដុល្លាអាមេរិកស្មើនឹង ៣.៩៩៥ រៀល។ ការកំណត់អត្រាប្តូរប្រាក់ ឲ្យមានតម្លៃប្រមាណ ៤.០០០ រៀលក្នុងមួយដុល្លា បានធ្វើឲ្យមានការឡើងថ្លៃបន្តិចបន្តួចនាពេលថ្មីៗនេះនៃអត្រាប្តូរប្រាក់ពិតនៃប្រាក់រៀល ដោយសារតែថ្មីៗ នេះ ប្រាក់ដុល្លាអាមេរិក បានឡើងថ្លៃបើប្រៀបទៅនឹងរូបិយប័ណ្ណសំខាន់ៗផ្សេងទៀត ដូចជា ប្រាក់អឺរ៉ូ និងប្រាក់យ័នប្រទេសចិន ដែលជារូបិយប័ណ្ណរបស់ដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា។

**ដំណើរការសារពើពន្ធត្រូវបានពង្រឹងបន្ថែម ដោយសារតែការគ្រប់គ្រងចំណូលមានភាពប្រសើរជាងមុន ដែលបានផ្តល់ហិរញ្ញប្បទានបន្ថែមទៀតគាំទ្រដល់ការចំណាយសាធារណៈសំខាន់ៗ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** ឱនភាពសារពើពន្ធសរុប (រួមទាំងជំនួយឥតសំណង) ត្រូវបានព្យាករថានឹងមានភាពប្រសើរឡើងជាបន្តទៅទៀត និងថយចុះពី ២,៧ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៣ មកត្រឹម ២,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបឆ្នាំ ២០១៤។ ស្ថានភាពប្រសើរនេះដោយសារតែការបង្កើនការប្រមូលចំណូល ដែលបានកើនឡើងយ៉ាងលឿនចំនួន ២១ ភាគរយ ក្នុងអំឡុងពេលបួនខែដំបូង ខណៈពេលដែលការចំណាយដែលមានកម្រិតទាបតាំងពីដំបូង នឹងរក្សាកម្រិតដដែលទៅតាមថវិកាដែលបានគ្រោងទុក។ ឱនភាពសារពើពន្ធនៅតែបន្តទទួលហិរញ្ញប្បទានដ៏ច្រើនពីមូលនិធិក្រៅប្រទេស។ ដូច្នេះ ប្រាក់សន្សំរបស់រដ្ឋាភិបាលបានកើនពី ៧០០ លានដុល្លាអាមេរិកនៅបំណាច់ឆ្នាំ ២០១៣ ដល់ ៩៣១ លានដុល្លាអាមេរិក ត្រឹមពាក់កណ្តាលឆ្នាំ ២០១៤។ ចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុល ដែលត្រូវបានវាយតម្លៃដោយការវិភាគរួមគ្នារវាង ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិអំពីនិរន្តរភាពបំណុល (DSA) ដែលបានធ្វើក្នុងឆ្នាំ ២០១៣ បានបង្ហាញថា ចំណាត់ថ្នាក់នេះនៅមានកម្រិតទាបនៅឡើយ។

## ស្ថានភាពនាពេលអនាគត បញ្ហាប្រឈមថ្មីៗ និងអនុសាសន៍

**ស្ថានភាពកំណើននាពេលអនាគតហាក់មានភាពល្អប្រសើរ ដោយសារតែមានស្ថិរភាពនយោបាយក្នុងប្រទេសសាជាថ្មី កំណើនភាពប្រសើរឡើងនៃសេដ្ឋកិច្ចក្នុងសហរដ្ឋអាមេរិក និងមានស្ថិរភាពក្នុងប្រទេសថៃ ឡើងវិញ ដែលជំរុញឲ្យមានកំណើនផលិតផលក្នុងស្រុកសរុបចំនួន ៧,៥ ភាគរយ ក្នុងឆ្នាំ ២០១៥ប្រហាក់ប្រហែលនឹងកំណើនក្នុងឆ្នាំ២០១៣ ដែរ។** ស្ថានភាពនៃការនាំចេញសម្លៀកបំពាក់នាពេលខាងមុខនៅតែមានភាពវិជ្ជមាន ខណៈពេល

ដែលមានការរំពឹងថា សកម្មភាពក្នុងវិស័យ សំណង់ និងសេវាកម្ម នឹងនៅតែមានភាពសកម្ម ហើយវិស័យទេសចរណ៍ នឹងមានភាពប្រសើរ ឡើងវិញ ដោយសារតែកំណើនស្ថិរភាពរបស់ ប្រទេសថៃ។ ទោះជាយ៉ាងណាក៏ដោយ កំណើន វិស័យកសិកម្ម នឹងនៅតែបន្តទទួលរងផលប៉ះ ពាល់ពីការធ្លាក់ចុះតម្លៃ កសិផលក្នុងទីផ្សារ អន្តរជាតិ។

**យ៉ាងណាក៏ដោយ នៅតែមានហានិភ័យមួយចំនួន ដែលអាចប៉ះពាល់ដល់កំណើនដែលបានព្យាករ។** ហានិភ័យទាំងនេះមានដូចជា លទ្ធភាពនៃការ រំជើបរំជួលឡើងវិញរបស់កម្មករ ទឹកជំនន់រដូវ វស្សា ដែលអាចប៉ះពាល់យ៉ាងខ្លាំងលើដំណាំខុស ពីធម្មតា មួយផ្នែកដោយសារលក្ខខណ្ឌអាកាស ធាតុ El Nino ការធ្លាក់ចុះតម្លៃអង្ករដោយសារតែ ការចាប់ផ្ដើមការបន្តនាំចេញអង្កររបស់ប្រទេសថៃ នៅត្រីមាសទី ៣ ក្នុងឆ្នាំនេះ និងភាពមិនប្រាកដ ប្រជាផ្នែកនយោបាយក្នុងតំបន់។

**តើប្រទេសកម្ពុជាអាចបន្តរក្សា និងជំរុញកំណើន សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រដោយរបៀប ណា? បញ្ហាប្រឈមសំខាន់ៗនាពេលខាងមុខ គឺ ការជំរុញវិស័យកសិកម្ម និងវិស័យទេសចរណ៍សា ជាថ្មីឡើងវិញ។** ដូចបានបង្ហាញក្នុងផ្នែកប្រធានបទ ពិសេសទីមួយ កំណើនផលិតកម្មស្រូវមានល្បឿន យឺតជាងមុនចាប់ពីឆ្នាំ ២០១២ ហើយដោយសារ តែបញ្ហាផ្ទៃដីដាំដុះមិនអាចបង្កើនច្រើនទៀតបាន កំណើនខ្ពស់ឡើងវិញនឹងអាស្រ័យទៅលើកំណើន ផលិតភាពស្រូវ និងគុណភាព ជាជាងការពង្រីកផ្ទៃ ដី។ វិធានការបង្កើនផលិតភាពកសិកម្ម រួមទាំងការ បង្កើនការវិនិយោគសាធារណៈលើសេវាកម្មប្រឹក្សា អំពីកសិដ្ឋាន ការអភិវឌ្ឍន៍ពូជ និងហេដ្ឋារចនា សម្ព័ន្ធស្រោចស្រព ការពង្រឹងការទប់ទល់ទៅនឹង ឥទ្ធិពលអវិជ្ជមាន ការបើកចំហទីផ្សារថ្មី នឹងជួយឲ្យ វិស័យកសិកម្មស្ទុះឡើងវិញ។ ការកែលម្អការ ចំណាយលើការកិនស្រូវ និងភស្តុភារ នឹងជួយ ដោះស្រាយមូលហេតុសំខាន់ពីរ ដែលធ្វើឲ្យកម្ពុជា បាត់បង់ការប្រកួតប្រជែង នៃតម្លៃផលិតផល នៅកសិដ្ឋាន។ ការបង្កើនលទ្ធភាពទទួលបាន ឥណទានសម្រាប់អ្នកផលិតស្រូវ និងអ្នកកិនស្រូវ និង ការកាត់បន្ថយការចំណាយក្នុងការធ្វើធុរៈកិច្ច នឹងជួយបង្កើនបរិមាណកិនស្រូវ និងកាត់បន្ថយ ការចំណាយលើការកិនស្រូវ។ ការកែលម្អភស្តុភារ ក៏នឹងជួយបង្កើនការប្រកួតប្រជែងនៃផលិតកម្ម និងការនាំចេញកសិកម្ម ដែលអាចជួយឲ្យកម្ពុជា ឈានទៅជិតសម្រេចបានគោលដៅនាំចេញអង្ករ ចំនួនមួយលានតោន។ ការកែលម្អហេដ្ឋារចនាស ម្ព័ន្ធ ជាមួយនឹងការប្រឹងប្រែងសម្របសម្រួលរវាង អាជ្ញាធរថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន វិស័យឯកជន និង សហគមន៍មូលដ្ឋាន នឹងជួយជំរុញការពង្រីកទី តាំងទាក់ទាញភ្ញៀវទេសចរ ឲ្យលើសពីឧទ្យាន ប្រាសាទបុរាណអង្គរ។

**ការសម្របសម្រួលកំណើននៃវិស័យកម្មន្តសាល ក៏ នឹងមានសារៈសំខាន់ក្នុងការរក្សា និងជំរុញកំណើន សេដ្ឋកិច្ចដែរ។** ដូចដែលបានបង្ហាញនៅក្នុងប្រធាន បទ ពិសេសទី ២ ការអង្កេតសហគ្រាសនៃការវាយ តម្លៃ បរិយាកាសវិនិយោគនាពេលខាងមុខ បង្ហាញ ថា បរិយាកាសធុរៈកិច្ចបន្តរាំងស្ទះដល់ការប្រកួត ប្រជែង របស់ក្រុមហ៊ុននៅកម្ពុជា។ ឧបសគ្គចម្បង សម្រាប់ក្រុមហ៊ុននៅតែជាលទ្ធភាពទទួលបាននិង ថ្លៃអគ្គិសនី ការចំណាយក្រៅផ្លូវការ និងការអនុវត្ត ដោយគ្មានលក្ខណៈប្រកួតប្រជែង។ ការអង្កេតក៏

បានបង្ហាញថា តំបន់សេដ្ឋកិច្ចពិសេស ដែលមានគោលបំណងផ្តល់បរិយាកាស ធុរៈកិច្ចប្រសើរជាងមុន មិនទាន់បានផ្តល់អត្ថប្រយោជន៍ ផ្សេងៗដែលវិនិយោគិនបរទេសរំពឹងទុកនៅឡើយទេ។ ដូច្នេះ កំណើនសេដ្ឋកិច្ចដ៏រឹងមាំផ្តល់ជាកាលានុវត្តភាពសម្រាប់កែលម្អបរិយាកាសធុរៈកិច្ច ដោយត្រូវដោះស្រាយតម្លៃអគ្គិសនីខ្ពស់តាមរយៈការទិញដោយមានតម្លាភាព ការបន្តធ្វើស្វ័យប្រវត្តិកម្មដំណើរការធុរៈកិច្ច បង្កើនការសម្របសម្រួលពាណិជ្ជកម្ម ការបង្កើនភាពទាក់ទាញតំបន់សេដ្ឋកិច្ចពិសេស ការបញ្ចប់ច្បាប់ស្តីពីការប្រកួតប្រជែង និងការវិនិយោគទុន ដែលពង្រឹងបរិយាកាសវិនិយោគ និងសម្រួលការចុះបញ្ជីពាណិជ្ជកម្ម។ ដើម្បីបង្កើនការនាំចេញបន្ថែមដោយបង្កើនការទទួលផលប្រយោជន៍ពីការងើបឡើងវិញនៃសេដ្ឋកិច្ចសកល ជាការសំខាន់ផងដែរត្រូវរក្សាស្ថិរភាពនយោបាយ និងសម្រេចបាននូវដំណើរការចរចាប្រាក់ឈ្នួលត្រីភាគីដោយតម្លាភាព និងច្បាស់លាស់ ទៅលើប្រាក់ឈ្នួលសម្រាប់វិស័យកាត់ដេរ។ ការធ្វើបែបនេះនឹងជួយទាក់ទាញគម្រោងវិនិយោគពីបរទេសថែមទៀត ដែលផ្លាស់ទីពីកន្លែងដែលមានសេដ្ឋកិច្ចលូតលាស់ក្នុងតំបន់នោះ។

**ការរក្សាស្ថិរភាពក្នុងវិស័យហិរញ្ញវត្ថុតាមរយៈការពង្រឹងការគ្រប់គ្រងធនាគារ នឹងជួយទប់ស្កាត់ការធ្លាក់ចុះលឿនជាគំហ៊ុកនៅក្នុងវិស័យកសិកម្ម និងអចលនទ្រព្យ** រួមទាំងពង្រឹងលទ្ធភាពទប់ទល់របស់ប្រទេសទៅនឹងការប្រែប្រួលខ្លាំងដែលអាចកើតមាននៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។

**ជារួម ការបង្កើនការវិនិយោគលើដើមទុន កំណែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ ការកែលម្អការអប់រំក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងជួយឲ្យកម្ពុជាត្រឡប់ទៅឈរលើវិថីនៃកំណើនខ្ពស់សាជាថ្មីវិញ។** ការពង្រីកមូលដ្ឋានប្រមូលពន្ធ និងការពង្រឹងការគ្រប់គ្រងពន្ធ នឹងជួយផ្តល់ហិរញ្ញប្បទានដល់ការចំណាយលើកិច្ចការអភិវឌ្ឍចាំបាច់នេះ។ ការអនុវត្តកំណែទម្រង់ដោយជោគជ័យ នឹងធ្វើឲ្យមានការវិនិយោគបន្ថែមចំនួនជាង ៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប និងធ្វើឲ្យកម្ពុជាសម្រេចបានកំណើនផលិតផលក្នុងស្រុកសរុបលើសពី ៨ ភាគរយ។

**ការបង្កើតនូវរបៀបវារៈកំណែទម្រង់យ៉ាងជាក់លាក់ដោយមានគោលដៅដែលផ្សារភ្ជាប់ទៅនឹងកំណែទម្រង់ជាអាទិភាព និងក្របខណ្ឌតាមដានដ៏រឹងមាំមួយ នឹងជួយពង្រឹងប្រសិទ្ធភាពនៃការអនុវត្តរបស់រដ្ឋាភិបាល។** យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដែលមានរយៈពេល ៥ ឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យ៉ាងច្បាស់អំពីបញ្ហាប្រឈម និងចំណុចអាទិភាពនៃការអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជា។ ការបង្កើតផែនការសកម្មភាពលម្អិតជាក់លាក់ដែលផ្សារភ្ជាប់ទៅនឹងអាទិភាព និងការបង្កើតប្រព័ន្ធត្រួតពិនិត្យរឹងមាំមួយ ដើម្បីត្រួតពិនិត្យការអនុវត្ត នឹងជួយឲ្យកម្ពុជាដោះស្រាយបញ្ហាប្រឈមនៃការអនុវត្ត និងសម្រេចបាននូវគោលដៅជាអាទិភាពរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព។

# វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗ

## ១. វិស័យផលិតកម្ម

**១. កំណើនសេដ្ឋកិច្ចនៅតែមានកម្រិតខ្ពស់ ចំណែកកំណើនពិតសម្រាប់ឆ្នាំ២០១៤ ត្រូវបានប៉ាន់ស្មានថានឹងមានចំនួន ៧,២ ភាគរយ ដូចការព្យាករណ៍ពីមុន ដែលនៅក្រោមអត្រាកំណើនឆ្នាំ២០១៣ដែលមាន ៧,៤ ភាគរយ** (រូប១)។ ការនាំចេញសម្លៀក បំពាក់នៅតែបន្តមានកំណើន ដោយមានអត្រាកំណើន ១៤,១ ភាគរយត្រឹមពាក់កណ្តាលឆ្នាំ២០១៤។ កំណើននេះកើតមានឡើងបណ្តាលមកពីបរិយាកាសសេដ្ឋកិច្ចសកលល្អ និងស្ថិរភាព ទីផ្សារការងារកាន់តែប្រសើរ។ ទំនុកចិត្តសាជាថ្មី និងការវិលត្រឡប់មកវិញនៃស្ថិរភាពទីផ្សារការងារកាន់តែប្រសើរជំរុញឲ្យមានកំណើន ក្នុងវិស័យសំណង់ ដោយតម្លៃគម្រោងសាងសង់ដែលបានទទួលការអនុម័តមានចំនួន ២,៥ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ៣០,៥ ភាគរយត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ ធៀបនឹងឆ្នាំមុន។ សកម្មភាពសេដ្ឋកិច្ចក្នុងវិស័យសេវាកម្មនៅតែមាន ទោះបីជា វិស័យទេសចរណ៍ មានកំណើនយឺត ដោយមានអត្រាកំណើនភ្ញៀវទេសចរមានត្រឹមតែ ៥,២ ភាគរយ ធៀបនឹងឆ្នាំមុនក្នុងរយៈពេលប្រាំមួយខែដំបូង ដោយសារអស្ថិរភាពក្នុងប្រទេសជិតខាង។ វិស័យកសិកម្មមានការរីកចម្រើនក្នុងកម្រិតមធ្យមប៉ុណ្ណោះ ដោយមានការធ្លាក់តម្លៃកសិផល និងការថយចុះនៃកំណើនទិន្នផលស្រូវ និងផ្លែដំឡូងជុះ។

**២. ដោយសារមានការកើតមានសាជាថ្មីនៃស្ថិរភាពនយោបាយក្នុងប្រទេស និងតំបន់ និងការងើបឡើងវិញនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក អត្រាកំណើនពិតសម្រាប់ឆ្នាំ២០១៥ ត្រូវបានរំពឹងថានឹងងើបឡើងវិញដោយនឹងមានអត្រាកំណើន ៧,៥ ភាគរយ ដែលជាអត្រាប្រហាក់ប្រហែលទៅនឹង អត្រាកំណើនកាលពីឆ្នាំ២០១៣ ដែរ។** ស្ថានភាពល្អពេលអនាគតត្រូវបានកំណត់ឡើងដោយសារតែការរំពឹងថា ការនាំចេញសម្លៀកបំពាក់នឹងកើនឡើង ដោយសារតែកំណើននៃការប្រើប្រាស់នៅសហរដ្ឋអាមេរិក ប្រព័ន្ធអនុគ្រោះ "អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ" (EBA)[1] របស់សហភាពអឺរ៉ុប (EU) និងការទទួលបានស្ថិរភាពទីផ្សារការងារ សកម្មភាពវិស័យសំណង់ដែលនៅតែមានកម្រិតខ្ពស់ និងកំណើនវិស័យសេវាកម្មក្នុងកម្រិតខ្ពស់ និងការរំពឹងថា វិស័យទេសចរណ៍ នឹងមានកម្រិតខ្ពស់ឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានហានិភ័យមួយចំនួនចំពោះកំណើន ដែលបានព្យាករនោះ ដោយហានិភ័យទាំងនោះរួមមាន ទឹកជំនន់រដូវវស្សា ដែលអាចបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងជាងធម្មតា មួយផ្នែកដោយសារលក្ខខណ្ឌអាកាសធាតុ El Nino ការចាប់ផ្តើមបន្តនាំចេញស្រូវឡើងវិញរបស់ប្រទេសថៃនៅក្នុង ត្រីមាសទី ៣ ដែលអាចធ្វើឲ្យ

[1] ប្រព័ន្ធអនុគ្រោះពន្ធ "អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ" របស់សហភាពអឺរ៉ុប ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ សម្រាប់ផ្តល់លទ្ធភាពឲ្យប្រទេសដែលមានការរីកច្រើនតិចតួច នាំចេញផលិតផលរបស់ខ្លួនទៅសហភាពអឺរ៉ុបដោយរួចពន្ធ និងមិនកំណត់បរិមាណទំនិញលើកលែងតែអាវុធ និងគ្រឿងសព្វាវុធ។ នៅក្នុងប្រព័ន្ធនេះ មានប្រទេសទទួលផលចំនួន ៤៩។ ប្រព័ន្ធអនុគ្រោះទូទៅ (GSP) ថ្មីត្រូវបានបង្កើតឡើងក្នុងសហភាពអឺរ៉ុបនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១៤។ នៅក្នុងប្រព័ន្ធអនុគ្រោះទូទៅថ្មីនេះ មានការពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធអ្វីគ្រប់យ៉ាងលើកលែងតែអាវុធ។ តាមរយៈការផ្តោតការអនុគ្រោះទៅលើប្រទេសដែលត្រូវការអនុគ្រោះទាំងនោះបំផុត (ប្រទេសដែលមានចំណូលទាប និងប្រទេសមានការរីកចម្រើនតិចតួច) ប្រព័ន្ធអនុគ្រោះទូទៅថ្មីនេះ មានចំនួនអ្នកទទួលផលតិចជាងមុន។ នៅពេលដែលប្រទេសមួយឆ្លងផុតដំណាក់កាលនៃការអភិវឌ្ឍន៍មានការទទួលស្គាល់ទៅលើកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសទាំងនោះ ហើយអង្គការសហប្រជាជាតិលែងចាត់ទុកប្រទេសទាំងនោះជា "ប្រទេសដែលមានការរីកចម្រើនតិចតួច" ទៀតហើយ។ ហេតុដូច្នេះ ប្រព័ន្ធអនុគ្រោះអ្វីគ្រប់យ៉ាងលើកលែងតែអាវុធ លែងចាំបាច់ទៀតហើយ។ ដំណើរការដ៏រលូនក្នុងការផ្លាស់ប្តូរស្ថានភាព ត្រូវបានធានាតាមរយៈការផ្លាស់ប្តូរដែលមានរយៈពេលបីឆ្នាំ ក្នុងអំឡុងពេលបន្តអនុវត្តប្រព័ន្ធអនុគ្រោះអ្វីគ្រប់យ៉ាងលើកលែងតែអាវុធ។ ការធ្វើបែបនេះអាចជួយកាត់បន្ថយវិបត្តិលំហូរពាណិជ្ជកម្ម។
ប្រភព៖ (http://trade.ec.europa.eu/doclib/docs/2013/april/tradoc_150983.pdf)
មានការលំបាកក្នុងការប៉ាន់ស្មានពីកាលបរិច្ឆេទដែលប្រទេសកម្ពុជានឹងចាកចេញពីប្រព័ន្ធអ្វីគ្រប់យ៉ាងលើកលែងតែអាវុធ ដោយសារតែអង្គការសហប្រជាជាតិកំណត់ថា ប្រទេសមួយលែងចាត់ទុកជា "ប្រទេសដែលមានការរីកចម្រើនតិចតួច" ដោយផ្អែកលើការវិវឌ្ឍនៃសូចនាករបី ៖ ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ ការវាស់វែងលើការអភិវឌ្ឍន៍ធនធានមនុស្ស (សន្ទស្សន៍ទ្រព្យសម្បត្តិមនុស្ស) និងការវាស់វែងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច (សន្ទស្សន៍នៃភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច)។ ប្រទេសកម្ពុជាអាចចាកចេញពីប្រព័ន្ធអ្វីគ្រប់យ៉ាងលើកលែងតែអាវុធប្រហែលនៅដើមទសវត្សរ៍ឆ្នាំ ២០២០។

តម្លៃស្រូវបន្តធ្លាក់ចុះ និងភាពតានតឹងផ្នែកនយោបាយក្នុងតំបន់។

**រូប ១** **កំណើនពិតក្នុងអំឡុងពេលបន្ទាប់ពីមានវិបត្តិមានភាពស្របនឹងសក្តានុពល។ ការរួមចំណែកចំពោះកំណើនផសសពិត (គិតជាភាគរយ)**




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ និងតួលេខប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

៣. កំណើនសេដ្ឋកិច្ចខ្ពស់នៅតែរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែកម្រិតកាត់បន្ថយនេះទាបជាងកម្រិតពីមុន។ អត្រាភាពក្រីក្របានធ្លាក់ចុះមកត្រឹម ១៨,៦ ភាគរយ ក្នុងឆ្នាំ២០១២ ដោយបានធ្លាក់ចុះ ១,៩ ភាគរយ បើធៀបនឹងអត្រាភាពក្រីក្រឆ្នាំ ២០១១។ ទោះជាយ៉ាងណាក៏ដោយកម្រិតនៃការកាត់បន្ថយភាពក្រីក្រក្នុងអំឡុងឆ្នាំ២០១១-២០១២ ទាបជាងកម្រិតនៃការកាត់បន្ថយក្នុងអំឡុងឆ្នាំ ២០០៤-២០១១ ដោយក្នុងអំឡុងពេលនោះ អត្រាភាពក្រីក្របានធ្លាក់ចុះចំនួន ៤,៧ ភាគរយក្នុងមួយឆ្នាំ នៅពេលដែលមានកំណើនតម្លៃស្រូវដែលបានជួយដល់ប្រជាជនក្រីក្រ នៅតាមតំបន់ជនបទ។

## ក) វិស័យកាត់ដេរ

**៤. វិស័យកាត់ដេរមានភាពរីកចម្រើន ទោះបីជាមានអស្ថិរភាពកម្លាំងពលកម្ម និងភាពមិនប្រាកដប្រជាផ្នែកនយោបាយកាលពីឆ្នាំមុនក៏ដោយ** (រូប ២)។ ផលិតកម្មសម្លៀកបំពាក់ ដែលត្រូវបាននាំចេញស្ទើរតែទាំងអស់នោះ បានបន្តលូតលាស់បន្ថែមទៀត ហើយវិស័យនេះបានទាក់ទាញការ វិនិយោគយ៉ាងច្រើន។ ការនាំចេញសម្លៀកបំពាក់នៅតែមានការកើនឡើង ដោយមានទឹកប្រាក់សរុបចំនួន ២,៦ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ១៤,១ ភាគរយ ត្រឹម ខែ មិថុនា ឆ្នាំ ២០១៤ ធៀបនឹងឆ្នាំមុន ដែលមានទឹកប្រាក់សរុបចំនួន ២,៣ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ១៧,៤ ភាគរយ។ បើយើងគិតជាទឹកប្រាក់ ចំនួនទឹកប្រាក់នៃការនាំចេញសម្លៀកបំពាក់ទៅកាន់សហភាពអឺរ៉ុប ដែលមានចំនួន ៣៧ ភាគរយនៃទឹកប្រាក់សរុបនៃការនាំចេញសម្លៀកបំពាក់ មានចំនួនច្រើនជាងទឹកប្រាក់ នៃការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក ដែលស្មើនឹង ៣៦ ភាគរយ ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៤។ បើយើងគិតជាបរិមាណ ចំនួននៃការនាំចេញសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក នៅតែមានកម្រិតខ្ពស់ជាងគេ ស្មើនឹង ៤៦ ភាគរយនៃបរិមាណ សម្លៀកបំពាក់នាំចេញសរុប ហើយចំនួនការនាំចេញសម្លៀកបំពាក់ទៅសហភាពអឺរ៉ុប មានចំនួន ៣៤ ភាគរយ ដែលជាបរិមាណខ្ពស់ជាងគេ បន្ទាប់ពីបរិមាណទៅប្រទេសអាមេរិក។ ចំណុចនេះបានឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រនៃការនាំចេញផលិតផលសម្លៀកបំពាក់មានតម្លៃខ្ពស់ ទៅកាន់សហភាពអឺរ៉ុប ដើម្បីទទួលអត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះ"អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ (EBA)" របស់សហភាពអឺរ៉ុប។

រូប ២

**កំណើនការនាំចេញសម្លៀកបំពាក់នៅបន្តគាំទ្រដល់កំណើនសេដ្ឋកិច្ចពិត**

ការនាំចេញសម្លៀកបំពាក់ (ពីដើមឆ្នាំដល់បច្ចុប្បន្ន គិតជាលានដុល្លាអាមេរិក)




ប្រភព ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

## ២) វិស័យសំណង់ និងអចលនទ្រព្យ

**៥. ដោយសារតែមានស្ថិរភាពនយោបាយឡើងវិញ វិនិយោគិនមានចំណាប់អារម្មណ៍សាជាថ្មីលើគម្រោងសាងសង់ចាប់ពីខ្នាតមធ្យមរហូតដល់ខ្នាតធំក្នុងវិស័យសេវាកម្ម ជាពិសេសក្នុងវិស័យលក់រាយ និងអនុវិស័យហិរញ្ញវត្ថុ ព្រមទាំងក្នុងផ្នែកសាងសង់ការិយាល័យ និងលំនៅដ្ឋានផង។** កត្តានេះបានរួមចំណែកដល់ការលូតលាស់ខ្លាំងក្នុង វិស័យសំណង់ និងអចលនទ្រព្យ។ តម្លៃគម្រោងសាងសង់ ដែលបានទទួលការអនុញ្ញាត (រូប៣) ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតម្លៃគម្រោងវិនិយោគ (អចលនទ្រព្យ) ក្នុងវិស័យទេសចរណ៍ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) (រូប ៤) បានកើនឡើងយ៉ាងលឿនរហូតដល់ ២,៥ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ៣០,៥ ភាគរយ និង ២៥៨ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ១៩៤ ភាគរយត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ ធៀបនឹងឆ្នាំមុន។ ការលូតលាស់ក្នុងវិស័យសំណង់ និងសេវាកម្ម ទន្ទឹមនឹងកំណើនវិស័យទេសចរណ៍ដែលមានល្បឿនយឺតជាងមុន បានឆ្លុះបញ្ចាំងពីកំណើននៃការជឿទុកចិត្តរបស់វិនិយោគិន ចំពោះសេដ្ឋកិច្ច។

**៦. ទោះបីជាយ៉ាងណា វាមានសារៈសំខាន់ក្នុងការទប់ស្កាត់ហានិភ័យសំខាន់ៗ ពាក់ព័ន្ធនឹងកំណើន វិស័យសំណង់ និងអចលនទ្រព្យ។** ការរីកលូតលាស់នៃវិស័យនេះទើបតែបានចាប់ផ្តើមហើយទទួលបានហិរញ្ញប្បទានភាគច្រើន ពីលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស ដោយតួនាទីនៃឥណទាន ក្នុងស្រុកបានថយចុះ ដែលបានកើនឡើងក្នុងកម្រិតតិចតួចជាងមុន ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៤ (សូមមើលផ្នែកស្តីពីវិស័យរូបិយវត្ថុខាងក្រោម សម្រាប់ព័ត៌មានលម្អិត)។ បើទោះបីជាមានការងើបឡើងវិញក្នុងវិស័យសំណង់ ក្នុងពេលថ្មីៗនេះ ហើយវិស័យអចលនទ្រព្យ គឺជាការអភិវឌ្ឍន៍ដែលទទួលបានការស្វាគមន៍ក៏ដោយ ប៉ុន្តែការរីកលូតលាស់នេះនេះបានធ្វើឲ្យមានហានិភ័យសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹង (១) វដ្តដែលជាប់មកជាមួយក្នុងវិស័យសំណង់ (២) ចំនួនការវិនិយោគផ្ទាល់ពីបរទេសច្រើន ដែលមានភាពងាយរងគ្រោះ ប្រសិនបើ និង/ឬ នៅពេលដែលការវិនិយោគផ្ទាល់ពីបរទេសធ្លាក់ចុះ (៣) ពពុះកើតពីការប្រថុយស្មាន (៤) ភាពប្រឈមជាប្រចាំចំពោះគោលនយោបាយដីធ្លីសម្រាប់ កំណើនការគ្រប់គ្រងដីប្រកបដោយតម្លាភាព ការកាត់បន្ថយភាពក្រីក្រ និងភាពរីកចម្រើនជារួម។ បទពិសោធន៍នៅអន្តរជាតិបង្ហាញថា កំណើនដែលជំរុញដោយវិស័យសំណង់ងាយនឹងប្រែប្រួល និងមិនសូវមានសមធម៌ទេ ដែលទាមទារឱ្យការពារចំពោះការរីកចម្រើននៃវិស័យសំណង់ដែលពុំមាននិរន្តរភាព។

រូប ៣

**ចំណាប់អារម្មណ៍សាជាថ្មីលើគម្រោងសាងសង់ក្នុងឆ្នាំ២០១៤**

លិខិតអនុញ្ញាតសាងសង់ (YTD, y/y% change)




ប្រភព ៖ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

រូប ៤ **គម្រោងទេសចរណ៍ (អចលនទ្រព្យ) មានការកើនឡើងបន្ទាប់ពីកំណើនអវិជ្ជមានកាលពីឆ្នាំមុន។** គម្រោងក្នុងវិស័យទេសចរណ៍ដែលត្រូវបានអនុម័ត (YTD, y/y % change)




ប្រភព ៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

រូប ៥ **កំណើនភ្ញៀវទេសចរនៅតែបន្ត ប៉ុន្តែមានល្បឿនយឺតជាង**
(YTD គិតជាលានដុល្លា (LHS) និង YTD, Y/Y% change (RHS)




ប្រភព ៖ ក្រសួងទេសចរណ៍

## គ) វិស័យទេសចរណ៍

**៧. ដោយសារតែភាពវឹកវរផ្នែកនយោបាយក្នុងប្រទេសថៃនាពេលថ្មីៗនេះ និងភាពតានតឹងរវាងប្រទេសវៀតណាម និងប្រទេសចិន កំណើនភ្ញៀវទេសចរណ៍មានការធ្លាក់ចុះ ដោយមានកំណើនត្រឹមតែ ៥,២ ភាគរយ ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ២០១៤ បើធៀបនឹងឆ្នាំមុនដែលមានកំណើនចំនួន ១៩ ភាគរយ** (រូប ៥)។ មានបញ្ហាអវិជ្ជមានមួយចំនួនដែលប៉ះពាល់ដល់ភ្ញៀវទេសចរដែលធ្វើដំណើរតាមផ្លូវគោក ដែលមានចំនួនប្រមាណពាក់កណ្តាលនៃភ្ញៀវទេសចរសរុប។ ជាលទ្ធផល ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៤ ចំនួនភ្ញៀវទេសចរវៀតណាម (៩៧ ភាគរយធ្វើដំណើរតាមផ្លូវគោក)ដែលកើនបាន ៩ ភាគរយក្នុងឆ្នាំ ២០១៣មានចំនួននៅទ្រឹងខណៈពេលដែលភ្ញៀវទេសចរចិន (៩០ ភាគរយ ធ្វើដំណើរតាមផ្លូវអាកាស) ដែលកើនបាន ៥៥ ភាគរយក្នុងឆ្នាំ ២០១៣ មានកំណើនត្រឹម ១៩,១ ភាគរយ។ ជាធម្មតា ប្រទេសកម្ពុជាគ្រាន់តែជាផ្នែកមួយនៃការទស្សនាក្នុងតំបន់របស់ភ្ញៀវទេសចរប៉ុណ្ណោះ (ភ្ជាប់ទៅប្រទេសថៃ និង/ឬប្រទេសវៀតណាម)។ ដោយសារតែប្រទេសវៀតណាម និងប្រទេសថៃ បានក្លាយជាគោលដៅទេសចរណ៍មិនប្រាកដប្រជាប្រទេសកម្ពុជាក៏បានបាត់បង់ភាពទាក់ទាញដល់ភ្ញៀវទេសចរផងដែរ។

**៨. កំណើនភ្ញៀវទេសចរចិន និងកូរ៉េខាងត្បូង មកកម្ពុជា យឺតជាងមុនយ៉ាងខ្លាំង ខណៈពេលដែលកំណើនភ្ញៀវទេសចរជប៉ុននៅមាន និរន្តរភាព** (រូប ៦)។ ស្ថានភាពនេះហាក់បង្ហាញពីការវិវឌ្ឍថ្មីមួយដែលថាប្រទេសកម្ពុជា បានក្លាយជាប្រទេសកាន់តែទាក់ទាញចំពោះភ្ញៀវទេសចរ និង វិនិយោគិនជប៉ុន។

រូប ៦ **ចំនួនភ្ញៀវទេសចរជប៉ុនមានការកើនឡើងជាលំដាប់ខណៈដែលចំនួនភ្ញៀវទេសចរកូរ៉េ និងចិនមានការថយចុះយ៉ាងច្រើន** (Year on year, % change)




ប្រភព ៖ ក្រសួងទេសចរណ៍

## ឃ) វិស័យកសិកម្ម

**៩. កំណើនវិស័យកសិកម្មនៅតែបន្តការលូតលាស់ ប៉ុន្តែមានកម្រិតទាបជាងមុន ដោយសារតែការពង្រីកផ្ទៃដីដាំដុះ និងទិន្នផលស្រូវមានកំណើនយឺតក្នុងអំឡុងពីរឆ្នាំចុងក្រោយនេះ** (រូប ៧)។ នៅឆ្នាំ ២០១៣ ផលិតផលស្រូវមានកំណើនអវិជ្ជមាន សម្រាប់ស្រូវរដូវប្រាំង ដែលមាន

ចំនួនប្រហែល២៣ ភាគរយនៃផលិតផលស្រូវសរុប។ តម្លៃកសិផលដែលធ្លាក់ចុះ ជាពិសេស តម្លៃស្រូវដែលមិនមានតុល្យភាពទៅនឹងការបន្ថយផលិតកម្ម និងការចំណាយទៅលើការស្វែងរកទីផ្សារ បានប៉ះពាល់ដល់កំណើនវិស័យកសិកម្ម និងការនាំចេញស្រូវ។ ដំណាំកសិកម្មសំខាន់ៗផ្សេងទៀត ដូចជា កៅស៊ូ និងដំឡូងមីក៏ទទួលរងការប៉ះពាល់ដោយសារ ការធ្លាក់ចុះតម្លៃផលិតផលកសិកម្មផងដែរ។ តម្លៃអង្ករមិនត្រូវរំពឹងថានឹងកើនឡើងខ្លាំងនាពេលខាងមុខឆាប់ៗឡើយ ដោយសារតែការប្រែប្រួលតម្លៃ អន្តរជាតិសម្រាប់ទំនិញភាគច្រើន បានងាកទៅរកលំនាំពីពេលមុនហើយ។ សូមមើលប្រធានបទពិសេសទី១ ៖ ការទាញយកប្រយោជន៍ឱ្យបានច្រើនបំផុតពីវិស័យអង្ករនៅកម្ពុជា ដែលមានការលើកឡើងលម្អិតពីតម្លៃ ផលិតកម្ម ការកែច្នៃ និងការនាំចេញអង្ករ។

រូប ៧ ការពង្រីកផ្ទៃដីដាំស្រូវ ហើយទិន្នផលស្រូវ បានធ្លាក់ចុះក្នុងរយៈពេល




ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**១០. ជាការសំខាន់ដែលត្រូវរកឲ្យឃើញមូលហេតុដែលធ្វើឲ្យមានការធ្លាក់ចុះផលិតផលស្រូវប្រាំង។** កំណើនផលិតផលស្រូវប្រាំង ដែលបានឈានដល់ចំណុចកំពូលក្នុងឆ្នាំ ២០១១ បានបន្ថយល្បឿនចាប់ពីពេលនោះមក និងមានកម្រិតអវិជ្ជមានកាលពីឆ្នាំកន្លងទៅ (រូប ៨)។ ដោយសារបញ្ហានេះបានកើតឡើងទន្ទឹមនឹងការខំប្រឹងប្រែងជាបន្តបន្ទាប់ ក្នុងការកែលម្អប្រព័ន្ធធារាសាស្ត្រ និងសេវាផ្សព្វផ្សាយព័ត៌មានកសិកម្ម ដែលជាចំណុចអាទិភាពសំខាន់នៅក្នុងយុទ្ធសាស្ត្រចតុកោណជំហានទី ៣ ដែលមានរយៈពេល ៥ ឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដូច្នេះហើយ ចាំបាច់ត្រូវមានការវិភាគបន្ថែមដើម្បីកំណត់ឲ្យឃើញ ពីមូលហេតុផ្សេងៗនៃកំណើនយឺតនេះ។ ការសិក្សាមួយដែលធ្វើរួមគ្នាដោយធនាគារពិភពលោក ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ និង រាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ២០១១ បានផ្តល់អនុសាសន៍ឲ្យមានការបង្កើនមូលនិធិសម្រាប់ការស្រាវជ្រាវផ្នែកកសិកម្ម ការបង្កើនប្រសិទ្ធភាពនៃការវិនិយោគលើ ប្រព័ន្ធធារាសាស្ត្រដោយស្តារប្រឡាយបន្ទាប់បន្សំ និងផ្តល់ការវិនិយោគគ្រប់គ្រាន់សម្រាប់ការជួសជុលប្រព័ន្ធធារាសាស្ត្រ និងសេវាផ្សព្វផ្សាយព័ត៌មានកសិកម្ម[2]។ ទោះជាយ៉ាងណាក៏ដោយ ក៏មិនទាន់មានភាពច្បាស់នៅឡើយថា តើអនុសាសន៍នានាត្រូវបានយកមកអនុវត្តប្រកបដោយជោគជ័យ ឬយ៉ាងណានោះទេ។

រូប ៨ កំណើនផលិតកម្មស្រូវប្រាំងមានភាពអវិជ្ជមានកាលពីឆ្នាំកន្លងទៅ

(Y/Y, % change)




ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[2] ការចំណាយរបស់រដ្ឋាភិបាលកម្ពុជាប្រកបដោយប្រសិទ្ធភាពដើម្បីឲ្យមានកំណើនរឹងមាំ និងមានការចូលរួម ការវាយតម្លៃរួមទៅលើការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងការពិនិត្យទៅលើចំណាយសាធារណៈ ខែវិច្ឆិកា ឆ្នាំ២០១១ ធនាគារពិភពលោក។

ប្រអប់ ១

## ការអភិវឌ្ឍវិស័យទេសចរណ៍

ប្រទេសកម្ពុជាទើបតែចាប់ផ្តើមប្រើប្រាស់សក្តានុពលពេញលេញនៃវិស័យទេសចរណ៍របស់ខ្លួនចាប់ពីទសវត្សរ៍កន្លងមក។ ទោះបីជាកម្ពុជាសម្បូរទៅដោយទីតាំងដ៏គួរឲ្យទាក់ទាញជាច្រើនរាប់មិនអស់ រួមមាន ទីតាំងប្រវត្តិសាស្ត្រ វប្បធម៌ និងធម្មជាតិ ក៏ការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅកម្ពុជាទើបតែអនុវត្តប៉ុណ្ណោះ។ កាលពីឆ្នាំ១៩៩៣ សន្តិភាពថ្មីតាមរយៈការបោះឆ្នោតថ្នាក់ជាតិលើកដំបូងនៅកម្ពុជាបានជួយឲ្យប្រទេសកម្ពុជាទាក់ទាញភ្ញៀវទេសចរប្រមាណ ១០០.០០០ នាក់ (រូប ខ១.១) ដែលជាចំនួន ២ ភាគរយនៃភ្ញៀវទេសចរអន្តរជាតិសរុបរបស់ប្រទេសថៃ (រូបលេខ ខ១.២)។ ទោះជាយ៉ាងណា ចំនួនភ្ញៀវទេសចរក្នុងប្រទេសកម្ពុជា បានកើនឡើងយ៉ាងលឿនក្នុងអំឡុង ១០ ឆ្នាំកន្លងមក មានចំនួនរហូតដល់ ១៥ ភាគរយនៃភ្ញៀវទេសចរសរុបរបស់ប្រទេសថៃគិតត្រឹមឆ្នាំ២០១៣។ មានការប៉ាន់ប្រមាណថាវិស័យទេសចរណ៍បានបង្កើតការងារដោយផ្ទាល់ចំនួន ៣០០.០០០ និងការងារដោយប្រយោលផ្សេងទៀតចំនួន ៧០០.០០០។ ហេតុដូច្នេះ ការងារសរុបដោយផ្ទាល់ និងប្រយោលរបស់វិស័យ នេះមានចំនួន ១៥ ភាគរយនៃការងារសរុបក្នុងប្រទេសកម្ពុជា ឬជាងពាក់កណ្តាលនៃការងារសរុបក្នុងវិស័យសេវាកម្ម។ កំណើនភ្ញៀវទេសចររបស់ប្រទេសកម្ពុជា មានលក្ខណៈដូចនឹងកំណើនភ្ញៀវទេសចរប្រទេសថៃកាលពីទសវត្សរ៍កន្លងទៅ ទោះបីជាវាបានឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជានៃភ្ញៀវទេសចរអន្តរជាតិក្នុងអំឡុងពេលបោះឆ្នោតក៏ដោយ (រូបលេខ ខ ១.៣)។ ខុសពីប្រទេសថៃដែលភ្ញៀវទេសចរ ៨០ ភាគរយចូលចិត្តតំបន់ទេសចរណ៍ ធម្មជាតិ និងមាត់សមុទ្រដែលមានឆ្នេរខ្សាច់ និងពន្លឺព្រះអាទិត្យ និងរមណីយដ្ឋានធម្មជាតិ តំបន់ទេសចរណ៍ដ៏គួរឲ្យទាក់ទាញបំផុតនៅកម្ពុជា គឺប្រាសាទបុរាណអង្គរវត្តដែលត្រូវបានសាងសង់ក្នុងសតវត្សរ៍ទី ១២ ដែលបានបន្សល់ទុកពីទីក្រុងផ្សេងៗនៃអាណាចក្រខ្មែរចាប់ពីសតវត្សរ៍ទី ៩ ដល់សតវត្សរ៍ទី ១៥។ ភ្ញៀវទេសចរដែលធ្វើដំណើរតាមផ្លូវអាកាសមានចំនួន ៥០ ភាគរយនៃភ្ញៀវទេសចរសរុបដែលចូលមកទស្សនាប្រទេសកម្ពុជា។ ភ្ញៀវទេសចរដែលមកពីប្រទេសវៀតណាម មានចំនួនច្រើនជាងគេបង្អស់ (២០,៣ ភាគរយក្នុងឆ្នាំ២០១៣) (បន្ទាប់មក គឺភ្ញៀវទេសចរមកពីប្រទេសចិន និងកូរ៉េខាងត្បូង) ហើយភ្ញៀវទេសចរវៀតណាមស្ទើរតែទាំងអស់ (៩៧ ភាគរយ) ចូលមកទស្សនាប្រទេសកម្ពុជាតាមផ្លូវគោក។ ចំណុចនេះបញ្ជាក់ពីសារៈសំខាន់នៃការសាងសង់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធដែលភ្ជាប់ព្រំប្រទល់កម្ពុជា និងវៀតណាមទៅកាន់តំបន់ទាក់ទាញភ្ញៀវទេសចរ ដូចជា ប្រាសាទអង្គរវត្តជា ដើម។ ទោះជាយ៉ាងណា សម្រាប់ប្រទេសថៃ ភ្ញៀវទេសចរតាមផ្លូវអាកាសមានប្រមាណ ៦៥ ភាគរយ ហើយភ្ញៀវទេសចរដែលមកពីប្រទេសចិន (បន្ទាប់មក គឺភ្ញៀវទេសចរមកពីប្រទេសម៉ាឡេស៊ី និងរុស្ស៊ី) មានច្រើនបំផុត (១៧,៣ ភាគរយ ក្នុងឆ្នាំ២០១៣)។

ទឹកប្រាក់សរុបដែលទទួលបានពីភ្ញៀវទេសចរដែលចូលមកទស្សនាប្រទេសកម្ពុជា (ការរួមចំណែកដោយផ្ទាល់) ត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ២,៥ ពាន់លានដុល្លាអាមេរិក (ឬ ១៦ ភាគរយនៃផលិតផលក្នុងស្រុកសរុប) ក្នុងឆ្នាំ២០១៣ ឬ ៦០៥ ដុល្លាសម្រាប់ភ្ញៀវទេសចរម្នាក់ៗ ខណៈដែលទឹកប្រាក់សរុបដែលទទួលបានពីភ្ញៀវទេសចរដែលចូលមកទស្សនាប្រទេសថៃមានចំនួន ៣៩,២ ពាន់លានដុល្លា (ឬ១០ ភាគរយនៃផលិតផលក្នុងស្រុកសរុប) ឬ ១.៤៧៩ ដុល្លាសម្រាប់ភ្ញៀវទេសចរម្នាក់ៗ។ ភ្ញៀវទេសចរដែលចូលមកទស្សនាប្រទេសកម្ពុជា ស្នាក់នៅជាមធ្យម រយៈពេលត្រឹមតែ ៦,៧ ថ្ងៃប៉ុណ្ណោះ និងចំណាយអស់ ១២០ ដុល្លាក្នុងមួយថ្ងៃ ខណៈពេលដែលភ្ញៀវទេសចរដែលចូលមកទស្សនាប្រទេសថៃ ស្នាក់នៅជាមធ្យមរយៈពេល ៩,៨ ថ្ងៃ និងចំណាយអស់ ១៥០ ដុល្លាក្នុងមួយថ្ងៃ។ ភ្ញៀវទេសចរដែលត្រឡប់មកទស្សនាម្តងទៀតនៅកម្ពុជា មានត្រឹមតែ ១៦ ភាគរយប៉ុណ្ណោះសម្រាប់ប្រទេសកម្ពុជា ខណៈពេលដែលប្រទេសថៃមាន ៥០ ភាគរយ (តារាង ខ.១)។ មូលហេតុចម្បងដែលធ្វើឲ្យភ្ញៀវទេសចរអន្តរជាតិ ត្រឡប់ទៅទស្សនានៅប្រទេសថៃម្តងទៀត រួមមាន (១) ភាពទាក់ទាញនៃតំបន់ទេសចរណ៍ រួមទាំងឱកាសសម្រាប់ធ្វើដំណើរផ្សងព្រេង កន្លែងកំសាន្តសប្បាយ ប្រជាជនមានភាពរស់រាយរាក់ទាក់ សុវត្ថិភាព និងភាពទាក់ទាញ និង (២) អាហារមានរសជាតិឆ្ងាញ់ និងច្រើនប្រភេទ អាហារចម្រុះវប្បធម៌ គ្រឿងផ្សំក្នុងស្រុក អាហារផ្តល់ជីជាតិ អាហារប្លែកមុខ និងមានអនាម័យ។

ដើម្បីបន្តការអភិវឌ្ឍវិស័យទេសចរណ៍ មានចំណុចជាច្រើនដែលត្រូវកែលម្អ ដើម្បីបង្កើនការរួមចំណែកឱ្យមានកំណើន ភាពរីកចម្រើនរួម និងការកាត់បន្ថយភាពក្រីក្រ ហើយវិស័យសាធារណៈមានមុខងារយ៉ាងសំខាន់ក្នុងការអនុវត្ត ឬជួយសម្របសម្រួលការអភិវឌ្ឍន៍នេះ។ បទពិសោធន៍របស់ប្រទេសកូស្តារីកា បង្ហាញថា ការធ្វើពិពិធកម្មទីតាំងអ្នកទេសចរ ដើម្បីទាញយកអត្ថប្រយោជន៍ពីសក្តានុពលដ៏សម្បើមនៃតំបន់ឆ្នេរ ក៏ដូចជាសក្តានុពលសម្រាប់វិស័យអេកូទេសចរណ៍នៅតំបន់ជនបទ នឹងជួយពង្រីកវិស័យទេសចរណ៍ និងចែករំលែកផលប្រយោជន៍ដែលមាននៅទូទាំងប្រទេស តាមរយៈការបង្កើនការងារសម្រាប់សហគមន៍ក្នុងមូលដ្ឋាន និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ។

## ប្រអប់ ១ ការអភិវឌ្ឍន៍វិស័យទេសចរណ៍ (បន្ត)

ការអនុវត្តប្រកបដោយជោគជ័យនូវសកម្មភាព និងគោលដៅសំខាន់ៗ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ ឆ្នាំ ២០១២-២០២០ របស់ប្រទេសកម្ពុជា នឹងផ្តល់នូវមូលដ្ឋានដ៏សមស្របមួយ បើទោះបីជាកិច្ចការជាច្រើនទៀតអាចធ្វើទៅបាន ដើម្បីធានាឱ្យបាននូវផលវិជ្ជមានច្រើនបំផុត។ បើទោះបីជាគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍សម្រាប់ការផ្សារភ្ជាប់ និងការសម្របសម្រួលការធ្វើដំណើរតាមអាកាស នឹងអាចជួយបង្កើនចំនួនមកដល់នៃអ្នកទេសចរ ប៉ុន្តែកត្តាជាវិជ្ជមានច្រើនជាងនេះ អាចទទួលបានតាមរយៈការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងពេលតែមួយ ជាពិសេសផ្លូវអ៊ុតកៅស៊ូ និងផ្លូវជនបទ ដែលទទួលបានការផ្តល់ហិរញ្ញប្បទានពីវិស័យសាធារណៈ ដោយសារចំនួនពាក់កណ្តាលនៃអ្នកទេសចរមកដល់សរុប គឺធ្វើដំណើរតាមផ្លូវគោក។ ការសម្របសម្រួលការអភិវឌ្ឍន៍សេវាគាំទ្រផ្នែកបដិសណ្ឋារកិច្ច និងផ្នែកភស្តុភារ ដែលទទួលការផ្តល់ហិរញ្ញប្បទានពីវិស័យឯកជន ក៏អាចក្លាយជាចំណុចគន្លឹះក្នុងការគាំទ្រការធ្វើពិពិធកម្ម និងការពង្រីកវិស័យទេសចរណ៍បានផងដែរ។ ហេតុដូច្នេះ វាមានសារៈសំខាន់ក្នុងការកំណត់ឱ្យបានច្បាស់លាស់អំពីតួនាទីរបស់វិស័យសាធារណៈ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងសហគមន៍មូលដ្ឋាន ព្រមទាំងបង្កើតឱ្យមានការរៀបចំការសម្របសម្រួលមុខងារដ៏ល្អប្រសើរមួយ ដើម្បីផ្តល់អាទិភាព អនុវត្ត និងតាមដានសកម្មភាព និងគោលដៅសំខាន់ៗ។ ឧទាហរណ៍ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីស្តារ និងពង្រីកផ្លូវហាយវេមួយចំនួន ដែលភ្ជាប់ពីប្រទេសកម្ពុជា ទៅកាន់ប្រទេសថៃ និងប្រទេសវៀតណាម ប៉ុន្តែ ប្រសិនបើពុំមានការសម្របសម្រួលឱ្យបានគ្រប់គ្រាន់ និងផ្តល់អាទិភាពលើការប្រមូលធនធាន ការថែទាំផ្លូវហាយវេ ដែលបានកសាង និងពង្រីក រួមទាំងព័ត៌មានពីអ្នកទេសចរណ៍ កន្លែងឈប់សម្រាក និងបង្គន់អនាម័យក្នុងកម្រិតមួយសមស្រប នឹងនៅតែជាបញ្ហាប្រឈមមួយ។ ដូចគ្នាដែរ អាជ្ញាធរថ្នាក់កណ្តាល និងថ្នាក់ខេត្ត បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការពង្រឹងសុវត្ថិភាព សន្តិសុខ និងបរិយាកាស ដើម្បីទាក់ទាញអ្នកទេសចរ ប៉ុន្តែប្រសិនបើគ្មានការចូលរួមយ៉ាងសកម្មពីសហគមន៍មូលដ្ឋានទេ កិច្ចខិតខំប្រឹងប្រែងទាំងនោះ អាចពុំមានប្រសិទ្ធភាព។ ការសម្របសម្រួលនៅថ្នាក់តំបន់ ក៏អាចជួយបង្កើនភាពទាក់ទាញនៃកញ្ចប់ទេសចរណ៍ចម្រុះបានផងដែរ។ ឧទាហរណ៍ ការរួមបញ្ចូលគ្នានូវកញ្ចប់អេកូទេសចរណ៍ ទេសចរណ៍វប្បធម៌ និងទេសចរណ៍ឆ្នេរសមុទ្រជាមួយបណ្តាប្រទេសជិតខាង អាចទាក់ទាញអ្នកទេសចរដែលមកលេងក្នុងតំបន់ ឱ្យចូលមកប្រទេសកម្ពុជាបានផងដែរ។ ដូចមានបង្ហាញក្នុងរូប ខ១.២ ភាពពឹងផ្អែកនៃ វិស័យទេសចរណ៍ទើបនឹងកើតថ្មីរបស់ប្រទេសកម្ពុជា ធៀបនឹងវិស័យទេសចរណ៍របស់ប្រទេសថៃដែលមានការអភិវឌ្ឍខ្លាំងជាងនេះ បង្ហាញអំពីសារៈសំខាន់នៃការសហការយ៉ាងជិតស្និទ្ធរវាងក្រសួង ភ្នាក់ងារ និងវិស័យឯកជននៃប្រទេសទាំងពីរ។

រូប ខ១.១ **ភ្ញៀវទេសចរមានការកើនឡើង**
(គិតជាលាននាក់នៃភ្ញៀវទេសចរ)




រូប ខ១.២ **មានលំនាំតាម (បង្ហាញពីការពឹងផ្អែក) និន្នាការ និងការប្រែប្រួលតាមរដូវនៃភ្ញៀវទេសចរប្រទេសថៃ** (ចំនួនភ្ញៀវគិតជាលាននាក់)



ប្រអប់ ១

# ការអភិវឌ្ឍន៍វិស័យទេសចរណ៍ (ត)

រូប ខ១.៣

ការកើនឡើងគិតជាចំណែកនៃភ្ញៀវទេសចរអន្តរជាតិថៃ




តារាង ខ១.១

ចំណុចសំខាន់ៗនៃវិស័យទេសចរណ៍

| | កម្ពុជា | ថៃ |
|---|---|---|
| **ចំនួនភ្ញៀវសរុប (២០០៣ គិតជាលាននាក់)** | **4.2** | **26.5** |
| តាមផ្លូវអាកាស(ភាគរយនៃចំនួនសរុប) | 50.0 | 65.0 |
| **ចំនួនភ្ញៀវទេសចរណ៍ដែលបានប៉ាន់ស្មាន/ការរួមចំណែកផ្ទាល់ (២០១៣ ជាលានដុល្លា)** | **2,547.0** | **39,282.3** |
| ជាភាគរយនៃ ផសស | 16.0 | 10.0 |
| ភ្ញៀវម្នាក់ | 13,579.3 | 19.5 |
| ក្នុងមួយថ្ងៃ | 120.7 | 150.2 |
| **ការរួមចំណែកប្រយោលនៃវិស័យទេសចរណ៍ដែលបានប៉ាន់ស្មាន (២០១២ ជាលានដុល្លា)** | **3,600.0** | **61,000.0** |
| ជាភាគរយនៃ ផសស | 25.4 | 16.7 |
| **រយៈពេលស្នាក់នៅ(ថ្ងៃ)** | **6.7** | **9.8** |
| **ភ្ញៀវត្រឡប់មកវិញ (ភាគរយនៃចំនួនសរុប)** | **16.0** | **50.0** |
| **ការងារ (គិតជាពាន់)** | **1,083.4** | **6,838.6** |
| ផ្ទាល់ | 320.1 | 2,019.9 |
| ប្រយោល | 763.3 | 4,818.7 |

ប្រភព៖ ក្រសួងទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ និងកីឡាប្រទេសថៃ (ឥទ្ធិពលលើសេដ្ឋកិច្ចនៃការធ្វើដំណើរ និងទេសចរពីប្រទេសថៃឆ្នាំ ២០១៣ និងការប៉ាន់ស្មានរបស់ធនាគារពិភពលោក)

ប្រអប់២

# ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនខ្ពស់

**ប្រទេសកម្ពុជា មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ ៧,៧ ភាគរយក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅ ដោយបច្ចុប្បន្ននេះ កម្ពុជា បានក្លាយជាប្រទេសដែលមានកំណើនលឿនបំផុតទី ៦ ក្នុងពិភពលោក។** ដំណើរការសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានភាពល្អប្រសើរខ្លាំង ដោយសារតែក្នុងពិភពលោកនេះ មានប្រទេសតែមួយចំនួនតូចប៉ុណ្ណោះដែលមានអត្រាកំណើនខ្ពស់ប្រកបដោយនិរន្តរភាពក្នុងរយៈពេលច្រើនទសវត្សរ៍បែបនេះ។ ជាទូទៅ ប្រទេសនានាក្នុងពិភពលោកបានឆ្លងកាត់ដំណាក់កាលផ្សេងៗ រួមមាន កំណើន ភាពនៅទ្រឹង ឬការធ្លាក់ចុះក្នុងរយៈពេលផ្សេងគ្នា[1]។ តាមការកត់សម្គាល់របស់គណៈកម្មការកំណើន (ឆ្នាំ ២០០៨) ចាប់តាំងពីឆ្នាំ១៩៥០ មក មានប្រទេសតែ ១៣ ប៉ុណ្ណោះក្នុងពិភពលោក ដែលមានកំណើនសេដ្ឋកិច្ចជាមធ្យមខ្ពស់ជាង ៧ ភាគរយក្នុងមួយឆ្នាំ ក្នុងរយៈពេល ២៥ ឆ្នាំ ឬយូរជាងនេះកន្លងមក។ តាមរយៈល្បឿននៃទំហំកំណើននេះវិស័យសេដ្ឋកិច្ចមានការរីកចម្រើនស្ទើរតែទ្វេដងនៅក្នុងមួយទសវត្សរ៍[2]។

**កំណើនដ៏ខ្ពស់របស់ប្រទេសកម្ពុជា ត្រូវបានកត់សំគាល់ពិសេសដោយភាពរឹងមាំ។** ក្រៅពីអត្រាកំណើនមធ្យមដ៏លឿន កម្ពុជាបានរក្សាកំណើនខ្ពស់ថេរជាប់ក្នុងរយៈកាលខាងលើនេះ។ កត្តានេះបានធ្វើឲ្យប្រទេសកម្ពុជាមានលក្ខណៈខុសពីប្រទេស Equatorial Guinea, Liberia, Angola និង Cape Verde ដែលជាប្រទេសដែលមានកំណើនខ្ពស់បំផុតទាំង ៥ ក្នុងរយៈពេល ២០ ឆ្នាំ ប៉ុន្តែ មិនទាន់មានកំណើនមួយដែលមានលក្ខណៈថេររហូតនោះឡើយ ប៉ុន្តែ ត្រូវដាក់បញ្ចូលទៅក្នុងក្រុមដូចគ្នា ដូចជា ប្រទេស ចិន ដែលស្ថិតនៅក្នុងចំណោមប្រទេសដែលមានកំណើនខ្ពស់បំផុតទាំង ៥ និងធ្លាប់បានជួបប្រទះកំណើនថេរ។

**ប្រអប់នេះ វាស់វែងអំពីកំណើនភាពរឹងមាំរបស់ក្រុមប្រទេសដែលមានកំណើនលឿន និងចាត់ថ្នាក់ប្រទេសទាំងនោះជា "ប្រទេសដែលមានកំណើនខ្ពស់"។** ក្រុមប្រទេសដែលមានកំណើនរឹងមាំ ត្រូវបានចាត់ទុកជាប្រទេស ដែលមានអត្រាកំណើនរយៈពេលមធ្យម ដែលត្រូវបានចាត់ថ្នាក់ក្នុងចំណោមប្រទេសដែលមានកំណើនលឿនបំផុតជារៀងរាល់ឆ្នាំក្នុងរយៈពេលពីរទសវត្សរ៍។ ក្នុងលំដាប់ប្រទេសកំពូលទាំង ៤០ (បញ្ចភាគកំពូលនៃសំណាកគំរូ) ត្រូវបានកំណត់ថាជាប្រទេសដែលមានកំណើនលឿន។ អត្រាកំណើន ផសសរយៈពេលមធ្យមប្រចាំឆ្នាំ (ហៅថា និន្នាការកំណើន) ត្រូវបានប៉ាន់ប្រមាណថាបានគណនាពីអត្រាកំណើនប្រចាំឆ្នាំ លើទិន្នន័យ ផសស ជាមធ្យមដែលផ្លាស់ប្តូរក្នុងរយៈពេលប្រាំឆ្នាំ។ មធ្យមភាគនៃការផ្លាស់ប្តូរ ត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការឡើងចុះនៃ ផសសក្នុងរយៈពេលខ្លី និងបង្ហាញពីនិន្នាការក្នុងរយៈពេលមធ្យម។ ផសសត្រូវបានវាស់វែងថាស្ថិតក្នុងកម្រិតថេរ ២០០៥ ដុល្លាអាមេរិក សម្រាប់ ១៦០ ប្រទេស ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០១៣។ ភាពទាក់ទាញនៃការកំណត់និយមន័យកំណើនដែលមានថាមពលនោះ ដោយសារថាវិធីសាស្ត្រនេះផ្តោតទៅលើកំណើនរបស់ប្រទេសមួយធៀបនឹងប្រទេសដទៃ និងគិតគូរពីដំណាក់កាលមានវិបត្តិ ដែលនៅពេលនោះ បណ្តាប្រទេសនានាមានកំណើនទាប។ តាមការប្រៀបធៀប អ្នករត់លឿនរឹងមាំគឺជាអ្នកដែលរត់បានលឿនជាងអ្នកផ្សេងទៀតទោះបីជាមានអ្វីកើតឡើងក៏ដោយ។ តាមទស្សនវិស័យនៃការអភិវឌ្ឍន៍ កំណើនលឿនរឹងមាំក្នុងអំឡុងពេលយូរ មានលក្ខណៈល្អប្រសើរជាងកំណើនខ្ពស់ក្នុងខណៈពេលខ្លីៗ។ មូលហេតុសំខាន់ពីរនៃចំណុចនេះគឺ កំណើនរឹងមាំផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ស្ថាប័នដើម្បីសម្របទៅតាមការផ្លាស់ប្តូរ ដូចជា ធនធានដែលត្រូវប្រើប្រាស់ និងការផ្លាស់ប្តូរបច្ចេកវិជ្ជា ដែលត្រូវគ្រប់គ្រងបានល្អជាងមុន (**គណៈកម្មាធិការកំណើន ឆ្នាំ២០០៨**) និងកំណើនរយៈពេលខ្លីៗ ទំនងជាពុំសូវអាចកាត់បន្ថយភាពក្រីក្របានច្រើន ដោយសារតែប្រជាជនក្រីក្រ ងាយរងគ្រោះនឹងកំណើនជាងប្រជាជនដែលមិនក្រីក្រ ដោយហេតុថា ប្រជាជនទាំងនោះ មានភាពទប់ទល់ និងការប៉ះពាល់ខ្សោយជាងមុន (ការសន្សំ និងទ្រព្យសកម្ម)។

**ដោយសារតែកំណើនភាពរឹងមាំខ្ពស់របស់ខ្លួនក្នុងរយៈពេល ២ទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានក្លាយជាផ្នែកមួយនៃក្រុមប្រទេសដែលបានជ្រើសរើសជា "ប្រទេសដែលមានកំណើនលឿន"។** ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសទាំងប្រាំបី និងអមដោយប្រទេសក្នុងតំបន់ ដូចជា ប្រទេស ចិន សាធារណរដ្ឋប្រជាមានិតឡាវ និងប្រទេសវៀតណាម (រូប ខ ២.១)។

រូប ខ២.១

និន្នាការកំណើនផលិតផលក្នុងស្រុកសរុបរបស់ប្រទេសដែលបានជ្រើសរើស




កំណត់សម្គាល់ ៖ និន្នាការកំណើន (ឬហៅថា អត្រាកំណើនប្រចាំឆ្នាំនៃផលិតផលក្នុងស្រុកសរុប"រយៈពេលមធ្យម") ត្រូវបានប៉ាន់ស្មានតាមរយៈការគណនាអត្រាកំណើនប្រចាំឆ្នាំផ្អែកតាមទិន្នន័យផលិតផលក្នុងស្រុកសរុបមធ្យមភាគរយៈពេល ៥ ឆ្នាំ។មធ្យមភាគត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាឡើងចុះនៃផលិតផលក្នុងស្រុកសរុបរយៈពេលខ្លី និងបង្ហាញពីកំណើនរយៈពេលមធ្យម។ ផលិតផលក្នុងស្រុកសរុបត្រូវបានវាស់វែងធៀបនឹងអត្រាថេរនៃប្រាក់ដុល្លាក្នុងឆ្នាំ ២០០៥។

ប្រភព ៖ សូចនាករអភិវឌ្ឍន៍សកល

[1]គណៈកម្មការកំណើន និងការអភិវឌ្ឍ (ឆ្នាំ2008) *របាយការណ៍ស្តីពីកំណើន ៖ យុទ្ធសាស្ត្រសម្រាប់និរន្តរភាពកំណើន និងការអភិវឌ្ឍដែលមានការរួមបញ្ចូល* Washington, D.C. ៖ធនាគារពិភពលោក។

[2]Hausmann, Pritchett, and Rodrik (2005). "ល្បឿននៃកំណើន", *និន្នានុប្បវត្តិស្តីពីកំណើនសេដ្ឋកិច្ច*Springer, លេខ 10(4),ទំព័រ 303-329។

## ប្រអប់២ ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនខ្ពស់ (បន្ត)

**កំណើនរបស់កម្ពុជាត្រូវបានជំរុញដោយម៉ាស៊ីនកំណើនទាំង ៤ ដែលរួមមាន ការនាំចេញសម្លៀកបំពាក់ វិស័យទេសចរណ៍ ដំណាំ និងសំណង់/អចលនទ្រព្យ។** កំណើនត្រូវបានជំរុញតាមរយៈកំណើនកត្តាបន្ថែមលើៗគ្នា និងកំណើនផលិតភាព ដោយសារតែការពង្រីកពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគប្រកបដោយនិរន្តរភាព។ ការញែកទៅលើផ្នែកផ្សេងៗនៃកំណើនបង្ហាញថា ជាមធ្យម កំណើនកត្តាបន្ថែមលើៗគ្នា រួមចំណែកប្រហែល ៤ ភាគរយ ដល់កំណើនផលិតផលក្នុងស្រុកសរុប[៣] ដែលមានកំណើនមូលធននិងកំណើនកម្លាំងពលកម្មនីមួយៗរួមចំណែក២ភាគរយស្មើៗគ្នា ក្នុងអំឡុងឆ្នាំ ១៩៨៧-២០១១។ ជាមធ្យម កំណើនផលិតភាពរួមចំណែកប្រហែល ៣ ភាគរយ ដល់កំណើនផលិតផលក្នុងស្រុកសរុប និងជាប្រភពកំណើនថេរសម្រាប់ប្រទេសកម្ពុជា[៤]។

**ភាពសកម្មរស់រវើករបស់ប្រទេសកម្ពុជាបានបន្ថយល្បឿនចាប់តាំងពីវិបត្តិហិរញ្ញវត្ថុពិភពលោក ដែលបានចោទជាសំណួរចំពោះនិរន្តរភាពនៃវិថីកំណើនខ្ពស់របស់ប្រទេស។** កំណើនរយៈពេលមធ្យមរបស់ប្រទេសកម្ពុជា ដែលត្រូវបានចាត់ថ្នាក់ជាបន្តបន្ទាប់ក្នុងចំណោមប្រទេសដែលមានកំណើនលឿនបំផុតទាំង ១០ មុនពេលមានវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ ២០០៨/២០០៩ បានធ្លាក់ចូលទៅក្នុងប្រទេសកំពូលទាំង ២០ បន្ទាប់ពីវិបត្តិ ដោយសារល្បឿនកំណើនមានសភាពយឺតជាងមុន ក្រោម ៨ ភាគរយ ដែលកម្ពុជាសម្រេចបានកន្លងមក (តារាង ខ២.១)។ ករណីនេះមានភាពផ្ទុយគ្នាទៅនឹងប្រទេសជិតខាង ដូចជា ប្រទេសឡាវ ដែលមានកំណើនរយៈពេលមធ្យម និងជាប់ចំណាត់ថ្នាក់កំពូលក្នុងចំណោមប្រទេសទាំង ១០ ដោយមានកំណើនការវិនិយោគ ដែលខុសពីប្រទេសកម្ពុជា ដែលមានកំណើនការវិនិយោគយឺតជាងមុន (រូប ខ២.២)។

### តារាង ខ២.១ អត្រាកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា និន្នាការកំណើន និងចំណាត់ថ្នាក់ក្នុងសកលលោក

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កំណើន ផសស ប្រចាំឆ្នាំរបស់កម្ពុជា | 6.4% | 5.4% | 5.6% | 5.0% | 11.9% | 8.8% | 8.0% | 6.7% | 8.5% | 10.3% | 13.3% | 10.8% | 10.2% | 6.7% | 0.1% | 6.0% | 7.1% | 7.3% |
| និន្នាការកំណើនរបស់ កម្ពុជា | 6.6% | 6.2% | 7.0% | 7.5% | 8.0% | 8.0% | 8.6% | 8.5% | 9.6% | 10.1% | 10.7% | 10.0% | 7.6% | 6.4% | 5.9% | 5.5% | 5.7% | 6.8% |
| ចំណាត់ថ្នាក់កំណើននិន្នាការកម្ពុជាក្នុងចំណោមប្រទេសក្នុងពិភពលោក | 27 | 17 | 12 | 7 | 9 | 10 | 7 | 10 | 10 | 8 | 8 | 9 | 14 | 26 | 34 | 36 | 29 | 20 |

ប្រភព ៖ ការគណនារបស់បុគ្គលិកធនាគារពិភពលោក ដោយប្រើប្រាស់ទិន្នន័យសូចនាករអភិវឌ្ឍន៍សកល

### រូប ខ២.២ ព័ត៌មានស្តីពីមូលធនសរុបដែលចំណែកមួយនៃផលិតផលក្នុងស្រុកសរុបនៅកម្ពុជា ដែលបានធ្លាក់ចុះ បន្ទាប់ពីមានវិបត្តិឆ្នាំ២០០៩ ខណៈពេលដែលចំណណែកនោះកើនឡើងនៅប្រទេសឡាវ




ប្រភព ៖ សូចនាករអភិវឌ្ឍន៍សកល

[៣] កំណើនផលិតផលក្នុងស្រុកសរុប ត្រូវបានប៉ាន់ស្មានថាជាទិន្នផលគំរូ ដោយសារតែ Cobb-Douglas បានបែងចែកមុខងារផលិតកម្មជាបី គឺដើមទុនរូបវន្ត ធាតុចូលកម្លាំងពលកម្ម និងលក្ខខណ្ឌផលិតភាពមិនលម្អៀង Hicks។

[៤] ផ្អែកតាមការពិនិត្យទៅលើផ្នែកផ្សេងៗនៃកំណើនរបស់ PhurichaiRungcharoenkitkul (ឆ្នាំ២០១២) "ការបង្កើតគំរូដោយប្រើទិន្នន័យតិចតួច៖ ការប៉ាន់ប្រមាណសន្ទុះកំណើននៅកម្ពុជា" IMF Working Paper WP/12/96, www.imf.org/external/pubs/ft/wp/2012/wp1296.pdf.

**ប្រទេសកម្ពុជា មានគោលបំណងកែប្រែសេដ្ឋកិច្ចឆ្ពោះទៅរកកំណើនផលិតផលក្នុងស្រុកសរុប ៨ ភាគរយនៅទសវត្សរ៍ក្រោយ។** អ្នកខ្លះហៅល្បឿនកំណើននេះថាជា "កំណើនអច្ឆរិយៈ" ប៉ុន្តែ គណៈកម្មការកំណើន (ឆ្នាំ២០០៨) បានលើកឡើងថា កំណើនលឿនប្រកបដោយនិរន្តរភាព មិនគួរត្រូវបានចាត់ទុកជាកំណើនអច្ឆរិយៈនោះទេ។ ប្រទេសដែលអាចសម្រេចបានកំណើនបែបនេះ ត្រូវមានកត្តាអំណោយផល និងប្រើប្រាស់គោលនយោបាយផ្សេងៗបានត្រឹមត្រូវ ដើម្បីចាប់យកឱកាស និងជម្នះរាល់បញ្ហាប្រឈមផ្សេងៗ។ កំណើនកត្តាប្រមូលផ្តុំ (ជាពិសេសដើមទុន និងកម្លាំងពលកម្មជំនាញ) និងកត្តាផលិតកម្ម គឺជាគន្លឹះដ៏សំខាន់សម្រាប់កំណើនច្រើនជាងនេះ។ ការអនុវត្តរបៀបវារៈកំណែទម្រង់ការអភិវឌ្ឍន៍ដែលបានកែលម្អជាថ្មីរបស់ប្រទេសកម្ពុជា ជាពិសេសលើបរិយាកាសធុរៈកិច្ច អាចជួយបង្កើនអនុបាតមូលធនធៀបនឹងផលិតផលក្នុងស្រុកសរុបត្រឹមប្រមាណ ៥ ភាគរយបន្ថែមដែលចាំបាច់សម្រាប់ជួយសម្រេចបានអត្រាកំណើនផលិតផលក្នុងស្រុក ៨ ភាគរយ (សូមមើលអនុសាសន៍ស្តីពីប្រធានបទពិសេសស្តីពីបរិយាកាសធុរៈកិច្ចក្នុងបញ្ហាដែលបានជ្រើសរើសចំនួន ២ ការបង្កើតឱកាសសម្រាប់ក្រុមហ៊ុន លទ្ធផលរកឃើញដែលទទួលបានពីបរិយាកាសវិនិយោគ)។

## ២. វិស័យទូទាត់ក្រៅប្រទេស

**១១. ការបន្តកំណើនសេដ្ឋកិច្ចដ៏ល្អប្រសើរក្នុងឆ្នាំនេះ ត្រូវបានគាំទ្រដោយដំណើរការវិស័យទូទាត់ក្រៅប្រទេស ដែលមានស្ថិរភាព នៅខណៈដែលមានកំណើនលំហូរការវិនិយោគផ្ទាល់ពីបរទេស ដែលជួយផ្តល់ហិរញ្ញប្បទានបានយ៉ាងច្រើនដល់កំណើនឱនភាពគណនីចរន្ត ដែលរួមចំណែកដល់កំណើនទុនបម្រុងអន្តរជាតិ។** ឱនភាពគណនីចរន្ត (មិនគិតការបង្វែរផ្ទេរការ) ដែលនៅតែមានចំនួនច្រើនគ្រាន់បើ ត្រូវបានព្យាករណ៍ថានឹងកើនដល់ ១១,៣ ភាគរយនៃផលិតផលក្នុងស្រុកសរុប ដោយសារកំណើនការនាំចូល និងការទទួលបានចំណូលពីសេវាកម្ម (ការធ្វើដំណើរ) ដែលយឺតជាងមុន ដែលមានលើសលប់ជាងកំណើននាំចេញ។ បើទោះ បីជាឱនភាពគណនីចរន្តឆ្នាំនេះ មានកម្រិតខ្ពស់បន្តិចបន្តួចជាងឱនភាពគណនីចរន្តដែលបានប៉ាន់ស្មាន ក្នុងឆ្នាំ២០១៣ ថាមានចំនួន ១០,៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប ប៉ុន្តែឱនភាពគណនីចរន្តនេះ បន្តទទួលបានហិរញ្ញប្បទានយ៉ាងច្រើន ពីការវិនិយោគផ្ទាល់ពីបរទេស (រូប ៩ និង ១០) ដែលត្រូវបានចាត់ទុកថាមិនសូវមានការប្រែប្រួលច្រើន ដូចលំហូរដើមទុន ផ្សេងទៀត ដូចជា ផលប័ត្រ និងលំហូររយៈពេលខ្លី។ លំហូរវិនិយោគផ្ទាល់ពីបរទេស មានការកើនឡើងដោយសារស្ថិរភាពទីផ្សារការងារកាន់តែល្អ ហើយវិនិយោគិនចាប់អារម្មណ៍សាជាថ្មីលើវិស័យសំណង់ និងអចលនទ្រព្យដែលកត្តានេះ បានធ្វើឲ្យមានកំណើនការនាំចូលសម្ភារសំណង់។ ការនាំចូលទំនិញប្រើប្រាស់ក៏មានការកើនឡើងផងដែរ ដូចជាការនាំចូលយានជំនិះ និងផលិតផលឥន្ធនៈ។ កំណើនការវិនិយោគផ្ទាល់ពីបរទេសរួមចំណែកដល់កំណើនទុនបម្រុងអន្តរជាតិដុល (GIR)។ ទុនបម្រុងអន្តរជាតិដុលត្រូវបានប្រើប្រាស់ជាញឹកញាប់ដោយធនាគារជាតិ ដើម្បីរក្សាស្ថិរភាពអត្រា ប្តូរប្រាក់ (សម្រាប់ព័ត៌មានលម្អិត សូមមើលវិស័យរូបិយវត្ថុខាងក្រោម)។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងរហូតដល់ ៤,២ ពាន់លានដុល្លា (ច្រើនបំផុតមិនធ្លាប់មាន) ឬប្រហែលជា ៣,៥ ខែនៃការនាំចូលត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ ឬកើនឡើង ១៧ ភាគរយធៀបនឹងឆ្នាំមុន ដែលនេះ អត្រាកំណើនលឿនបំផុតក្នុងអំឡុងក្រោយពេលមានវិបត្តិ។ កន្លងមក ទុនបម្រុងអន្តរជាតិដុលមានសភាពនៅទ្រឹង ដោយជាមធ្យមមានប្រហែល ៣,៦ លានដុល្លា (ឬ ៣,៤ ខែនៃការនាំចេញ) ក្នុងឆ្នាំ២០១៣ ដោយសារតែភាពមិនប្រាកដប្រជាផ្នែកនយោបាយ។

**រូប ៩** កំណើនឱនភាពពាណិជ្ជកម្មដោយសារតែកំណើននាំចូលលើសពីកំណើននៃការនាំចេញ (គិតជាលានដុល្លា)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា និងតួលេខប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូប ១០** កំណើនឱនភាពពាណិជ្ជកម្ម ដោយសារកំណើនការនាំចូលមានចំនួនច្រើនជាងកំណើនការនាំចេញ (គិតជាលានដុល្លា)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា និងតួលេខប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

### ក) ការនាំចេញ

**១២ .ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានរក្សា មួយផ្នែកដោយសារតែ ស្ថានភាពវិស័យទូទាត់ក្រៅប្រទេសប្រកបដោយស្ថិរភាព និងការបន្តកំណើនរឹងមាំ។** កំណើននៃការនាំចេញបានបន្តដោយសារតែដំណើរការល្អនៃការនាំចេញផ្នែកកម្មន្តសាល ដែលប្រើកម្លាំង

ពលកម្មច្រើន ដូចជា សំលៀកបំពាក់ និងស្បែកជើង។ កំណើននេះត្រូវបានគាំទ្រដោយបរិយាកាសសេដ្ឋកិច្ចសកលដែលមានភាពប្រសើរឡើង ប្រព័ន្ធអនុគ្រោះដែលប្រទេសកម្ពុជាទទួលបានក្រោមគម្រោង "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ" របស់សហភាពអឺរ៉ុប និងស្ថានភាពល្អនៃហិរញ្ញប្បទានពីខាងក្រៅ រួមមាន ការបង្កើនការវិនិយោគពីបរទេស។ ទោះជាយ៉ាងណាក៏ដោយបើគិតពីតម្លៃ ការនាំចេញទំនិញកសិកម្ម ដូចជា អង្ករ និងកៅស៊ូ នៅតែទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការធ្លាក់ចុះតម្លៃទំនិញកសិកម្មក្នុងពិភពលោក ទោះបីជាបរិមាណ នៃការនាំចេញមានការកើនឡើងក៏ដោយ។ យ៉ាងណាក៏ដោយចំនួនទឹកប្រាក់សរុបនៃការនាំចេញគិតជាប្រាក់ដុល្លា ត្រូវបានប៉ាន់ស្មានថា បានកើនឡើងជាង ១៨ ភាគរយនៅពាក់កណ្តាលឆ្នាំ២០១៤ ធៀបនឹងឆ្នាំ ២០១៣ ដែលមានកំណើនត្រឹមតែ ១៤,៥ ភាគរយប៉ុណ្ណោះ ដោយសារតែកំណើនជាបន្តនៃការនាំចេញសម្លៀកបំពាក់។

## ខ) ការនាំចូល

**១២. ដោយសារតែកម្ពុជាស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច កំណើននៃការការនាំចូលមានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រវិស័យសេវាកម្ម និងកម្មន្តសាលដែលមានការលូតលាស់យ៉ាងលឿន។** កំណើននៃការនាំចូលបានកើនឡើង ដោយមានការគាំទ្រពីកំណើនការនាំចូលយានជំនិះ ផលិតផលឥន្ធនៈ និងសម្ភារសំណង់ ដោយសារតែអ្នកប្រើប្រាស់ និងវិនិយោគិនមានភាពជឿជាក់សាជាថ្មី។ កំណើនការនាំចូលហាក់ដូចជាយឺតជាងកំណើនការនាំចេញក្នុងអំឡុងប្រាំមួយខែដំបូង ប៉ុន្តែត្រូវបានព្យាករថានឹងមានកំណើនក្នុងអំឡុងឆមាសទីពីរក្នុងឆ្នាំនេះ ដោយសារទទួលបានទំនុកចិត្តសាជាថ្មីក្នុងវិស័យសេដ្ឋកិច្ច ហើយភាពជាប់គាំងផ្នែកនយោបាយត្រូវបានបញ្ចប់នៅក្នុងខែកក្កដា។

## ៣. អតិផរណា

**១៣. ទោះបីជាមានកំណើនអតិផរណាបន្តិច ស្ថិរភាពតម្លៃនៅតែស្ថិតក្នុងកម្រិតអាចទទួលយកបាន ដែលជំរុញការលូតលាស់សេដ្ឋកិច្ច និងគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ។** អតិផរណាបានកើនឡើងបន្តិចពី ៤,៦ ភាគរយ កាលពីបំណាច់ឆ្នាំ ២០១៣ រហូតដល់ ៤,៩ ភាគរយត្រឹមពាក់កណ្តាលឆ្នាំ២០១៤ (រូបលេខ ១១)។ តម្លៃគ្រឿងឧបភោគបរិភោគភាគច្រើន ដែលជាកត្តាជំរុញដ៏សំខាន់នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅកម្ពុជា (CPI) ដែលមានកម្រិតជំរុញចំនួន ៤៣,៣ ភាគរយនៅតែមានកម្រិតថេរ។ ទោះយ៉ាងណា គ្រឿងឧបភោគបរិភោគមួយចំនួន ដូចជា សាច់ និងផ្លែឈើ និងគ្រឿងមិនមែនឧបភោគបរិភោគ ដូចជា ទំនិញប្រើប្រាស់នៅតែបន្តបង្កើតសម្ពាធអតិផរណាដោយសារតែកំណើនតម្រូវការ។

រូប ១១ ការរួមចំណែកដល់អតិផរណារយៈពេល១២ ខែ ភាគច្រើនបណ្តាលមកពីអនុសន្ទស្សន៍នៃស្បៀងអាហារ

(CPI, Phnom Penh)




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ

**១៤. ការថយចុះអតិផរណាក្នុងប្រទេសក្នុងតំបន់ក៏ជួយទប់អតិផរណានៅកម្ពុជាដែរ។** អតិផរណារបស់ប្រទេសក្នុងតំបន់ និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត បានធ្លាក់ចុះ ចាប់ពីត្រីមាសទីពីរក្នុងឆ្នាំ ២០១៤ (រូបលេខ ១២)។ ការធ្លាក់ចុះនេះបង្ហាញពីអតិផរណាកម្រិតទាបក្នុងប្រទេសចិន ទន្ទឹមនឹងកំណើនដ៏យឺត។ តម្លៃទំនិញដែលនៅថេរ បានធ្វើឲ្យមានការធ្លាក់ចុះអតិផរណាក្នុងចំណោមប្រទេសដែលមានចំណូលទាប នៅខណៈពេលដែលការពង្រឹងគោលនយោបាយក៏បានរួមចំណែក

ដល់ការដោះស្រាយបញ្ហាអតិផរណា នេះផងដែរ។ សម្រាប់ប្រទេសមានចំណូលមធ្យមមួយចំនួនអតិផរណា នៅតែមានកម្រិតខ្ពស់ ដែលបង្ហាញពីការឆ្លងចូលពីការធ្លាក់ចុះថ្លៃនៃរូបិយប័ណ្ណក្នុងស្រុកកាលពីមុន។ហានិភ័យតម្លៃអង្ករដោយសារលក្ខខណ្ឌធាតុអាកាស El Nino អាចធ្វើឲ្យអតិផរណាកើនឡើង។

រូប ១២ អតិផរណារបស់ប្រទេសក្នុងតំបន់ និងប្រទេសកំពុងអភិវឌ្ឍន៍បានថយចុះ (% ប្រែប្រួលធៀបនឹងឆ្នាំមុន)។



ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ និងការិយាល័យស្ថិតិរបស់ប្រទេសក្នុងតំបន់

## ៤. វិស័យរូបិយវត្ថុ

### ក) រូបិយវត្ថុសរុប អត្រាប្តូរប្រាក់ និងអត្រាការប្រាក់

**១៥. ការមានទំនុកចិត្តឡើងវិញលើសេដ្ឋកិច្ច និងប្រព័ន្ធធនាគារ បានធ្វើឲ្យមានកំណើនរូបិយប័ណ្ណទូទៅ។** កំណើនរូបិយប័ណ្ណទូទៅបានកើនឡើង ២០,៨ ភាគរយ ត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ ធៀបនឹងបំណាច់ឆ្នាំ ២០១៣ ដែលមានត្រឹមតែ ១៤,៦ ភាគរយ (រូបលេខ ១៣) ក្នុងអំឡុងពេលដូចគ្នានេះចំណែកប្រាក់បញ្ញើរូបិយប័ណ្ណបរទេស (FCD) ក្នុងកំណើនរូបិយប័ណ្ណទូទៅបានកើនឡើងពី ៨២ ភាគរយរហូតដល់ ៨៤ ភាគរយ ដោយសារមានការជឿទុកចិត្តសាជាថ្មីលើប្រព័ន្ធធនាគារ ខណៈពេលដែលចំណែកប្រាក់រៀលដែលកំពុងចរាចរ (RIC) ធ្លាក់ចុះពី ១៤ ភាគរយមក ១២ ភាគរយ។ ចំណែកប្រាក់បញ្ញើជាប្រាក់រៀល (RD) មានចំនួនប្រហែល ៤ ភាគរយនៃរូបិយប័ណ្ណទូទៅ។

រូប ១៣ ភាគរយបញ្ញើរូបិយប័ណ្ណបរទេសក្នុងកំណើនរូបិយប័ណ្ណទូទៅបានកើនពី ៨២% នៅចុងឆ្នាំ២០១៣ រហូតដល់ ៨៤% ក្នុងខែមិថុនា ឆ្នាំ២០១៤



ប្រភព ៖ធនាគារជាតិនៃកម្ពុជា

**១៦. តួនាទីរបស់រូបិយប័ណ្ណ ប្រាក់រៀល បានថយចុះចាប់តាំងពីចុងឆ្នាំ ២០១៣ នៅខណៈពេលដែលមានកំណើនរូបិយប័ណ្ណទូទៅ ដែលប៉ះពាល់ថែមទៀតដល់គោលនយោបាយរូបិយវត្ថុ។** កត្តារួមចំណែកដល់កំណើនរូបិយប័ណ្ណទូទៅប្រមាណ ២០,៨ ភាគរយនៅពាក់កណ្តាលឆ្នាំ២០១៤ ភាគច្រើនបណ្តាលមកពីប្រាក់បញ្ញើរូបិយប័ណ្ណបរទេស (១៨,១ ភាគរយ) ដោយការរួមចំណែករបស់ប្រាក់រៀលដែលចរាចរណ៍មានចំនួន ១,៦ ភាគរយ ហើយចំណែកនៅសល់គឺប្រាក់បញ្ញើជាប្រាក់រៀលដែលមានចំនួន ១,១ ភាគរយ (រូបលេខ ១៤)។ ដោយសារតែមានការវិលត្រឡប់នៃ ការជឿទុកចិត្តលើវិស័យធនាគារវិញកំណើនប្រាក់បញ្ញើរូបិយប័ណ្ណបរទេសកើនឡើងយ៉ាងលឿនរហូតដល់ ២១,៨ ភាគរយ ត្រឹមពាក់កណ្តាលឆ្នាំ២០១៤ បើធៀបនឹងបំណាច់ឆ្នាំ២០១៣ ដែលមានត្រឹមតែ ១៣,៤ ភាគរយប៉ុណ្ណោះ ដោយសារតែមានការជឿទុកចិត្តសាជាថ្មីលើវិស័យ ធនាគារ។ ទោះជាយ៉ាងណាក៏ដោយ កំណើនប្រាក់រៀលដែលកំពុងចរាចរបានធ្លាក់ចុះពី ១៨,៦ ភាគរយ មក ១២ ភាគរយ ក្នុងអំឡុងពេលដូចគ្នានេះ។ តួលេខនេះបានបង្ហាញពីការថយចុះក្នុងការប្រើប្រាស់ប្រាក់រៀល បើធៀបនឹងប្រាក់ដុល្លា ដែលនេះជាជំហានថយក្រោយមួយឆ្ពោះទៅរកការធ្វើបដិដុល្លារូបនីយកម្ម។

**១៧. ការថយចុះក្នុងការប្រើប្រាស់ប្រាក់រៀលប៉ះពាល់ដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ។** សេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មខ្ពស់ធ្វើឲ្យ អាជ្ញាធរផ្នែករូបិយវត្ថុលំបាកក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលចាំបាច់ដើម្បីគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។ ការកំណត់អត្រាប្តូរប្រាក់ ដែលមានភាពសមស្របក្នុងការរក្សាលំនឹងតម្លៃផ្លូវការនៃរូបិយប័ណ្ណក្នុងស្រុក មិនបានជំរុញឲ្យមានការកាត់បន្ថយដុល្លារូបនីយកម្មនោះទេ ហើយក្នុងពេលបច្ចុប្បន្នដែលរូបិយប័ណ្ណអាស៊ានកំពុងចុះតម្លៃធៀបនឹងប្រាក់ដុល្លានោះ ស្ថានភាពនេះនឹងប៉ះពាល់ដល់ការប្រកួតប្រជែងការនាំចេញរបស់កម្ពុជា។ ទោះបីជាទុនបម្រុងអន្តរជាតិសរុបមានរហូតដល់កម្រិតមួយខ្ពស់បំផុតរហូតដល់ ៤,២ ពាន់លានដុល្លា ប្រហែល ៣,៥ ខែ នៃការនាំចូលត្រឹមពាក់កណ្តាលឆ្នាំ២០១៤ ក៏ទុនបម្រុងទាំងនោះនៅតែមានកម្រិតទាប បើធៀបនឹងស្តង់ដាក្នុងតំបន់ និងក្នុងបរិបទដែលធនាគារកណ្តាល មិនអាចដើរតួជាផ្តល់ប្រាក់កម្ចីដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់។

រូប ១៤ **កំណើនបញ្ញើរូបិយប័ណ្ណបរទេសបានកើនឡើង ដោយសារតែការមានទំនុកចិត្តសាជាថ្មីលើវិស័យធនាគារ**

ការរួមចំណែកដល់កំណើនរូបិយប័ណ្ណទូទៅ(% ប្រែប្រួលធៀបនឹងឆ្នាំមុន)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**១៨.ការប្រកួតប្រជែងកាន់តែខ្លាំងក្នុងចំណោមធនាគារបានរួមចំណែកធ្វើឲ្យធ្លាក់ចុះតម្លៃអត្រាការប្រាក់ដុល្លាអាមេរិក ដូច្នេះកាត់បន្ថយការចំណាយលើប្រាក់កម្ចី ទោះបីជាមានការរិតបណ្តឹងនយោបាយរូបិយវត្ថុជាបណ្តើរៗរបស់សហព័ន្ធ**[3]។ អត្រាប្រាក់កម្ចីជាប្រាក់ដុល្លា (១២ខែ) បានធ្លាក់ចុះបន្តិចពី ១១,៣ ភាគរយ កាលពីបំណាច់ឆ្នាំ២០១៣ មកត្រឹម ១១,២ ភាគរយ ត្រឹមខែមេសា ឆ្នាំ២០១៤(រូបលេខ ១៥)។ ទោះបីជាគម្លាតអត្រាការប្រាក់ (ភាពខុសគ្នារវាងអត្រាប្រាក់កម្ចីធម្មតា និងអត្រាប្រាក់បញ្ញើ) ជាក់ស្តែងនៅមានគម្លាតធំក៏ដោយ គម្លាតនេះបានរួមតូចបន្តិចម្តងៗ ដោយសារមានការកើនឡើងនូវការប្រកួតប្រជែងរបស់ធនាគារ។ លំហូរមូលធនបានងើបឡើងវិញយ៉ាងលឿន បន្ទាប់ពីមានការថយចុះអស្ថិរភាពនយោបាយ នៅដើមឆ្នាំនេះ និងបានធ្វើឲ្យចំណាយលើការខ្ចីប្រាក់មានការធ្លាក់ចុះ។

រូប ១៥ **អត្រាខ្ចីប្រាក់ដុល្លារជាមធ្យមនៅតែថយចុះ**

អត្រាការប្រាក់ដុល្លាររយៈពេល ១២ខែ (គិតជាភាគរយក្នុងមួយឆ្នាំ)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**១៩. អត្រាប្តូរប្រាក់ពិត និងអត្រាប្តូរប្រាក់ជាក់ស្តែងមានការឡើងថ្លៃបន្តិចនៅក្នុងកំឡុងពេលឆមាសទីមួយឆ្នាំ ២០១៤។** ការកំណត់អត្រាប្តូរប្រាក់បានរួមចំណែកធ្វើឲ្យមានស្ថិរភាពអត្រាប្តូរប្រាក់រវាងប្រាក់រៀល និងប្រាក់ដុល្លា ដែលនៅថេរត្រឹម ៤.០០០ រៀល ក្នុង ១ ដុល្លា អស់រយៈពេលជាច្រើនឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ

[3]យោងតាមកំណត់ហេតុរបស់គណៈកម្មាធិការសហព័ន្ធទីផ្សារសេរី កាលពីថ្ងៃទី ២៩-៣០ ខែកក្កដា ឆ្នាំ២០១៤ របស់ប្រព័ន្ធទុនបម្រុងសហព័ន្ធ (Fed) គណៈកម្មាធិការបានព្រមព្រៀងថា នៅដើមខែសីហា គណៈកម្មាធិការនឹងបន្ថែមទឹកប្រាក់ ចំនួន ១០ ពាន់លានដុល្លាក្នុងមួយខែ ជាជាង ១៥ ពាន់លានដុល្លាក្នុងមួយខែ ទៅក្នុងស្តុករបស់ទីភ្នាក់ងារ MBS ហើយនឹងបន្ថែម ១៥ ពាន់លានដុល្លា មិនមែន ២០ ពាន់លានដុល្លា ទៅក្នុងស្តុកមូលប័ត្ររតនាគាររបស់ខ្លួន។

ការកំណត់អត្រាប្តូរប្រាក់នេះបានធ្វើឲ្យមានការបង្កើនតម្លៃអត្រាប្តូរប្រាក់ជាក់ស្តែង និងអត្រាប្តូរប្រាក់ពិតដោយសារតែប្រាក់ដុល្លា ទើបតែឡើងថ្លៃ ធៀបនឹងរូបិយប័ណ្ណសំខាន់ៗផ្សេងទៀត ដូចជាប្រាក់អឺរ៉ូ និងប្រាក់យ៉េន ដែលជារូបិយប័ណ្ណដៃគូពាណិជ្ជកម្មកម្ពុជាយ៉ាងសំខាន់ (រូប ១៦)។ សន្ទស្សន៍អត្រាប្តូរប្រាក់ជាក់ស្តែង (2010=100) បានធ្លាក់ចុះពី ១០៣,៩ កាលពីចុងឆ្នាំ ២០១៣ មក ១០៣,៣ កាលពីខែឧសភា ឆ្នាំ២០១៤ ខណៈដែលសន្ទស្សន៍អត្រាប្តូរប្រាក់ពិតធ្លាក់ចុះពី ១០៩,៩ មក ១០៩,៥ ក្នុងអំឡុងពេលដូចគ្នា។ ដោយសារថ្មីៗនេះ មានការឡើងថ្លៃប្រាក់ដុល្លា អត្រាប្តូរប្រាក់រវាងប្រាក់រៀល និងប្រាក់ដុល្លា មានការធ្លាក់ចុះតិចតួចត្រឹម ៤,០៤០ រៀល ក្នុងមួយដុល្លាត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំកន្លងទៅគឺ ១ ដុល្លា ប្តូរបានតែ ៣,៩៩៥ រៀលនៅបំណាច់ឆ្នាំ ២០១៣។

រូប ១៦ អត្រាប្តូរប្រាក់ជាក់ស្តែង និងអត្រាប្តូរប្រាក់ពិត បានកើនឡើងតិចតួច

NEER និង REER (សន្ទស្សន៍ 2010=100)




ប្រភព ៖ IFS

## ខ) វិស័យធនាគារ

**២០. កំណើនប្រាក់បញ្ញើរបស់វិស័យឯកជនបានកើនឡើងយ៉ាងលឿន ដោយសារតែការមានទំនុកចិត្តឡើងវិញសាជាថ្មី ដែលបានធ្វើឲ្យមានកំណើនស្ថិរភាពក្នុងវិស័យធនាគារ។** ប្រាក់បញ្ញើក្នុងវិស័យឯកជនបានកើនឡើងដល់ ៨,០៩ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ២២,២ ភាគរយ ត្រឹមពាក់កណ្តាលឆ្នាំ២០១៤ ធៀបនឹងចុងឆ្នាំ ២០១៣ ដែលប្រាក់បញ្ញើក្នុងវិស័យឯកជនមាន ៦,៨៨ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ១៨,២ ភាគរយ (គួរកត់សម្គាល់ថា ប្រាក់បញ្ញើវិស័យឯកជនបានធ្លាក់ចុះក្នុងអំឡុងក្រោយពេលបោះឆ្នោត ចាប់ពីខែកក្កដា រហូតដល់ ខែសីហា ឆ្នាំ២០១៣ ដែលធ្លាក់ចុះពី ៦,៥ ពាន់លានដុល្លា ក្នុងខែមិថុនា រហូតដល់ ៥,៩ ពាន់លានដុល្លាក្នុងខែ សីហា ប៉ុន្តែកើនវិញក្នុងខែ វិច្ឆិកា។ កំណើនឥណទានដែលហាក់មានការកើនឡើងខ្ពស់ក្នុងអំឡុងពីរបីឆ្នាំកន្លងមកនេះ បានធ្លាក់ចុះមកត្រឹម ២១,៨ ភាគរយ ដោយឥណទានដែលមិនទាន់សងមានចំនួន ៧,៥៨ ពាន់លានដុល្លាអាមេរិក ត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំ២០១៣ មានការធ្លាក់ចុះពី ២៦,៧ ភាគរយដោយមានចំនួនឥណទានដែលមិនទាន់សង ៦,៩១ ពាន់លានដុល្លាអាមេរិក។ ការកើនឡើងនៃកំណើនប្រាក់បញ្ញើ ទន្ទឹមនឹងការធ្លាក់ចុះកំណើនឥណទាន បានធ្វើឲ្យអនុបាតរវាងប្រាក់កម្ចី និងប្រាក់បញ្ញើធ្លាក់ចុះពី ៩០ ភាគរយនៅចុងឆ្នាំ២០១៣ មក ៨២,២ ភាគរយ ត្រឹមពាក់កណ្តាលឆ្នាំ ២០១៤ (រូប ១៧)។

រូប ១៧ ការបង្កើនការជឿទុកចិត្ត ធ្វើឲ្យមានកំណើនប្រាក់បញ្ញើនៅធនាគារ ខណៈពេលដែលកំណើនឥណទានបានចុះ ដែលធ្វើឲ្យអនុបាតរវាងប្រាក់កម្ចី និងប្រាក់បញ្ញើមានកម្រិតទាប (ដោយកំណើនខ្ពស់ទីបំផុតបានថយចុះ)



ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**២១. វិស័យហិរញ្ញវត្ថុ និងធនាគារ បានបន្តគាំទ្រ ដល់វិស័យសេវាកម្ម(ដែលជាម៉ាស៊ីនកំណើន ផសស ដ៏សំខាន់) ជាពិសេសចំពោះអាជីវកម្មលក់ដុំ និងរាយ។** អាជីវកម្មលក់ដុំ និងរាយ នៅបន្តស្រូបយកឥណទានសរុបសម្រាប់វិស័យឯកជនប្រហែល ១ ភាគ ៣។ ក្រៅពីនេះ

ឥណទានមិនបានប្រមូលផ្តុំច្រើនតែក្នុងវិស័យមួយ វិស័យមួយចំនួនតូចនោះឡើយ (រូប១៨)។

រូប ១៨ ការលក់ដុំ និងលក់រាយ នៅតែបន្តស្រូបឥណទានជាង ១ ភាគ ៥។ ឥណទានរបស់សហគ្រាសពាណិជ្ជកម្ម (ខែមេសា ឆ្នាំ២០១៤)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៥. វិស័យសារពើពន្ធ

**ដំណើរការសារពើពន្ធ ត្រូវបានពង្រឹងបន្ថែម ដែលផ្តល់ហិរញ្ញប្បទានបន្ថែមគាំទ្រដល់កំណើននៃការចំណាយសាធារណៈ ដោយមិនប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** ការប្រមូលចំណូលបានកើនឡើងយ៉ាងលឿន ដោយបានកើនចំនួន ២១ ភាគរយក្នុងអំឡុង ៤ ខែដំបូង នៅខណៈពេលដែលចំណាយដែលមានកម្រិតទាបតាំងពីដំបូង នឹងនៅរក្សាកម្រិតដដែល ទៅតាមថវិកាដែលបានគ្រោងទុក។ ឱនភាពសារពើពន្ធសរុប (រាប់ទាំងជំនួយឥតសំណងផង) បានកើនឡើងរហូតដល់ ២,៧ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៣ ហើយត្រូវបានព្យាករថានឹងមានការធ្លាក់ចុះមកត្រឹម ២,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤។

### ក) សមាសភាគចំណូល

**២២.ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលត្រូវបានព្យាករថានឹងកើនឡើងរហូតដល់ ១៦ ភាគរយនៃ ផលិតផលក្នុងស្រុកសរុប ឬ ២,៦៨ ពាន់លានដុល្លាអាមេរិកក្នុងឆ្នាំ ២០១៤ ដោយសារតែការគ្រប់គ្រងចំណូលមានភាពប្រសើរជាមុន** (រូប១៩)។ ចំណូលក្នុងស្រុកធ្លាក់ចុះពី ១៥,៣ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១២ មកត្រឹម ១៥,១ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៣ ដោយសារកំណើននៃការប្រមូលពន្ធដោយប្រយោលទទួលរងការប៉ះពាល់ដោយ សារតែការធ្លាក់ចុះចំណូលមិនមែនពន្ធ និងចំណូល តាមខេត្ត។ ចំណូលក្នុងប្រទេសរបស់ កម្ពុជាពឹងផ្អែកជាចម្បងលើការយកពន្ធដោយប្រយោល។ ពន្ធតម្លៃបន្ថែមរួមចំណែកដល់ ចំណូលពន្ធសរុបប្រមាណមួយភាគបីក្នុងឆ្នាំ២០១៣ ខណៈពេល ដែលពន្ធពាណិជ្ជកម្ម (រួមទាំងអាករលើទំនិញនាំចូល) រួមចំណែកប្រមាណ ២០ ភាគរយ។ ពន្ធផ្ទាល់ដែលគ្របដណ្តប់លើពន្ធចំណូលសាជីវកម្ម នៅតែមានចំនួនតិច ដោយ សារការអនុគ្រោះពន្ធច្រើន។ ចំណូលក្នុងប្រទេសក្នុងឆ្នាំ ២០១៤ ត្រូវបានព្យាករថានឹងមានការកើនឡើង ដោយសារការពង្រឹងការគ្រប់គ្រងចំណូល (ប្រអប់ ៤) និងការលូតលាស់នៃសកម្មភាពសេដ្ឋកិច្ច រួមទាំងការនាំចូលផង។

រូប ១៩ ចំណូលក្នុងប្រទេសរបស់រដ្ឋាភិបាល ត្រូវបានព្យាករថានឹងកើនឡើងដោយសារកំណើនពន្ធប្រយោល និងពន្ធពាណិជ្ជកម្ម។ **សមាសភាគចំណូល** (គិតជាភាគរយនៃផសស)




ចំណាំ ៖ p= ព្យាករណ៍

ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ប្រអប់ ៣** **ការបង្កើនការគ្រប់គ្រងចំណូល**

តាមរយៈ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋាភិបាល កំពុងពង្រឹងការគ្រប់គ្រងលើចំណូល។ វិធានការបង្កើនចំណូល រួមមានការបង្កើតយុទ្ធសាស្ត្រប្រមូលចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ ការពង្រឹងប្រព័ន្ធស្វ័យប្រវត្តិសម្រាប់ ទិន្នន័យគយ (ASYCUDA) និងការពង្រឹងប្រព័ន្ធមូលដ្ឋានទិន្នន័យគ្រប់គ្រងហានិភ័យគយ ដោយធ្វើឲ្យដំណើរការកាន់តែប្រសើរសូចនាករហានិភ័យ និងការធ្វើសវនកម្មក្រោយពេលបំពេញបែបបទរួច។ សកម្មភាពបង្កើនចំណូលផ្សេងទៀតរួមមានកិច្ចពិភាក្សារបស់ក្រុមការងារអន្តរក្រសួងនិងការសម្របសម្រួលបញ្ហាពាក់ព័ន្ធនឹងការប្រមូលចំណូលពីប្រេង និងឧស្ម័ន ការចាប់ផ្តើមអនុវត្តប្រព័ន្ធបង្កាន់ដៃទទួលប្រាក់ចំណូលមិនមែនពន្ធសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹង និងពង្រីកប្រព័ន្ធវាយតម្លៃដោយខ្លួនឯងលើអ្នកបង់ពន្ធ ការពង្រឹងនិងពង្រីកការបង់ប្រាក់តាមប្រព័ន្ធធនាគារសម្រាប់អ្នកបង់ពន្ធខ្នាតមធ្យមតាមខេត្ត និងការបង្កើតក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីពន្ធដារ។ ក្របខ័ណ្ឌច្បាប់ និងនិយ័តកម្មសម្រាប់ការគ្រប់គ្រងចំណូលកំពុងត្រូវបានបង្កើតឡើង និងកែលម្អរួមទាំងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាស៊ីណូ។

ប្រភព ៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ខ) សមាសភាគចំណាយ

**២៣. ចំណាយទូទៅសរុបរបស់រដ្ឋាភិបាល ត្រូវបានព្យាករថាស្របទៅនឹងថវិកាដែលបានគ្រោងទុក ២០,៤ ភាគរយនៃផលិតផលក្នុងស្រុកសរុបឆ្នាំ ២០១៤ ឬ ៣,៤ ពាន់លានដុល្លាអាមេរិក** (រូប ២០)។ ចំណាយនេះស្ថិតនៅក្រោមចំនួន ២១,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប ដែលបានអនុវត្តកាលពីឆ្នាំ ២០១៣ ដែលជាឆ្នាំដែលមានការបោះឆ្នោត។ ដោយសារតែជំនួយឥតសំណង និងប្រាក់កម្ចីសម្បទាន ប្រទេសកម្ពុជាអាចវិភាជន៍ចំណូលក្នុងស្រុករបស់ខ្លួនស្ទើរតែទាំងស្រុង កាលពីប៉ុន្មានឆ្នាំមុនដើម្បីចេញថ្លៃចំណាយចរន្ត ដែលមានប្រហែល ១២ ភាគរយនៃផលិតផលក្នុងស្រុកសរុប (៥៥ ភាគរយនៃការចំណាយសរុប) នៅពេលដែលមានការរក្សាការចំណាយមូលធនចំនួនប្រហែល ៨ ភាគរយនៃផលិតផលក្នុងស្រុកសរុប (៤៥ ភាគរយនៃចំណាយសរុប) ដែលក្នុងនោះ បីភាគបួនជាហិរញ្ញប្បទានពីបរទេស។

**រូប ២០** ចំណាយរបស់រដ្ឋាភិបាលនៅតែស្ថិតក្រោមការគ្រប់គ្រង ទោះបីជាមានកំណើនបញ្ជីបៀវត្សរ៍ក៏ដោយ។ សមាសភាពចំណាយ (គិតជាភាគរយនៃផសស)




ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ចំពោះសមាសភាពចំណាយចរន្ត បញ្ជីបៀវត្សមានការកើនឡើងយ៉ាងលឿនរហូតដល់ ៥,៦ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៤ ធៀបនឹងឆ្នាំ ២០០៦ ដែលមានត្រឹមតែ ២,៨ ភាគរយ។

## គ) សមតុល្យសារពើពន្ធ

**២៤. ការថយចុះឱនភាពសារពើពន្ធដែលបណ្តាល មកពីការប្រមូលពន្ធប្រសើរជាងមុន បានជួយ កែលម្អស្ថានភាពសារពើពន្ធរបស់កម្ពុជា និង ជំរុញដំណើរការសារពើពន្ធដោយនិរន្តរភាព នៅខណៈពេលដែលកែលម្អការផ្តល់សេវាកម្មសាធារណៈ។** ឱនភាពសារពើពន្ធសរុប (រួមទាំងជំនួយឥត សំណង) បានកើនឡើងរហូតដល់ ២,៧ ភាគរយ នៃផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៣ និងត្រូវបានព្យាករថានឹងថយមកត្រឹម ២,៥ ភាគរយ នៃផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៤ (រូប ២១)។ ឱនភាពសារពើពន្ធនៅបន្តកើតមាន ដោយសារហិរញ្ញប្បទានដ៏ច្រើនលើសលប់ពីមូលនិធិក្រៅប្រទេស (រូប ២២)។ ហេតុដូច្នេះ ប្រាក់សន្សំរបស់រដ្ឋាភិបាល (ប្រាក់បញ្ញើ) កើនឡើងរហូតដល់ ៩៣១ លានដុល្លាអាមេរិក ត្រឹម

ពាក់កណ្តាលឆ្នាំ២០១៤ ធៀបនឹងចុងឆ្នាំ ២០១៣ ដែលមានចំនួន ៧០០ លានដុល្លា។

**២៥. ទោះជាគោលនយោបាយពង្រឹកសារពើពន្ធមិនកំណត់ត្រឹមតែការប្រើប្រាស់ប្រាក់សន្សំរបស់រដ្ឋាភិបាលក្តី កំណើនប្រាក់សន្សំអាចជួយដោះស្រាយបញ្ហាប៉ះពាល់ ដោយមិនចាំបាច់ប្រើប្រាស់ហិរញ្ញប្បទាន ខ្ចីប្រាក់ពីធនាគារក្នុងប្រទេសឡើយ ហើយការធ្វើបែបនេះនឹងជួយរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** គោលនយោបាយសារពើពន្ធនៅតែ ជាឧបករណ៍ចម្បងក្នុងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដោយសារកំណើនដុល្លារូបនីយកម្ម។ ចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុលនៃប្រទេសកម្ពុជា នៅតែមានកម្រិតទាប។ ការវិភាគរួមគ្នារវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិអំពីនិរន្តរភាពបំណុល ក្នុងឆ្នាំ២០១៣ បានបង្ហាញថា ចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុលរបស់ប្រទេសកម្ពុជានៅ មានកម្រិតទាបដោយ សូនាករបន្ទុកបំណុលទាំងអស់ត្រូវបាន ព្យាករថាស្ថិតនៅក្រោមកម្រិតគោលនៃសូចនាករបន្ទុកបំណុលទាំងនោះ។

រូប ២១ ឱនភាពសារពើពន្ធមានភាពប្រសើដោយសារកំណើនការប្រមូលចំណូល (គិតជាភាគរយនៃផសស)




ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រូប ២២ មូលនិធិក្រៅប្រទេសផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធ (គិតជាភាគរយនៃ ផសស)។




ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ខ្លឹមសារគន្លឹះ និងអនុសាសន៍

**២៦. ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលមួយឆ្ពោះទៅកាន់ការបន្តមានកំណើនដ៏ខ្ពស់មួយឆ្នាំទៀត ដោយសារការងើបឡើងនៃសេដ្ឋកិច្ចក្នុងប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន និងការកាត់បន្ថយភាពមិនប្រាកដប្រជាក្នុងប្រទេស។** វិនិយោគិនមានទំនុកចិត្តសាជាថ្មី បន្ទាប់ពីមានភាពមិនប្រាកដប្រជាដែលបានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០១៣ រហូតដល់ដើមឆ្នាំនេះ ហើយដោយ សារការជឿទុកចិត្តរបស់វិនិយោគិនសាជាថ្មីនេះ បានធ្វើឲ្យវិស័យវិនិយោគងើបឡើងវិញ។ ការរក្សាសន្តិភាព និងស្ថិរភាពទីផ្សារការងារ នឹងជាការសំខាន់ក្នុងការបន្តទាក់ទាញការវិនិយោគពីបរទេស គាំទ្រដល់ការពង្រីកវិស័យកម្មន្តសាល និងទទួលផលឲ្យបានច្រើនបំផុតពីការងើបឡើងវិញ ក្នុងសកលលោក។ ការសម្រេចឲ្យបាននូវដំណើរការច្បាស់លាស់ និងមានតម្លាភាពក្នុង ការចរចាប្រាក់ឈ្នួលអប្បបរមាត្រីភាគីសម្រាប់វិស័យកាត់ដេរ នឹងមានសារៈសំខាន់ក្នុងការជំរុញការអភិវឌ្ឍន៍វិស័យកាត់ដេរសំលៀកបំពាក់។

**២៧. កម្រិតម៉ាស៊ីនកំណើនរបស់កម្ពុជាមានការផ្លាស់ប្តូរ ដែលបង្ហាញពីតម្រូវការក្នុងការក្នុងការជំរុញវិស័យកសិកម្ម និងទេសចរណ៍ ដែលបានជួបប្រទះល្បឿនកំណើនយឺតជាងមុន។** ចាំបាច់ត្រូវមានការពិនិត្យឡើងវិញលើការបែងចែក និងប្រសិទ្ធភាពនៃការវិនិយោគលើវិស័យកសិកម្ម ជាពិសេសចំពោះប្រព័ន្ធធារាសាស្ត្រ និងសេវាផ្សព្វផ្សាយព័ត៌មានកសិកម្ម ដោយសារតែកំណើនផលិតកម្មស្រូវមានសភាពយឺតយ៉ាវ។ ការធ្វើដូច្នេះនឹងជួយធ្វើឲ្យប្រាកដថាតើ លទ្ធផលរកឃើញពីមុនដែលបានណែនាំឲ្យ បង្កើនមូលនិធិសម្រាប់ការស្រាវជ្រាវផ្នែកកសិកម្ម ការបង្កើនប្រសិទ្ធភាពនៃការចំណាយលើប្រព័ន្ធធារាសាស្ត្រ ដោយស្តារប្រឡាយសំខាន់ និងចំណាយឲ្យបានគ្រប់គ្រាន់ លើការថែទាំប្រព័ន្ធធារាសាស្ត្រ និងសេវាផ្សព្វផ្សាយព័ត៌មានកសិកម្មនោះ នៅតែមានសុពលភាព និងត្រូវដោះស្រាយឲ្យបាន ឬយ៉ាងណា។ ភស្តុភារដែលចំណាយតិច និងលឿនសម្រាប់ការនាំចេញផលិតផលកសិកម្មនឹងជំរុញឲ្យមានកំណើនវិស័យអង្ករ ព្រមទាំងជួយដល់ការធ្វើពិពិធកម្មការនាំចេញផលិតផលកសិកម្មផងដែរ។ ការបង្កើនការត្រៀមសម្រាប់គ្រោះទឹកជំនន់ធ្ងន់ធ្ងរ និងគ្រោះរាំងស្ងួតនឹងបង្កើនការទប់ទល់របស់វិស័យកសិកម្ម ដោយបច្ចុប្បន្ននេះផលិតផលកសិកម្មកំពុងមានការធ្លាក់ថ្លៃ។ ការពង្រីកវិស័យកសិកម្ម និងការទប់ទល់ទៅនឹងការប្រែប្រួលផ្សេងៗ មានផលប៉ះពាល់វិជ្ជមានដោយផ្ទាល់ចំពោះភាពក្រីក្រ ដោយសារតែប្រជាជនភាគច្រើនពឹងផ្អែកលើវិស័យនេះក្នុងការចិញ្ចឹមជីវិត។

**២៨. ការបន្តអភិវឌ្ឍវិស័យទេសចរណ៍នឹងជួយធ្វើឲ្យវិស័យនេះមានការរីកចម្រើនឡើងវិញ។** មានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ ហើយវិស័យសាធារណៈ មានមុខងារយ៉ាងសំខាន់ក្នុងការអនុវត្ត ឬជួយសម្របសម្រួលការអភិវឌ្ឍន៍នេះ តាមរយៈការជំរុញឲ្យមានការចូលរួមបន្ថែមទៀតពីវិស័យឯកជន។ វិស័យអេកូទេសចរណ៍នៅកម្ពុជាមិនទាន់មានការអភិវឌ្ឍន៍ច្រើននៅឡើយទេ ហើយមានសក្តានុពលជាច្រើននៅពេលមានការអភិវឌ្ឍន៍តំបន់ឆ្នេរ។ ដូចករណីប្រទេសកូស្តារីកា ការជំរុញទេសចរណ៍ចម្រុះអាចជួយបង្កើនចំនួនភ្ញៀវទេសចរ និងបង្កើនឥទ្ធិពលវិស័យទេសចរណ៍ចំពោះការរីកចម្រើន និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើនការងារនៅទីជនបទ។ ដោយសារភ្ញៀវ ៥០ ភាគរយធ្វើដំណើរមកតាមផ្លូវគោក ការស្តារ និងអភិវឌ្ឍន៍ផ្លូវថ្នល់ដែលភ្ជាប់តំបន់ទាក់ទាញភ្ញៀវទេសចរទៅកាន់តំបន់ព្រំប្រទល់ នឹងមានឥទ្ធិពលយ៉ាងខ្លាំងចំពោះចំនួនភ្ញៀវទេសចរ។ ការបង្កើនការសម្របសម្រួលរវាងអាជ្ញាធរថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន វិស័យឯកជន និងសហគមន៍មូលដ្ឋាន នឹងជួយបង្កើនកិច្ចប្រឹងប្រែងពង្រីកសេវាកម្មទេសចរណ៍។ ការជំរុញឲ្យមានស្ថិរភាព កិច្ចសហការក្នុងតំបន់ ការពង្រឹងភាពជាដៃគូជាមួយប្រទេសជិតខាងផ្សេងៗ បដិសណ្ឋារកិច្ច

និងសុវត្ថិភាព នឹងជួយធ្វើឲ្យវិស័យនេះកាន់តែមានភាពរីកចម្រើនថែមទៀត។

២៩. ការសម្របសម្រួលកំណើននៃវិស័យកម្មន្តសាលក៏នឹងមានសារៈសំខាន់ក្នុងការរក្សា និងជំរុញកំណើនសេដ្ឋកិច្ចដែរ។ ដូចដែលបានបង្ហាញនៅក្នុងប្រធានបទពិសេសទី ២ ការអង្កេតសហគ្រាសនៃការវាយតម្លៃបរិយាកាសវិនិយោគនាពេលខាងមុខ បង្ហាញថាបរិយាកាសធុរៈកិច្ចបន្តរាំងស្ទះដល់ការប្រកួតប្រជែងរបស់ក្រុមហ៊ុននៅកម្ពុជា។ ឧបសគ្គចម្បងសម្រាប់ក្រុមហ៊ុននៅតែជាលទ្ធភាពទទួលបាន និងថ្លៃអគ្គិសនី ការចំណាយក្រៅផ្លូវការ និងការអនុវត្តដោយគ្មានលក្ខណៈប្រកួតប្រជែង។ ការអង្កេតក៏បានបង្ហាញថាតំបន់សេដ្ឋកិច្ចពិសេស ដែលមានគោលបំណងផ្តល់បរិយាកាសធុរៈកិច្ចប្រសើរជាងមុន មិនទាន់ផ្តល់អត្ថប្រយោជន៍ផ្សេងៗដែលវិនិយោគិនបរទេសរំពឹងទុកនៅឡើយទេ។

**៣០. កិច្ចខិតខំប្រឹងប្រែងបន្ត ដើម្បីបង្កើនចំណូល និងប្រសិទ្ធភាពក្នុងការចំណាយ នឹងផ្តល់លទ្ធភាពឲ្យមានការចំណាយផ្នែកសង្គម និងការវិនិយោគសាធារណៈច្រើនជាងមុន។** ការបន្តពង្រីកមូលដ្ឋានពន្ធ និងការពង្រឹងការគ្រប់គ្រងពន្ធ នឹងជួយជំរុញដល់ការប្រមូលចំណូល ដែលនឹងធ្វើឲ្យមានការវិនិយោគសាធារណៈកាន់តែច្រើនក្នុងវិស័យសង្គម និងសេដ្ឋកិច្ចសំខាន់ៗ ដូចជា វិស័យអប់រំ ការអភិវឌ្ឍន៍ជំនាញ និងហេដ្ឋារចនាសម្ព័ន្ធ។

**៣១. ការពង្រឹងការគ្រប់គ្រងធនាគារ ដើម្បីឲ្យមានការពង្រឹងវិស័យហិរញ្ញវត្ថុ និងដើម្បីឈានទៅសម្រេចបាននូវស្វ័យភាពគោលនយោបាយរូបិយវត្ថុ នឹងជួយដល់ការគ្រប់គ្រងវិស័យម៉ាក្រូហិរញ្ញវត្ថុ។** ដំណើរការត្រួតពិនិត្យដោយពិនិត្យលើហានិភ័យដែលទើបតែអនុវត្តនាពេលថ្មីៗនេះ គឺជាជំហានដ៏សំខាន់ក្នុងការឆ្ពោះទៅរកការជំរុញស្ថិរភាពហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះ ធនាគារកណ្តាលកំពុងតែជំរុញឲ្យមានការប្រើប្រាស់ប្រាក់រៀល និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០។

**៣២. ការផ្តោតលើការអនុវត្ត** ភាគច្រើននៃខ្លឹមសារគន្លឹះខាងលើ ជាចំណុចដដែលៗសម្រាប់កម្ពុជា និងសុទ្ធតែត្រូវបានកំណត់ត្រឹមត្រូវ ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងដំណាក់កាលទីបី ដែលមានរយៈពេលប្រាំឆ្នាំ។ បញ្ហាប្រឈមចម្បងរបស់កម្ពុជាគឺការបង្កើតរៀបវារៈកំណែទម្រង់ និងការអនុវត្តរបៀបវារៈនោះ[4]ប្រកបដោយប្រសិទ្ធភាព ដែលទាមទារឲ្យមានការបង្កើនការសម្របសម្រួលអន្តរក្រសួង និងការដឹកនាំ ហើយសំខាន់បំផុត គឺការពិនិត្យតាមដានគោលដៅជាក់លាក់ក្នុងកំណែទម្រង់ទាំងនោះ។ ការអនុវត្តកំណែទម្រង់ទាំងនេះ បានជោគជ័យអាចជួយឲ្យកម្ពុជាសម្រេចបាននូវនិន្នាការកំណើនផលិតផលក្នុងស្រុកសរុបចំនួន ៨ ភាគរយឡើងវិញ។

[4] ឧទាហរណ៍នៃការអនុវត្តដែលមិនទាន់សម្រេចល្បឿនដែលបានគ្រោងទុកនោះគឺភាពប្រហាក់ប្រហែលគ្នារវាងសកម្មភាពដែលមាននៅក្នុងផែនការសកម្មភាព ១២ ចំណុចថ្មី សម្រាប់ការសម្របសម្រួលពាណិជ្ជកម្មពីឆ្នាំ ២០១៤ និងឆ្នាំ ២០០៩។

# ប្រធានបទពិសេសទី ១ ៖ វិស័យអង្ករនៅកម្ពុជា

## ១. ការជំរុញ

១. ស្រូវមានសារៈសំខាន់ចំពោះប្រទេសកម្ពុជាជាច្រើនចំណុច។ ផលិតកម្មស្រូវមានចំនួន ១៥ ភាគរយនៃតម្លៃបន្ថែមផ្នែកកសិកម្ម ហើយស្រូវគ្របដណ្តប់ទៅលើ ៧៥ ភាគរយនៃផ្ទៃដីកសិកម្ម។ ផលិតកម្ម ការកែច្នៃ និងការរកទីផ្សារស្រូវ ត្រូវបានប៉ាន់ស្មានថា ផ្តល់ការងារដល់មនុស្សចំនួន ៣ លាននាក់ ដែលជាចំនួនជាង មួយភាគប្រាំនៃចំនួនប្រជាជនសរុបក្នុងប្រទេស។ ក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងមក ការកាត់បន្ថយភាពក្រីក្រចំនួនពាក់កណ្តាល កើតឡើងដោយសារតែកំណើនតម្លៃស្រូវ ផលិតកម្មស្រូវ និងប្រាក់ឈ្នួល នៅកសិដ្ឋាន[5]។ ដោយសារតែសារៈសំខាន់នៃស្រូវ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនគោលនយោបាយស្រូវក្នុងឆ្នាំ ២០១០ ដើម្បីអភិវឌ្ឍវិស័យនេះ ហើយបានកំណត់គោលដៅនាំចេញអង្ករចំនួនមួយលានតោន។ ក្នុងចំណោមសមិទ្ធផលសំខាន់ៗ គឺការបង្កើនផលិតកម្មស្រូវទ្វេដង ពី ៤,៣ លានតោនក្នុងឆ្នាំ ២០០៣ ទៅ ៩,៣ លានតោនក្នុងឆ្នាំ ២០១៣ និងកំណើនការនាំចេញអង្ករជាផ្លូវការ ពី ១២.៦០០ តោន នៅឆ្នាំ ២០០៩ ដល់ ៣៧៨.៨០០ តោនក្នុងឆ្នាំ ២០១៣។ ក៏មានការទទួលស្គាល់កាន់តែច្រើន របស់អន្តរជាតិចំពោះអង្ករក្រអូបកម្ពុជា ដោយក្នុងរយៈពេលពីរឆ្នាំកន្លងមក បានទទួលចំណាត់ថ្នាក់ខ្ពស់បំផុតក្នុងរង្វាន់ពិភពលោក។ ដូច្នេះ ផ្នែកប្រធានបទពិសេសនេះពិនិត្យទៅលើវឌ្ឍនភាពចុងក្រោយនៃផលិតកម្ម ការកែច្នៃ និងការនាំចេញអង្ករ និងផ្តល់អនុសាសន៍មួយចំនួនដើម្បីអភិវឌ្ឍបន្តទៅទៀត។

## ២. ផលិតកម្ម និងការកែច្នៃស្រូវ

២. **កសិដ្ឋានស្រូវភាគច្រើននៅក្នុងប្រទេសកម្ពុជាមានទំហំតូចជាងមួយហិកតា មិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិដីជាផ្លូវការនៅឡើយ និងនៅប្រើមធ្យោបាយបូរាណនៅឡើយ។** លទ្ធភាពទទួលបានឥណទាន មិនត្រូវបានរារាំងខ្លាំង ដោយសារតែការគ្មានប័ណ្ណកម្មសិទ្ធិជាផ្លូវការនោះទេ ព្រោះថាប្លង់ទន់ (លិខិតបញ្ជាក់ពីប្រធានភូមិ ឬប្រធានឃុំ) ត្រូវបានស្ថាប័នហិរញ្ញវត្ថុខ្នាតតូចនៅមូលដ្ឋានទទួលស្គាល់ជារបស់ប្រចាំ។ កសិដ្ឋានតូចៗ ជាច្រើននៅតែប្រើប្រាស់មធ្យោបាយបូរាណ ដោយប្រើប្រាស់ធនធានជំនួយការដាំដុះដែលទិញពីគេតិចតួច។ ប៉ុន្តែ មានកសិករកាន់តែច្រើនឡើងៗ ជាពិសេសអ្នកដែលដាំដុះលើដីទំហំធំពី ២ ទៅ ៥ ហិកតា កំពុងធ្វើទំនើបកម្មផលិតកម្មរបស់ខ្លួនដោយប្រើប្រាស់

រូប គ១.១ ផលិតផលស្រូវនៅកម្ពុជា ឆ្នាំ២០០៨-២០១៣




ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[5] ធនាគារពិភពលោកឆ្នាំ២០១៣ “តើអ្នកក្រីក្រទាំងអស់ទៅណា? ការវាយតម្លៃភាពក្រីក្រនៅកម្ពុជាឆ្នាំ ២០១៣” ការសិក្សារបស់ធនាគារពិភពលោកប្រចាំប្រទេស ខែវិច្ឆិកា ឆ្នាំ ២០១៣

គ្រាប់ពូជល្អៗ ប្រើជី អនុវត្តតាមការដាំដុះកសិកម្មល្អៗ និងប្រើប្រាស់សេវាកម្មគ្រឿងយន្ត[6]។

**៣. ផលិតកម្មស្រូវក្នុងឆ្នាំ២០១៣ របស់កម្ពុជាមានការកើនឡើងបន្តិចបន្តួចបើធៀបនឹងឆ្នាំ២០១២ ទោះបីជាប្រទេសកម្ពុជាទទួលរងការរំខានដោយសារគ្រោះទឹកជំនន់ទន្លេមេគង្គកាលពីឆ្នាំកន្លងមកក៏ដោយ។** ផលិតផលស្រូវសរុបក្នុងឆ្នាំ ២០១៣ មានចំនួនប្រមាណ ៩,៣ លានតោន (រូប គ ១.១) ដែលក្នុងនោះស្រូវប្រមាណ ៧៧ ភាគរយ (៧,២លានតោន) ត្រូវបានដាំដុះក្នុងរដូវវស្សា។ ទិន្នផលជាមធ្យមសម្រាប់ឆ្នាំ២០១៣ គឺ ៣,១២ តោន/ហិកតា គឺ ២,៨ តោន/ហិកតាក្នុងរដូវវស្សា និង ៤,៣៣ តោន/ហិកតា ក្នុងរដូវប្រាំង។ ក្នុងបរិមាណនេះ ស្រូវក្រអូបមានជាង ៣០ ភាគរយ ប្រភេទស្រូវមិនក្រអូបធម្មតាមាន ៣៥ ភាគរយ និងស្រូវអ៊ីអែរដែលផ្តល់ទិន្នផលខ្ពស់មាន ៣០ ភាគរយ។ ជារួមផលិតផលស្រូវក្រអូប និងស្រូវអ៊ីអែរ មានកំណើនខ្ពស់ ចំណែកផលិតផលប្រភេទស្រូវមិនក្រអូបធម្មតាមានការធ្លាក់ចុះ។

**៤. ការជំរុញបន្ថែមឆ្ពោះទៅរកផលិតកម្មអង្ករក្រអូប និងអង្ករសម្រិតដែលមានគុណភាពខ្ពស់ នឹងជួយធានាឲ្យកម្ពុជាអាចបង្កើនការប្រកួតប្រជែងរបស់ខ្លួនបាន។** កង្វះលទ្ធភាពទទួលបានពូជស្រូវមានគុណភាព ចំណេះដឹងស្តីពីបច្ចេកទេសដាំដុះសមស្រប ធាតុចូលដែលមានគុណភាពខ្ពស់ និងសេវាគ្រឿងយន្ត និងប្រព័ន្ធធារាសាស្ត្រ សុទ្ធតែជាឧបសគ្គរាំងដល់ការជំរុញការអភិវឌ្ឍន៍ផលិតកម្មស្រូវ។

**៥. សមត្ថភាពម៉ាស៊ីនកិនស្រូវរបស់កម្ពុជាមានភាពរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងរយៈពេល ៤ ឆ្នាំកន្លងមក។** សមត្ថភាពម៉ាស៊ីនកិនស្រូវដ៏ទំនើបរបស់កម្ពុជា (ឧ. ម៉ាស៊ីនកិនស្រូវធំៗ) បានកើនឡើង ៧ ដង ពី ៩៦ តោនក្នុងមួយម៉ោងក្នុងឆ្នាំ២០០៩ រហូតដល់ជាង ៧០០ តោន/ម៉ោង នាចុងឆ្នាំ២០១៣ (រូប គ ១.២)។ សមត្ថភាពខាត់រំលីងអង្ករក៏មានការកើនឡើងខ្លាំងផងដែរ ដោយបានកើនពី ៧២ តោន/ម៉ោង ក្នុងឆ្នាំ២០០៩ រហូតដល់ ៥៦៤ តោន/ម៉ោង ក្នុងឆ្នាំ២០១៣ ដោយមានអត្រាកិនស្រូវជាមធ្យម ៦៤ ភាគរយ។ វិស័យឯកជនបានវិនិយោគលើម៉ាស៊ីនកិនស្រូវខ្នាតធំទាំងអស់ ហើយយ៉ាងហោចណាស់ ការវិនិយោគ ៣៥ ភាគរយ ជាការចូលហ៊ុនគ្នាជាមួយវិនិយោគិនបរទេស។ តាមទ្រឹស្តី សមត្ថភាពបច្ចុប្បន្នរបស់ម៉ាស៊ីនកិនស្រូវអាចកែច្នៃអតិរេកស្រូវស្ទើរតែទាំងស្រុងក្នុងប្រទេសកម្ពុជា។ យ៉ាងណាក៏ដោយ ការចំណាយខ្ពស់លើឥន្ធនៈ និងអគ្គិសនី បានធ្វើឲ្យថ្លៃកិនស្រូវនៅប្រទេសកម្ពុជាមានតម្លៃខ្ពស់ជាងថ្លៃកិនស្រូវក្នុងប្រទេសថៃ និងប្រទេសវៀតណាមប្រមាណ ៣០ ភាគរយ។ ជាងនេះទៀត ម៉ាស៊ីនកិនស្រូវខ្វះខាតមូលធនចរន្តសម្រាប់ទិញស្រូវទុក។

## ៣. ការនាំចេញអង្ករ

**៦. ការនាំចេញអង្ករក្នុងឆ្នាំ ២០១៣ ត្រូវបានប៉ាន់ស្មានថាមាន ១,៥ លានតោន** ដែលក្នុងនោះអង្ករ ៣៧៨.៨៥០ តោនត្រូវបាននាំចេញតាមច្រកផ្លូវការ។ បរិមាណអង្ករនាំចេញតាមច្រកផ្លូវការស្ទើរតែពាក់កណ្តាល (៤៧ ភាគរយ) គឺជាអង្ករក្រអូប។ ក្រៅពីនោះ មានការនាំចេញស្រូវតាមច្រកក្រៅផ្លូវការ តាមរយៈទំនាក់ទំនងពាណិជ្ជកម្មតាមព្រំដែនជាមួយពាណិជ្ជករជនជាតិថៃ និងវៀតណាម។ នៅឆមាសទីមួយក្នុងឆ្នាំ២០១៤ ពេលដែលកំណើនការនាំចេញស្រូវក្រៅផ្លូវការរក្សាបាននូវកំណើនដូចធម្មតា កំណើនការនាំចេញអង្ករផ្លូវការនៅទ្រឹង បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ។

**៧. ការនាំចេញអង្ករផ្លូវការក្នុងឆ្នាំ ២០១៣ មានចំនួនច្រើនជាងឆ្នាំ២០១២ ប្រមាណ ៨៤ ភាគរយ** និងច្រើនជាងបីដងនៃបរិមាណក្នុងឆ្នាំ ២០១០ ដែលសម្រេចបានប្រមាណ ៧៥ ភាគរយនៃគោលដៅឆ្នាំ ២០១៣ ដែលមានចំនួន ០,៥ លានតោន។ នៅពេលដែលសហភាពអឺរ៉ុប (EU) នៅតែជាទីផ្សារចម្បងនៃបរិមាណនាំចេញអង្ករប្រមាណ ៦៣ ភាគរយ កម្ពុជាបានពង្រីកទីផ្សារ

[6] ធនាគារពិភពលោក ឆ្នាំ២០១៤ "កសិកម្មកម្ពុជាកំពុងប្រែប្រួលៈ កាលានុវត្តភាព និងហានិភ័យ" ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤



ប្រភព ៖ ការសិក្សារបស់ធនាគារពិភពលោក ឆ្នាំ២០១៣

រូប គ១.២ កំណើនសមត្ថភាពកិន និងខាត់រំលីងអង្ករបស់ម៉ាស៊ីនកិនស្រូវខ្នាតធំ ឆ្នាំ ២០០៩-២០១៣ (តោន/ម៉ោង)




ប្រភព ៖ ការសិក្សារបស់ធនាគារពិភពលោកឆ្នាំ២០១៣

អង្កររបស់ខ្លួនទៅកាន់បណ្តាប្រទេសមួយចំនួន ក្នុងទ្វីបអាស៊ី និងអាហ្វ្រិក (រូប គ ១.៣)។ យ៉ាងណាក៏ដោយ ការ ពន្លឿនការនាំចេញអង្ករផ្លូវការរបស់កម្ពុជាមិនមានស្ថិរភាពឡើយ ដោយសារតែតម្លៃអង្កររបស់កម្ពុជាមិនសូវមានលទ្ធភាពប្រកួតប្រជែងនោះទេ ធៀបនឹងប្រទេសវៀតណាម ហើយការពង្រីកទីផ្សាររបស់ប្រទេសនេះធ្វើឡើង ក្នុងអំឡុងពេលដែលការនាំចេញអង្កររបស់ថៃ បានធ្លាក់ចុះប៉ុណ្ណោះ។ បរិមាណនៃការនាំចេញអង្ករផ្លូវការ នាអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៤ ប្រហាក់ប្រហែលទៅនឹងឆ្នាំ ២០១៣ ប៉ុន្តែបរិមាណអង្ករដែលនាំចេញទៅទីផ្សារអឺរ៉ុបមានការកើនឡើងយ៉ាងខ្លាំង។

រូប គ១.៣ ការនាំចេញអង្កតាមប្រព័ន្ធ EBA ទៅកាន់សហភាពអឺរ៉ុប គិតជាតោន ឆ្នាំ២០០៥/០៦-២០១២/១៣




ប្រភព ៖ សហភាពអឺរ៉ុប

## ៤. នីតិវិធីនាំចេញអង្ករ និងភស្តុភារ

៨. **នីតិវិធីនាំចេញអង្កររបស់កម្ពុជាត្រូវបានកែសម្រួលដោយការបង្កើតលេខាធិការដ្ឋានសេវាច្រកចេញចូលតែមួយសម្រាប់ការនាំចេញអង្ករ (SOW-REF)។** នៅមានចំណុចមួយចំនួនដែលត្រូវកែលម្អបន្ថែមទៀត (តារាង គ ១.១) ទោះបីជាមានការកាត់បន្ថយរយៈពេល និងចំណាយយ៉ាងច្រើន ក្នុងការទទួលបានការអនុញ្ញាតក៏ដោយ។ ការប្តេជ្ញាចិត្ត និងកំណែទម្រង់បច្ចុប្បន្នរបស់ក្រសួងពាក់ព័ន្ធមួយចំនួនលើបញ្ហានេះ គឺជាការល្អ។

តារាង គ១.១ នីតិវិធី ពេលវេលា និងចំណាយលើការនាំចេញអង្ករនៅកម្ពុជា ឆ្នាំ២០១២ និង ២០១៣

| សេវា | ចំណាយលើការដំណើរការ | | រយៈពេលដំណើរការ | |
|---|---|---|---|---|
| | ២០១២ | ២០១៣ | ២០១២ | ២០១៣ |
| លិខិតបញ្ជាក់ អនាម័យ និងភូត្តគាមអនាម័យ | ១៥០ ដុល្លា/កេស | ៣៥ ដុល្លា/កេស | ២ ថ្ងៃ | ១ ថ្ងៃ |
| លិខិតបញ្ជាក់ការត្តុងផ្សេង | ២០ ដុល្លា/ កុងតឺន័រ | ៣៥ ដុល្លា/ កុងតឺន័រ | ១ ថ្ងៃ | ១ ថ្ងៃ |
| វិញ្ញាបនបត្រប្រភពទំនិញ | ២៥០ដុល្លា/កេស | ១៩១ ដុល្លា/កេស | ១ ថ្ងៃ | ១ ថ្ងៃ |
| លិខិតបញ្ជាក់គយ | ២៥ ដុល្លា/ កុងតឺន័រ | ៦,៥ ដុល្លា/ កុងតឺន័រ | ២ ថ្ងៃ | កន្លះថ្ងៃ |
| លិខិតបញ្ជាក់កាំកុងត្រូល | ២៥ ដុល្លា/ កុងតឺន័រ | ៥២,៥ ដុល្លា/ កុងតឺន័រ | ២ ថ្ងៃ | កន្លះថ្ងៃ |
| លិខិតបញ្ជាក់សារធាតុសរីរាងកៃច្នៃ (GMO) | ១៥០ដុល្លា/ច្បាប់ | ៨០ ដុល្លា/ច្បាប់ | ៣-៤ ថ្ងៃ | ២-៣ថ្ងៃ |
| **សរុបមធ្យម*** | **២០ ដុល្លា/តោន** | **១៤ ដុល្លា/តោន** | **៨ ថ្ងៃ** | **៤ ថ្ងៃ** |

ប្រភព៖ តួលេខប៉ាន់ស្មានរបស់ក្រុមធនាគារពិភពលោក ផ្អែកលើព័ត៌មានរបស់ក្រុមហ៊ុននាំចេញអង្ករសំខាន់ៗ និង SOWS-REF

*សម្រាប់ការនាំចេញខ្នាតធំ កម្រៃសេវាជាមធ្យមក្នុងមួយតោនគឺទាបជាង

៩. **ការនាំចេញអង្ករក្រៅផ្លូវការរបស់កម្ពុជាទៅកាន់ប្រទេសវៀតណាម និងថៃ តាមរយៈការធ្វើពាណិជ្ជកម្មតាមព្រំដែន។** ភាគីពាក់ព័ន្ធទាំងអស់សុទ្ធតែបានដឹងពីពាណិជ្ជកម្មក្រៅផ្លូវការនេះ ប៉ុន្តែមិនទាន់មានការកំណត់ច្បាស់ពីបរិមាណជាក់លាក់នៅឡើយ។ មានការជឿថា ស្រូវជាង ១,៧ លានតោនត្រូវបាននាំចេញទៅប្រទេសវៀតណាមក្នុងឆ្នាំ ២០១៣ ចំណែកស្រូវប្រមាណ ០,២៥ លានតោន និងអង្ករមានគុណភាពអន់ប្រមាណ ០,៣ លានតោន ត្រូវបាននាំចេញទៅប្រទេសថៃ។ មូលហេតុចម្បងនៃលំហូរក្រៅផ្លូវការនេះគឺកង្វះដើមទុនដំណើរការរបស់ម្ចាស់ម៉ាស៊ីនកិនស្រូវ និង

ពាណិជ្ជករក្នុងប្រទេស។ ការនាំចេញក្រៅផ្លូវការក៏បានផ្តល់ផលវិជ្ជមានផងដែរ ដោយការនាំចេញនេះបានផ្តល់ទីផ្សារដែលមានស្ថិរភាព ការផ្ទេរបច្ចេកទេសនិងការលើកទឹកចិត្តដល់កសិករ ទោះបីជាកម្ពុជាបានទទួលតម្លៃបន្ថែមតិចតួចក៏ដោយ។

**១០. ហេដ្ឋារចនាសម្ព័ន្ធ និងភស្តុភាររបស់កម្ពុជាមានភាពរីកចម្រើន ប៉ុន្តែមិនទាន់អាចសម្រួលដល់ការនាំចេញអង្ករបានទាំងស្រុងនៅឡើយទេ។** ប្រទេសកម្ពុជាស្ថិតក្នុងលំដាប់ទី ៨៣ ក្នុងសន្ទស្សន៍ស្តីពីដំណើរការភស្តុភារឆ្នាំ ២០១៤ ដោយរំកិលឡើងបាន ៤៦ លេខ ពីឆ្នាំ២០១០ ហើយនេះជាកំណើនដែលគួរឲ្យកត់សម្គាល់ បើទោះបីជាកម្ពុជាស្ថិតនៅលំដាប់ក្រោមប្រទេសថៃ និងវៀតណាម (តារាង គ ១.២)ក៏ដោយ។ ចំណាយលើការដឹកជញ្ជូនតាមផ្លូវគោកក្នុងមួយកុងតឺន័រ បានធ្លាក់ចុះចំនួន ១៥ ភាគរយ ប៉ុន្តែតម្លៃដឹកជញ្ជូនគិតជាគីឡូម៉ែត្រនៅតែថ្លៃជាងពាក់កណ្តាលជាងតម្លៃនៅប្រទេសវៀតណាម។ ជាក់ស្តែង រាល់ការនាំចេញអង្ករផ្លូវការរបស់កម្ពុជា ត្រូវដឹកជញ្ជូនតាមកុងតឺន័រ ដែលជាមធ្យោបាយមួយធ្វើឲ្យកម្ពុជារងការខាតបង់។ ចំណុចនេះក៏មានភាពផ្ទុយទៅនឹងនិន្នាការពិភពលោកដែរ។ នៅលើពិភពលោក អង្ករមិនក្រអូប និងអង្ករក្រអូបមួយភាគបី ត្រូវបាននាំចេញជាទំនិញបរិមាណច្រើនរួម។ ដំណាក់កាលដំបូងនៃការពង្រីកកំពង់ផែស្វយ័តក្រុងភ្នំពេញ បានបញ្ចប់រួចរាល់ ហើយកំពង់ផែនេះបានចាប់ផ្តើមដំណើរការកាលពីដើមឆ្នាំ ២០១៣ ចំណែកសមត្ថភាពរបវន្តរបស់កំពង់ផែសមុទ្រកំពុងត្រូវបានបង្កើន។ ការសាងសង់ផ្លូវដែកឡើងវិញដែលមានប្រវែង ២៥៦ គីឡូម៉ែត្រតភ្ជាប់ពីក្រុងភ្នំពេញទៅ កំពង់ផែក្រុងព្រះសីហនុបានបញ្ចប់រួចរាល់ ប៉ុន្តែចាំបាច់ត្រូវមានការកែលម្អរចនាសម្ព័ន្ធផ្លូវដែកនេះបន្ថែមទៀត ដើម្បីសម្រួលដល់ការនាំចេញ អង្ករ។

**តារាង គ១. ២** សន្ទស្សន៍ស្តីពីដំណើរការភស្តុភានៅកម្ពុជា ធៀបនឹងប្រទេសជិតខាង ឆ្នាំ២០១០-២០១៤

| ចំណាត់ថ្នាក់ភស្តុភារក្នុងសន្ទស្សន៍ស្តីពីដំណើរការភស្តុភារ ឆ្នាំ២០១៤ | | | |
|---|---|---|---|
| | 2010 | 2012 | 2014 |
| ថៃ | | 38 | 35 |
| វៀតណាម | | 53 | 48 |
| កម្ពុជា | 129 | 101 | 83 |
| មីយ៉ាន់ម៉ា | | 129 | 145 |

ប្រភព ៖ ធនាគារពិភពលោក

**រូប គ១.៤** តម្លៃអង្កររបស់បណ្តាប្រទេសក្នុងទ្វីបអាស៊ី ឆ្នាំ២០០៦-២០១៣ គិតជាដុល្លា/តោន



ប្រភព ៖FAO GIEWS.

*ចំណាំ ៖ តម្លៃចម្រុះនៃការលក់ដុំអង្ករនៅកម្ពុជា ប្រទេសថៃ* នៅពេលនាំចេញ *៥ ភាគរយ ប្រទេសវៀតណាម* នៅពេលនាំចេញ *៥ ភាគរយ។*

## ៥. តម្លៃអង្ករ

**១១. តម្លៃអង្ករក្នុងប្រទេសកម្ពុជាកំពុងឡើងចុះតាមតម្លៃអង្ករក្នុងប្រទេសថៃ និងវៀតណាម** (រូប ១.៤)។ កាលពីឆ្នាំ ២០១៣ និងដើមឆ្នាំ ២០១៤ តម្លៃស្រូវរបស់កម្ពុជាទទួលរងឥទ្ធិពលពី តម្លៃស្រូវក្នុងប្រទេសវៀតណាមជាជាងប្រទេសថៃ។ តម្លៃស្រូវនៅកសិដ្ឋានក្នុងឆ្នាំ២០១៣ ប្រហាក់ប្រហែលនឹងឆ្នាំ ២០១១ និង ២០១២ និងទាបជាងតម្លៃស្រូវក្នុងប្រទេសជិតខាង។ ជារឿយៗចំណាយលើការដឹកជញ្ជូនបានធ្វើឲ្យតម្លៃស្រូវនៅកសិដ្ឋានតាមតំបន់ឆ្ងាយៗធ្លាក់ចុះ ខណៈពេលដែលស្រូវមិនក្រអូប

ដែលមានគុណភាពល្អ ងាយប្រឈមនឹងការប្រែប្រួលតាមរដូវកាលជាងពូជស្រូវផ្សេងទៀត។ តម្លៃស្រូវនៅកសិដ្ឋានសម្រាប់ស្រូវក្រអូបកម្ពុជាក្នុងឆ្នាំ២០១៣ មានលក្ខណៈថេរពេញមួយឆ្នាំ ដោយមានតម្លៃប្រមាណ ២៧០ ដុល្លា/តោន និងទាបជាងតម្លៃក្នុងប្រទេសវៀតណាម។ តម្លៃស្រូវក្នុងប្រទេសថៃមានអត្រាខ្ពស់ជាង ប៉ុន្តែបានធ្លាក់ចុះកាលពីខែធ្នូ ឆ្នាំ២០១៣ និងឆមាសទី១ ក្នុងឆ្នាំ ២០១៤។

**១២. លំនាំពាណិជ្ជកម្មអង្ករក្នុងតំបន់នាឆ្នាំ២០១៣ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងឆ្នាំ២០១២ ប៉ុន្តែមានការប្រែប្រួលមួយចំនួន។** បរិមាណនៃការនាំចេញអង្ករសរុបរបស់ប្រទេសវៀតណាមក្នុងឆ្នាំ ២០១៣ ទាបជាងឆ្នាំ២០១២ ប្រមាណ ១៣ ភាគរយ ទោះបីជាសម្រង់តម្លៃអង្កររបស់ប្រទេសនេះតែងទាបជាងគេក្នុងតំបន់ក៏ដោយ។ និន្នាការនេះបានបន្តក្នុងឆ្នាំ ២០១៤ នៅពេលដែលការនាំចេញអង្កររបស់ប្រទេសវៀតណាមក្នុងអំឡុងពេលឆមាសទីមួយក្នុងឆ្នាំ២០១៤ (៣,៦២ លានតោន) បានធ្លាក់ចុះ ១២ ភាគរយ ធៀបនឹងឆ្នាំ២០១៣ (៤,១ លានតោន)។ ទីផ្សារអង្កររបស់ប្រទេសថៃរងផលប៉ះពាល់ដោយសារគម្រោងកិច្ចសន្យាអង្កររបស់ខ្លួនដែលបានបញ្ឈប់ក្នុងឆ្នាំ ២០១៤ និងកំពុងព្យាយាមបន្តការនាំចេញរបស់ខ្លួនក្នុងឆ្នាំ ២០១៤។ តាមរយៈកំណែទម្រង់បច្ចុប្បន្នរបស់ខ្លួន ប្រទេសមីយ៉ាន់ម៉ាកំពុងស្ថិតក្នុងដំណាក់កាលស្តារឡើងវិញ ដើម្បីចូលក្នុងទីផ្សារអង្ករពិភពលោក ហើយត្រូវបានជំរុញដោយការអនុញ្ញាតឲ្យនាំចេញ "អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ" ទៅសហភាពអឺរ៉ុប។ ប្រទេសឥណ្ឌានៅតែជាប្រទេសនាំចេញអង្ករឈានមុខគេក្នុងពិភពលោក។

## ៦. សេចក្តីសន្និដ្ឋាន

**១៣. កំណើនផលិតកម្មស្រូវដែលមានល្បឿនយឺតជាងមុនក្នុងឆ្នាំ ២០១៣ បង្ហាញពីសារៈសំខាន់ក្នុងការកែលម្អវិស័យស្រូវ ដើម្បីធ្វើឲ្យវិស័យនេះក្លាយជាម៉ាស៊ីនជំរុញកំណើន ផសស វិញ។** ដោយសារតែបញ្ហាផ្ទៃដីដាំដុះមានកម្រិត កំណើនផលិតកម្មស្រូវនាពេលអនាគតនឹងអាស្រ័យសំខាន់ទៅលើកំណើនផលិតភាព និងគុណភាពជាងការពង្រីកផ្ទៃដីដាំដុះ។

**១៤. ទោះបីជាទីផ្សារនាំចេញអង្ករមានកាន់តែច្រើនឡើង និងកំណើនទីផ្សារជាគោលដៅ ការចំណាយខ្ពស់ទៅលើការកិនស្រូវ និងដឹកជញ្ជូននៅកម្ពុជា បានធ្វើឲ្យមានការបាត់បង់ការប្រកួតប្រជែងនៃតម្លៃផលិតផលនៅកសិដ្ឋាន។** រូប គ ១.៥ បង្ហាញពីស្ថានភាពនេះ ដោយប្រៀបធៀបតម្លៃអង្ករកម្ពុជានៅកសិដ្ឋាន នៅម៉ាស៊ីនកិនស្រូវ និងនៅពេលនាំចេញ ជាមួយនឹងនៅប្រទេសវៀតណាម និងប្រទេសថៃ។

**រូប គ.១.៥ តម្លៃអង្ករសក្នុងមួយតោននៅក្នុងឆ្នាំ ២០១៣ នៅកសិដ្ឋានម៉ាស៊ីនកិន និងពេលនាំចេញ**




ប្រភព៖ ការគណនារបស់បុគ្គលិកធនាគារពិភពលោកផ្អែកលើឯកសារត្រួតពិនិត្យអង្ករឆ្នាំ ២០១៤

## ប្រធានបទពិសេសទី ២ ៖ ការបង្កើតភាពងាយស្រួលសម្រាប់ក្រុមហ៊ុននៅកម្ពុជា ៖ លទ្ធផលរកឃើញពីការវាយតម្លៃចុងក្រោយលើបរិយាកាសវិនិយោគ

### ១. ការជំរុញ

១. **យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទីបី ដែលមានរយៈពេល ៥ ឆ្នាំ បានបន្តផ្តល់អាទិភាពដល់ការជំរុញបរិយាកាសធុរកិច្ចដើម្បីធ្វើពិពិធកម្ម និងបង្កើនតម្លៃបន្ថែមក្នុងផលិតកម្ម។** ប្រទេសកម្ពុជាចាប់ផ្តើមទទួលបានការវិនិយោគផ្ទាល់ពីបរទេសឡើងវិញបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកល។ កត្តាទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស រួមមាន ប្រាក់ឈ្នួលទាប ការបើកទូលាយ ការអនុគ្រោះពន្ធនាំចូល "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ" ទៅកាន់សហភាពអឺរ៉ុប និងការរួចពន្ធ ដែលអាចប៉ះប៉ូវការចំណាយខ្ពស់លើការធ្វើធុរៈកិច្ចក្នុងប្រទេស។ វិស័យកម្មន្តសាល និងការនាំចេញ នៅតែជាវិស័យសំខាន់នាំមុខគេ ទោះបីជាមានការវិនិយោគផ្ទាល់ពីបរទេស និងសញ្ញាមួយចំនួននៃពិពិធកម្ម (ដូចជា ការបង្កើតក្រុមហ៊ុនជប៉ុនសម្រាប់ផលិតគ្រឿងបន្លាស់ និងបរិក្ខារអគ្គិសនី) ក៏ដោយ។ ការដោះស្រាយឧបសគ្គចម្បងៗក្នុងបរិយាកាសធុរកិច្ច នឹងជួយជំរុញការវិនិយោគពីបរទេស និងការវិនិយោគក្នុងប្រទេសក្នុងវិស័យថ្មីៗដែលជំរុញពិពិធកម្ម និងបង្កើនតម្លៃបន្ថែមក្នុងផលិតកម្ម។

### ២. វឌ្ឍនភាព និងឧបសគ្គដែលនៅតែមាន

២. **មានវឌ្ឍនភាពសំខាន់ច្រើននៅក្នុងការសម្របសម្រួលពាណិជ្ជកម្មក្នុងរយៈពេលបួនឆ្នាំកន្លងមក។** ការសន្និដ្ឋាននេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងខ្លាំងនៃចំណាត់ថ្នាក់របស់ប្រទេសកម្ពុជាពាក់ព័ន្ធនឹងសន្ទស្សន៍ស្តីពីដំណើរការភស្តុភារ ដែលធនាគារពិភពលោកបានធ្វើ។ ប្រទេសកម្ពុជាបានឈានមកត្រឹមលំដាប់ទី ៨៣ ដោយឡើងពីលេខរៀងទី ១២៩ នៃសន្ទស្សន៍ស្តីពីដំណើរការភស្តុភារក្នុងឆ្នាំ២០១០ ដោយរំកិលបាន ៤៦ លេខ។ រយៈពេលនៃការបំពេញបែបបទគយបានបន្ថយពី ៥,៩ ថ្ងៃក្នុងឆ្នាំ២០១០ មកត្រឹម ១,៤ ថ្ងៃក្នុងឆ្នាំ២០១៤ ខណៈពេលដែលភាគរយនៃការបញ្ជូនទំនិញសំខាន់ៗសម្រាប់ការត្រួតពិនិត្យ បានធ្លាក់ពី ២៩ ភាគរយក្នុងឆ្នាំ២០១០ មកត្រឹម ១៧ ភាគរយក្នុងឆ្នាំ២០១៤។

៣. **ទោះបីមានវឌ្ឍនភាពយ៉ាងនេះក៏ដោយ បរិយាកាសធុរៈកិច្ចនៅតែបន្តរាំងស្ទះដល់ការប្រកួតប្រជែងរបស់ក្រុមហ៊ុននៅកម្ពុជា ដូចមានបង្ហាញក្នុងការវាយតម្លៃនៅពេលខាងមុខលើបរិយាកាសវិនិយោគ (ICA) របស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងឆ្នាំ២០១៤។** ឧបសគ្គចម្បងៗរបស់ក្រុមហ៊ុនក្នុងរបាយការណ៍ការវាយតម្លៃបរិយាកាសវិនិយោគ មានបង្ហាញក្នុងរូប គ ២.១។

- **ក្រុមហ៊ុននានាបានបញ្ជាក់ថា បច្ចុប្បន្នអគ្គិសនីគឺជាឧបសគ្គចម្បងទីមួយដែលរារាំងដល់បរិយាកាសធុរៈកិច្ច។** ការព្រួយបារម្ភអំពីបញ្ហាអគ្គិសនីមានចំនួនកើនឡើងទ្វេរដង បើធៀបនឹងឆ្នាំ ២០០៧។ អគ្គិសនីមិនត្រឹមតែមានតម្លៃថ្លៃជាង បណ្តាប្រទេសផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការផ្គត់ផ្គង់មិនមានប្រសិទ្ធភាព និងមិនជាប់លាប់។ ការបាត់បង់ថាមពលអគ្គិសនីនៅពេលបញ្ជូន និងចែកចាយនៅកម្ពុជា ដោយធៀបនឹងភាគរយនៃបរិមាណអគ្គិសនីសរុប មានចំនួនខ្ពស់ជាងប្រទេសផ្សេងៗដែលបានប្រៀបធៀប។ លើសពីនេះទៀតបរិមាណបាត់បង់ថាមពលនេះក៏បានកើនឡើងទ្វេរដងបើប្រៀបនឹងឆ្នាំ២០១៤។ រោងចក្រផលិតភាគច្រើន ត្រូវប្រើប្រាស់ម៉ាស៊ីនភ្លើង ដើម្បីបំពេញតម្រូវការថាមពលរបស់ខ្លួន។ បញ្ហានេះមានភាពធ្ងន់ធ្ងរនៅតំបន់តាមតំបន់ព្រំដែន ដែលមានតំបន់សេដ្ឋកិច្ចពិសេស។ ទោះជារាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែងបង្កើនប្រភពផ្គត់ផ្គង់អគ្គិសនី តាមរយៈការផលិត

អត្តិសនីក្នុងប្រទេស (វារីអគ្គិសនី) និងការនាំចូលអគ្គិសនីពីក្រៅប្រទេសនោះក្តី ក៏នៅមិនទាន់មានភាពច្បាស់លាស់ថាតើ អគ្គិសនីនឹងត្រូវផ្តល់ឲ្យប្រើប្រាស់ក្នុងតម្លៃសមស្រប ជាងមុនដល់វិស័យកម្មន្តសាលក្នុងរយៈពេលដ៏ខ្លី ឬយ៉ាងណានោះឡើយ។

រូប គ២.១




ប្រភព ៖ ការវាយតម្លៃបរិយាកាសវិនិយោគ ឆ្នាំ២០១៤

- **ការបង់ប្រាក់ក្រៅផ្លូវការនៅតែត្រូវបានមើលឃើញថា ជាឧបសគ្គចម្បងទីបីសម្រាប់ក្រុមហ៊ុនទាំងអស់ បន្ទាប់ពីភាពមិនប្រកដប្រជានៃម៉ាក្រូសេដ្ឋកិច្ច**[7] **និង ជាឧបសគ្គចម្បងទីពីរសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជី។** ការបង់ប្រាក់ក្រៅផ្លូវការនៅតែបន្តកើតមាននៅកម្ពុជា។ បើទោះ ជាបរិមាណនៃការបង់ប្រាក់ក្រៅផ្លូវការមានការថយចុះ បើធៀបនឹងប្រាក់បានពីការលក់ ការអនុវត្តនៃការបង់ប្រាក់ក្រៅផ្លូវការមិនបានថយចុះទេ ដែលអាចមានន័យថា ទោះជាមន្ត្រីអាចទារប្រាក់មិនសូវញឹកញាប់ដូចមុន តែភាគរយក្រុមហ៊ុនដែលបង់ប្រាក់នេះ មិនចុះឡើយ(ហើយមានសញ្ញាជាច្រើនបញ្ជាក់ថា ចំពោះសកម្មភាពមួយចំនួន ដូចជា ការនាំចូលទំនិញ ចំនួនក្រុមហ៊ុនដែលបង់ប្រាក់នៅពេលធ្វើការអង្កេតនោះ បានកើនឡើង)។ ផ្ទុយទៅវិញ ការបង់ប្រាក់ក្រៅផ្លូវការ ក៏ដូចជាការស៊ីសំណូកដែរ នៅប្រទេសឡាវ ត្រូវបានយល់ឃើញថា ថយចុះក្នុងចំណោមឧបសគ្គចម្បងនៅចន្លោះពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១២ (កាលបរិច្ឆេទនាំការវាយតម្លៃបរិយាកាសវិនិយោគថ្មីនេះ)។
- **ការអនុវត្តដោយគ្មានការប្រកួតប្រជែង ដែលពាក់ព័ន្ធខ្លាំងនឹងការបង់ប្រាក់ក្រៅផ្លូវការ គឺជាឧបសគ្គចម្បងទីប្រាំ បន្ទាប់ពីការដឹកជញ្ជូន។** កម្រិតវិស័យក្រៅផ្លូវការក្នុងប្រទេសកម្ពុជា នៅតែមានកម្រិតខ្ពស់នៅឡើយ។ មានការមើលឃើញថា ក្រុមហ៊ុនក្រៅផ្លូវការ នឹងទទួលបានអត្ថប្រយោជន៍លើសពីក្រុមហ៊ុនផ្លូវការ និងប្រឈមតិចតួចទៅនឹងឧបសគ្គផ្នែកច្បាប់ក្នុងការធ្វើធុរៈកិច្ច។ ផល ប្រយោជន៍នៃការប្រកួតប្រជែងនេះ បានរារាំងមិនឲ្យក្រុមហ៊ុនផ្លូវការ ធ្វើប្រតិបត្តិការលើមូលដ្ឋានស្មើភាពគ្នាឡើយ។ ឧបសគ្គផ្សេងៗដែលនៅបន្តមាន ហើយត្រូវបានកំណត់ឃើញនៅក្នុងការអង្កេតការវាយតម្លៃបរិយាកាស វិនិយោគ ដោយឧបសគ្គទាំងនេះបានចូលជ្រៅទៅក្នុងវប្បធម៌ធុរកិច្ចក្នុងប្រទេស ហើយជាបញ្ហាប្រឈមសម្រាប់អ្នកតាក់តែងគោលនយោបាយ ត្រូវដោះស្រាយ និងចាត់វិធានការកាត់បន្ថយ។ ដោយមិនព្យាយាមដាក់សម្ពាធទៅលើសកម្មភាពក្រៅផ្លូវការទាំងនេះ រដ្ឋាភិបាលអាចពិចារណាជំរុញឲ្យក្រុមហ៊ុនក្នុងវិស័យក្រៅផ្លូវការរីកចម្រើន ដោយអនុម័តគោលនយោបាយល្អៗមួយចំនួន ដូចជា ការផ្តល់ការលើកទឹកចិត្ត ឲ្យប្រែក្លាយទៅជាក្រុមហ៊ុនផ្លូវការដែលអាចរួមទាំង ដំណើរការចុះបញ្ជី ការផ្តល់អាជ្ញាប័ណ្ណ និងការអនុម័តបានលឿន ដែលកត្តាទាំងនេះជួយបង្កើនចំណូលសារពើពន្ធ ផ្តល់ប្រាក់ឈ្នួលខ្ពស់ដល់កម្មករនិយោជិត និងផ្ទេរចំណេះដឹងល្អប្រសើរ។

៤. **ក្រៅពីការបង្ហាញឧបសគ្គចម្បងៗមួយចំនួន ការវិភាគបរិយាកាសវិនិយោគ បានផ្តល់ការរកឃើញសំខាន់ៗចំនួនពីរ។ ការរកឃើញទីមួយគឺ តំបន់សេដ្ឋកិច្ចពិសេស មិនបានផ្តល់អត្ថប្រយោជន៍តាមការរំពឹងទុករបស់ វិនិយោគិនបរទេសឡើយ។** ទោះបីជាតំបន់នេះបានផ្តល់អត្ថប្រយោជន៍ជាច្រើន ដូចជា ការិយាល័យ

[7] ការកំណត់ភាពមិនប្រាកដប្រជានៃម៉ាក្រូសេដ្ឋកិច្ច ថាជាឧបសគ្គសំខាន់ ធ្វើឲ្យមានភាពភ្ញាក់ផ្អើល។ អាចរួមទាំងបរិយាកាសម៉ាក្រូសេដ្ឋកិច្ចខាងក្រៅដែលមិនច្បាស់លាស់បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុពិភពលោក។

ច្រកចេញចូលតែមួយ និងការកែលម្អនីតិវិធីការបំពេញបែបបទតាមព្រំដែនក៏ដោយ វិនិយោគិននៅតែសំដែងការខកចិត្ត និងគិតថា បរិយាកាសវិនិយោគអំណោយផលក្នុងតំបន់ទាំងនោះ មិនត្រូវបានបំពេញឲ្យឡើយ។

**៥. ការរកឃើញសំខាន់ទីពីរគឺ "អវត្តមានក្រុមហ៊ុនខ្នាតមធ្យម" ក្នុងចំណោមក្រុមហ៊ុននាំចេញនៅកម្ពុជា។** តាមរយៈការប្រៀបធៀបជាមួយ បណ្តាប្រទេសដែលមានកម្រិតផលិតផលក្នុងស្រុកដូចគ្នា មានសហគ្រាសខ្នាតមធ្យមតិចតួចប៉ុណ្ណោះ ដែលបាននាំចេញទំនិញយ៉ាងសកម្មពីកម្ពុជា។ អវត្តមានក្រុមហ៊ុនខ្នាតមធ្យមអាចពាក់ព័ន្ធនឹងបរិយាកាសធុរៈកិច្ចចំណាយច្រើន ដែលផ្តល់ភាពអនុគ្រោះដល់អាជីវកម្មខ្នាតធំ និងធ្វើឲ្យក្រុមហ៊ុនខ្នាតតូចមិនអាចពង្រីកខ្លួនបាន និងមានលក្ខណៈក្រៅផ្លូវការដើម្បីគេចពីផ្លូវច្បាប់។

**៦. អំឡុងពេលនៃកំណើនដ៏ខ្លាំងក្លាបច្ចុប្បន្ន គឺជាកាលានុវត្តភាពសម្រាប់កែលម្អបរិយាកាសធុរកិច្ចដែលអាចទាក់ទាញវិនិយោគិនរយៈពេលវែង។** វិនិយោគិនជាច្រើនសុទ្ធតែចាប់អារម្មណ៍នឹងគម្រោង "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ" ដែលអនុញ្ញាតឲ្យមានការនាំចេញទំនិញទៅកាន់ទីផ្សារសហភាពអឺរ៉ុបដោយរួចពន្ធ ប៉ុន្តែការអនុគ្រោះទាំងនេះ មិនមានរយៈពេលយូរអង្វែងនោះឡើយ។ ការកែលម្អបរិយាកាសវិនិយោគបច្ចុប្បន្ន នឹងធានាការវិនិយោគប្រកបដោយ ស្ថិរភាពក្នុងប្រទេសកម្ពុជា នៅពេលដែលការអនុគ្រោះទាំងនោះផុតកំណត់។

## ៣. សំណើអំពីជំហានបន្ទាប់សម្រាប់កំណែទម្រង់បរិយាកាសធុរៈកិច្ច

**ក. ដោះស្រាយបញ្ហាការចំណាយខ្ពស់លើថ្លៃអគ្គិសនី** ដោយមានផែនការជាតិទូលំទូលាយ ដែលមានការពិនិត្យឡើងវិញលើប្រភពថាមពល (រួមទាំងថាមពលកើតឡើងវិញ) និងកំណត់ការអនុវត្តជាក់លាក់ (ឧទាហរណ៍ កិច្ចព្រមព្រៀងជាវថាមពលដែលមិនមានតម្លាភាព) ដែលអាចធ្វើឲ្យចំណាយខ្ពស់លើថ្លៃអគ្គិសនី។ ការកែលម្អកិច្ចព្រមព្រៀងមានស្រាប់ជាមួយ បណ្តាប្រទេសជិតខាង នឹងធានានូវការផ្គត់ផ្គង់អគ្គិសនីប្រកបដោយនិរន្តរភាព និងអាចជឿជាក់បាន ដល់តំបន់សេដ្ឋកិច្ចពិសេសដែលមានទីតាំងនៅក្បែរព្រំដែន កម្ពុជា។ វិធីសាស្រ្តថ្នាក់តំបន់ ក្នុងការដោះស្រាយឧបសគ្គដែលជួបប្រទះនាពេលបច្ចុប្បន្នក្នុងវិស័យថាមពល អាចមានភាពសមស្រប ព្រោះថាការពង្រីកវិស័យថាមពលដោយឡែកអាចនឹងតម្រូវ ឲ្យមានការថ្លឹងថ្លែងយ៉ាងលំបាករវាងកំណើនសេដ្ឋកិច្ច និងបញ្ហា បរិស្ថាន។

**ខ. ធ្វើស្វ័យប្រវត្តិកម្មនីតិវិធីរបស់រដ្ឋាភិបាល ៖** អំពើពុករលួយ និងការអនុវត្តក្រៅផ្លូវការ មានការរីករាលដាលក្នុងស្ថានភាពមិនមានតម្លាភាព ដែលជារឿយៗ តម្រូវឲ្យមានការទាក់ទងផ្ទាល់រវាងវិនិយោគិន និងមន្ត្រីរដ្ឋាភិបាល។ ការធ្វើស្វ័យប្រវត្តិកម្មនីតិវិធីសំខាន់ៗរបស់រដ្ឋាភិបាល អាចជួយកាត់បន្ថយសកម្មភាពទាំងនេះបាន តាមរយៈការបំបាត់ចោលទំនាក់ទំនង ដោយផ្ទាល់រវាងភាគីនានា និងការបង្កើតបណ្តាញទំនាក់ទំនង (portal) តាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយតម្លាភាព ដើម្បីទទួលបានព័ត៌មានពីគោលការណ៍ និងនីតិវិធីចាំបាច់សម្រាប់ក្រុមហ៊ុន។ ការធ្វើស្វ័យប្រវត្តិកម្មអាចជួយក្នុងការបង្កើតកំណត់ត្រាប្រតិបត្តិការដែលអាចតាមដានបានរវាងរដ្ឋាភិបាល និងវិស័យឯកជន។ ដើម្បីសម្រេចការងារនេះ ការអនុម័តរបស់រដ្ឋសភាលើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នឹងជួយជំរុញឲ្យក្រុមហ៊ុនអាចទូទាត់សាច់ប្រាក់ សម្រាប់សេវារដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម កំពុងអនុវត្តការធ្វើស្វ័យប្រវត្តិកម្មនេះក្នុងផ្នែកគយ និងកំណែទម្រង់ព្រំដែន ការចុះបញ្ជីក្រុមហ៊ុនថ្មី និងវិញ្ញាបនបត្រប្រភពទំនិញ (CO) ដែលអាចធ្វើជាគំរូសម្រាប់ក្រសួងផ្សេងទៀត។

**គ. ជំរុញការវិនិយោគថ្មី ជាពិសេសក្នុងតំបន់សេដ្ឋកិច្ចពិសេស។** អ្វីដែលសំខាន់នោះ ត្រូវបញ្ចប់ការកែសម្រួលឡើងវិញលើច្បាប់វិនិយោគបច្ចុប្បន្ន តាមដែលអាចធ្វើទៅបាន ដើម្បីធ្វើទំនើបកម្មរបបដែលមានស្រាប់។ ប្រព័ន្ធផ្តល់ការលើកទឹកចិត្ត និងការការពារការវិនិយោគប្រកបដោយប្រសិទ្ធភាព អាចត្រួសត្រាយផ្លូវសម្រាប់វិនិយោគិនបរទេស ដែលសម្រេចចិត្តវិនិយោគក្នុងប្រទេសកម្ពុជា ដោយទទួលបានអត្ថប្រយោជន៍ពីការចំណាយ

លើកម្លាំងពលកម្មដែលមានលក្ខណៈប្រកួតប្រជែង និងទីតាំងភូមិសាស្ត្រអំណោយផលរបស់ខ្លួន នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។ រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាលើការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រធ្វើឲ្យគ្មានអំពើពុករលួយទាល់តែសោះ ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយក្នុងតំបន់សេដ្ឋកិច្ចពិសេស។ ការតាមដានយុទ្ធសាស្ត្រនេះ អាចធ្វើទៅបានក្នុងបរិយាកាសដែលមានការគ្រប់គ្រងក្នុងតំបន់សេដ្ឋកិច្ចពិសេស និងមានឥទ្ធិពលខ្លាំងដល់ការជំរុញឲ្យកម្ពុជាមានកេរ្តិ៍ឈ្មោះល្អ ដើម្បីក្លាយខ្លួនជាគោលដៅនៃការវិនិយោគផ្ទាល់ពីបរទេស។

**ឃ. បន្តកែលម្អកិច្ចសម្របសម្រួលពាណិជ្ជកម្ម ៖** ការកែលម្អសំខាន់ៗលើផ្នែកគយ មិនបានទុកឱកាសឲ្យមានភាពរីករាយភ្លេចខ្លួនឡើយ ដោយសារតែនៅមាននីតិវិធីស្មុគស្មាញ និងចំណាយពេលយូរក្នុងការបំពេញឯកសារដោយដៃ ដោយទីភ្នាក់ងារជាច្រើន មុនពេលផ្តល់លិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណនាំចេញនាំចូល។ តាម រយៈការសម្របសម្រួល និងធ្វើស្វ័យប្រវត្តិកម្មនីតិវិធីទាំងនេះ ក្នុងក្របខណ្ឌបញ្ជរតែមួយជាតិ (NSW) ប្រទេសកម្ពុជាអាចកែលម្អដំណើរការពាណិជ្ជកម្មរបស់ខ្លួនបានយ៉ាងល្អប្រសើរ ដោយចូលរួមចំណែកកាត់បន្ថយចំណាយក្នុងសកម្មភាពពាណិជ្ជកម្ម និងបង្កើនការ ប្រកួតប្រជែងរបស់ក្រុមហ៊ុន។

**ង. បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង** និងការបង្កើតទីភ្នាក់ងារឯករាជ្យទទួលបន្ទុកការប្រកួតប្រជែង នឹងអាចធានាឲ្យមានការប្រកួតប្រជែងដោយស្មើភាពគ្នារវាងក្រុមហ៊ុនទាំងអស់។

**ច. រៀបចំ និងអនុវត្តប្រព័ន្ធផ្តល់ការលើកទឹកចិត្តសម្រាប់ការចុះបញ្ជីអាជីវកម្ម** ដែលជំរុញឲ្យក្រុមហ៊ុនមានលក្ខណៈផ្លូវការ ដោយផ្តល់ផលប៉ះពាល់ជាអវិជ្ជមានខ្លាំងដល់ចំណូលសារពើពន្ធ និងផលិតភាពរបស់សហគ្រាស ដែលនឹងផ្តល់ផលប៉ះពាល់ល្អដល់សមត្ថភាពលូតលាស់របស់ក្រុមហ៊ុន និងលទ្ធភាពចូលក្នុងទីផ្សារបរទេស។ បទពិសោធន៍ពីប្រទេសផ្សេងទៀតបង្ហាញថា ការបន្ថយការចំណាយ និងភាពស្មុគស្មាញនៃការចុះបញ្ជីអាជីវកម្ម គឺជាចំណុចចាំបាច់ ប៉ុន្តែជាញឹកញាប់មិនមានវិធានការគ្រប់គ្រាន់ ហើយចាំបាច់ត្រូវមានការអនុវត្តឲ្យបានល្អ ក្នុងការជំរុញក្រុមហ៊ុនឲ្យប្រតិបត្តិការក្នុងប្រព័ន្ធផ្លូវការ[8]។

**៧. ផ្តោតលើការអនុវត្តច្បាប់ ៖** ជារឿយៗ បរិយាកាសច្បាប់របស់កម្ពុជាអនុលោមតាមវិធានល្អៗមានលក្ខណៈអន្តរជាតិ និងអនុលោមតាមការប្តេជ្ញាចិត្ត និងកាតព្វកិច្ចអន្តរជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ យ៉ាងណាក៏ដោយ សកម្មភាពក្រៅផ្លូវការនៅតែបន្តកើតមាន ដោយមានការអនុវត្តមិនល្អ បានរាំងស្ទះដល់ការសម្រេចបានគោលបំណងនៃការគ្រប់គ្រងទាំងនោះ។

[8] Bruhn និង McKenzie (2013) "លិខិតបទដ្ឋានសម្រាប់ការចាប់ផ្តើម និងការធ្វើឲ្យសហគ្រាសខ្នាតតូចមានលក្ខណៈផ្លូវការក្នុងប្រទេសកំពុងអភិវឌ្ឍន៍" ទំព័រ ១៧

# សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា

| | ឆ្នាំ 2012 | ឆ្នាំ 2013 | ឆ្នាំ 2014p | ឆ្នាំ 2015f | ឆ្នាំ 2016f |
|---|---|---|---|---|---|
| **លទ្ធផល ការងារ និងថ្លៃ** | | | | | |
| ផសស ពិត (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 7.3 | 7.4 | 7.2 | 7.5 | 7.2 |
| តម្រូវការក្នុងស្រុក(%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 14.9 | 12.1 | 12.4 | 11.0 | 10.7 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (%ប្រែប្រួលចុងគ្រា) | 2.5 | 4.6 | 5.0 | 5.5 | 6.0 |
| **វិស័យសាធារណៈ** | | | | | |
| ចំណូលរដ្ឋាភិបាល (% នៃផសស) | 15.3 | 15.1 | 16.1 | 16.4 | 16.4 |
| ចំណាយរដ្ឋាភិបាល(% នៃផសស) | 21.0 | 21.5 | 20.4 | 20.9 | 21.3 |
| តុល្យការរដ្ឋាភិបាលមិនគិតជំនួយឥតសំណង (% នៃផសស) | -5.7 | -6.4 | -4.3 | -4.5 | -4.9 |
| តុល្យការរដ្ឋាភិបាលគិតទាំងជំនួយឥតសំណង (% នៃផសស) | -3.3 | -2.7 | -2.5 | -3.5 | -3.3 |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងពាណិជ្ជកម្ម និងបំណុលបរទេស** | | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -2,455.7 | -2,598.4 | -2,908.3 | -2,955.7 | -2,856.1 |
| នាំចេញទំនិញ (លានដុល្លារអាមេរិក) | 5,632.8 | 6,890.2 | 8,193.4 | 9,700.2 | 11,571.6 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.9 | 22.3 | 18.9 | 18.4 | 19.3 |
| ការនាំចេញសំខាន់ៗ (% ប្រែប្រួលធៀបនឹងឆ្នាំមុន) 1/ | 7.0 | 17.6 | 15.0 | 15.5 | 15.0 |
| ការនាំចូលទំនិញ (លានដុល្លារអាមេរិក) | 8,088.5 | 9,488.6 | 11,101.7 | 12,655.9 | 14,427.7 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 20.6 | 17.3 | 17.0 | 14.0 | 14.0 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1,366.0 | -1,639.0 | -1,849.1 | -1,989.0 | -1,834.0 |
| (% នៃផសស) | -9.6 | -10.7 | -11.3 | -11.2 | -9.6 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | 1,404.8 | 1,298.8 | 1,380.0 | 1,400.0 | 1,450.0 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 4,559.3 | 5,124.1 | 5,630.6 | 6,019.1 | 6,380.5 |
| (% នៃផសស) | 32.1 | 33.3 | 34.4 | 33.9 | 33.3 |
| បំណុលរយៈពេលខ្លី (លានដុល្លារអាមេរិក) | - | - | - | - | - |
| អនុបាតសេវាបំណុល (% ការនាំចេញទំនិញនិងសេវា) | 1.1 | 1.1 | 1.2 | 1.1 | 1.3 |
| ទុនបំរុងជារូបិយបណ្ណបរទេសដុល(លានដុល្លារអាមេរិក) | 3,463.0 | 3,642.5 | 4,300.0 | 4,600.0 | 5,100.0 |
| (ចំនួនខែនៃការនាំចូលទំនិញនិងសេវា) | 3.1 | 3.4 | 3.5 | 3.3 | 3.2 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 29.6 | 26.7 | 20.0 | 19.5 | 18.0 |
| អត្រាការប្រាក់រយៈពេលខ្លី (%ក្នុងមួយឆ្នាំ) | 11.6 | 11.3 | 11.2 | 11.0 | 11.0 |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារអាមេរិក ចុងគ្រា) | 3,995.0 | 3,995.0 | 4,065.0 | 4,076.0 | 4,050.0 |
| អត្រាប្តូរប្រាក់ខ្មែរពិត(ឆ្នាំ2000=100) | 105.4 | 109.9 | 112.1 | 113.5 | 115.5 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 0.5 | 4.3 | 2.0 | 1.3 | 1.7 |
| អនុស្សារណៈ ផសសជាក់ស្តែង(លានដុល្លារអាមេរិក) | 14,188 | 15,373 | 16,367 | 17,759 | 19,173 |

ប្រភព ៖ ប្រភពទិន្នន័យជាតិ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

f = ព្យាករណ៍

p = ព្យាករណ៍ (គណនា)

1/ វិស័យកាត់ដេរ

2/ មិនគិតបង្វែរផ្លូវការ

WORLD BANK GROUP

ធនាគារពិភពលោក
ការិយាល័យប្រចាំប្រទេសកម្ពុជា
ផ្ទះលេខ113 មហាវិថីនរោត្តម
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (855-23) 861 300
ទូរសារ ៖ (855-23) 861 301/302
គេហទំព័រ ៖www.worldbank.org/cambodia